ENg

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ការអប់រំបរិស្ថាន

## កំរិតបឋមសិក្សា



## សៀវភៅសំរាប់គ្រូ

តុលា ១៩៩៧

ងបរិស្ថាន | ក្រសួងអប់រំយុវជន និងកីឡា | UNDP-ETAP

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំយុវជន និងកីឡា**

លេខ ..3164... អយក.ហវ

រាជធានីភ្នំពេញ ថ្ងៃទី២I ខែ[illegible] ឆ្នាំ ១៩៩៧

# រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**ជំរាបមក**

**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត - ក្រុង**

<u>កម្មវត្ថុ</u> : ការផ្សព្វផ្សាយ និងការប្រើប្រាស់សាកល្បងសៀវភៅអប់រំបរិស្ថាន តាមរយៈកំរងសាលារៀនបឋមសិក្សា ។

<u>យោង</u> : - លិខិតលេខៈ ១១២៦ អយក.ហវ ចុះថ្ងៃទី៧ ខែឧសភាឆ្នាំ១៩៩៧ ស្តីពីការបើកសិក្ខាសាលាអប់រំបរិស្ថានកំរិតបឋមសិក្សា ។

- លិខិតលេខៈ ២៣៧៥ អយក.ហវ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៧ ស្តីពីការអប់រំបរិស្ថានតាមរយៈកំរងសាលារៀនបឋមសិក្សា ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជំរាបលោកប្រធានថា ដើម្បីឱ្យការអប់រំបរិស្ថានមានប្រសិទ្ធភាពសំដៅរួមចំណែកថែរក្សាការពារបរិស្ថានជាតិឱ្យបានល្អប្រសើរ គណៈកម្មការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាននឹងមានផែនការចុះធ្វើទស្សនកិច្ចសិក្សា និងប្រជុំបច្ចេកទេសនៅតាមសាលាកំរងមួយក្នុងចំណោមសាលាកំរងដែលបានចូលរួមក្នុងសិក្ខាសាលាអំពីការការអប់រំបរិស្ថាន នាខែឧសភា-មិថុនា ១៩៩៧ កន្លងមក ។ ផែនការនេះរួមមាន :

១) គណៈកម្មការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន នឹងធ្វើការមកជូនរបាយការណ៍សិក្ខាសាលាគ្រប់ភូមិភាគទាំង ៦ ឱ្យដល់សិក្ខាកាមទាំងអស់ ជាពិសេស នាយកកំរង និងតំណាងគ្រូ ដែលបានចូលរួមសិក្ខាសាលា ដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាពសិក្ខាសាលាកន្លងមក ជាប្រយោជន៍សំរាប់ត្រៀមរៀបចំសកម្មភាពមួយចំនួនក្នុងការអនុវត្ត ការផ្សព្វផ្សាយ និងការប្រើប្រាស់សាកល្បងសៀវភៅសិក្សាអប់រំបរិស្ថាន តាមរយៈកំរងសាលារៀនរបស់ខ្លួន ។

**២) គណៈកម្មការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន និងអង្គការ UNDP/ETAP ត្រៀមរៀបចំចុះទៅចូលគ្នានរបស់អស់លោក-លោកស្រីដោយផ្ទាល់ ដើម្បីធ្វើការប្រជុំពិភាក្សាការងារបច្ចេកទេសមួយចំនួន**

ព្រមទាំងនាំមកជាមួយនូវឯកសារសៀវភៅសិក្សាអប់រំបរិស្ថាន ផ្ទាំងរូបភាព សៀវភៅរឿងនិទានរបស់អង្គការ JSRC និងការសែតរីចែតនូវទាក់ទងខ្លឹមសារអប់រំបរិស្ថាន ដើម្បីចែកជូនកំរងសាលានីមួយៗដែលបានចូលរួមសិក្ខាសាលា យកទៅអនុវត្ត ផ្សព្វផ្សាយបន្តដល់គ្រូទាំងអស់ក្នុងកំរង និងប្រើប្រាស់សាកល្បងក្នុងឆ្នាំសិក្សា ១៩៩៧-៩៨ នេះ ។

៣) គណៈកម្មការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន និងអង្គការ UNDP/ETAP នឹងចុះទៅតាមខេត្តរបស់លោក-លោកស្រី ចាប់ពីដើមខែវិច្ឆិកា ១៩៩៧នេះតទៅ តាមកាលបរិច្ឆេទ និងទីកន្លែងដូចមានភ្ជាប់មកជាមួយ ។

៤) ក្នុងដំណើរទស្សនកិច្ចរបស់គណៈកម្មការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន និងអង្គការUNDP/ETAP មានបំណងជួបជាមួយនាយក ឬនាយករងកំរងសាលារៀន និងតំណាងគ្រូ ដោយមានកិច្ចសហការពីមន្ទីរ និងការិយាល័យ អប់រំយុវជន និងកីឡា ។

៥) សមាសភាពប្រតិភូ ដែលចុះធ្វើទស្សនៈកិច្ចសិក្សា និងប្រជុំបច្ចេកទេសនេះរួមមាន :

- តំណាងគណៈកម្មការ អន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន .................... ១នាក់
- តំណាងគ្រូឧទ្ទេស .................................................................... ១នាក់
- តំណាងបុគ្គលិក UNDP/ETAP .................................................. ១នាក់

ម្យ៉ាងទៀត ដើម្បីឱ្យការបញ្ជ្រាបការអប់រំបរិស្ថានទៅក្នុងមុខវិជ្ជាគោលទាំង៤ និងដើម្បីឱ្យការសាកល្បងកែលំអសៀវភៅអប់រំបរិស្ថានមានប្រសិទ្ធភាព ក្រសួង សូមធ្វើការណែនាំបច្ចេកទេសបន្ថែមដូចតទៅ :

១- ប្រធានមន្ទីរត្រូវធ្វើការទាក់ទងការងារបរិស្ថានជាមួយនាយកកំរង និងតំណាងគ្រូដែលបានចូលរួមសិក្ខាសាលា ដើម្បីកំណត់ការងារដែលត្រូវធ្វើបន្ត និងរៀបចំកាលវិភាគនៃការអប់រំបរិស្ថានឱ្យបានជាក់លាក់ក្នុងកំឡុងឆ្នាំសិក្សា ១៩៩៧-៩៨ នេះ ។

២- ប្រធានមន្ទីរត្រូវធ្វើការសំរបសំរួល និងសហការជាមួយនាយកកំរង និងតំណាងគ្រូ ដែលបានចូលរួមសិក្ខាសាលា ដើម្បីជ្រើសរើសគ្រូបង្គោលទទួលបន្ទុកការអប់រំបរិស្ថានចំនួនបីនាក់ទទួលខុសត្រូវសំរាប់កំរិតទី ១ (ថ្នាក់ ទី ១-២) កំរិតទី ២ (ថ្នាក់ទី ៣-៤) និងកំរិតទី ៣ (ថ្នាក់ទី ៥-៦) នៅក្នុង សាលាបង្គោល និងសាលាសម្ព័ន្ធនីមួយៗ ។

៣- នាយកកម្រងសាលានីមួយៗ ដែលចូលរួមសិក្ខាសាលាត្រូវរៀបចំការប្រជុំបច្ចេកទេសការងារអប់រំបរិស្ថាន នៅរៀងរាល់ថ្ងៃព្រហស្បតិ៍ ដើម្បីផ្សព្វផ្សាយឱ្យគ្រូក្រោមឱវាទទាំងអស់បានជ្រាបអំពីខ្លឹមសារនៃការអប់រំបរិស្ថាន និងរៀបចំផែនការ និងវិធីបញ្ជ្រាបតាមមុខវិជ្ជានីមួយៗ ។

៤- រាល់ការប្រជុំបច្ចេកទេស ដែលទាក់ទងនឹងការងារអប់រំបរិស្ថានត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការកម្រងស្រុក-ខេត្ត និងគណៈកម្មការអន្តរក្រសួង ដឹកនាំការអប់រំបរិស្ថាន ។

៥- របាយការណ៍ត្រូវយកចិត្តទុកដាក់លើចំនុចខ្វះខាតនៃការបង្រៀន និងការកែលំអសៀវភៅសិក្សាអប់រំបរិស្ថាន ។

៦- នាយកកំរងត្រូវសំរបសំរួលការប្រើប្រាស់សៀវភៅរឿងនិទាន បោះពុម្ពផ្សព្វផ្សាយដោយអង្គការ JSRC មានចែកជូន ១ក្បាលក្នុងមួយរឿង សំរាប់កម្រងនីមួយៗ ដែលមានតំកល់នៅក្នុងបណ្ណាល័យនៃមជ្ឈមណ្ឌលធនធានកម្រងសាលាសំរាប់ឱ្យគ្រូខ្ចីយកទៅបង្រៀន ។

៧- នាយកកំរង រួមជាមួយប្រធានមន្ទីរ ត្រូវសហការរៀបចំគំរូនៃការដឹកនាំ ការអនុវត្តវិធីរបៀបប្រើប្រាស់ និងសាកល្បងសៀវភៅសិក្សាអប់រំបរិស្ថាន ដោយមានជាលាយលក្ខណ៍អក្សរ ជាឯកសារសំរាប់ប្រតិភូពិនិត្យពេលចុះទៅធ្វើទស្សនកិច្ចម្តងៗ ។

៨- នាយកកំរងត្រូវរៀបចំរាល់កាលវិភាគ និងទីកន្លែងឲ្យស់លាស់សំរាប់ គណៈកម្មការអន្តរក្រសួងដឹកនាំការអប់រំបរិស្ថាន និង ETAP សំរាប់ធ្វើការប្រជុំបង្ហូកខេស និងបូកសរុប វាយតំលៃលើគំរោងការងារ ។

៩- ដោយមានកិច្ចសហការពីមន្ទីរ និងការិយាល័យ អប់រំយុវជន និងកីឡា នាយកកំរងត្រូវសំរបសំរួលការងារប្រជុំ ដោយមានវត្តមាននាយកកំរង និងតំណាងគ្រូពីកំរងសាលាផ្សេងៗទៀតដែលបានចូលរួមសិក្ខាសាលាអប់រំបរិស្ថាន និងគ្រូបង្គោលទទួលបន្ទុកការងារបរិស្ថាននៅក្នុងគ្រប់សាលាក្នុងកំរង ឬបើមានលទ្ធភាព អញ្ជើញគ្រូបង្គោលទទួលបន្ទុកការងារបរិស្ថាននៅកំរងសាលាណាដែលនៅជិត ។

ក្រសួងសង្ឃឹមថា លោកប្រធាននឹងអនុវត្តតាមស្មារតីលិខិតនេះឱ្យមានប្រសិទ្ធភាពខ្ពស់ជាមិនខាន ។

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

<u>ចំលងជូន</u> :

- សាលាខេត្ត-ក្រុងជាក់ព័ន្ធ
- ក្រសួងបរិស្ថាន
- ក្រសួងធម្មការ និងកិច្ចការសាសនា
  "ដើម្បីជូនជ្រាបជាពត៌មាន"
- នាយកដ្ឋានជាក់ព័ន្ធ
- កាលប្បវត្តិ
- ឯកសារ : នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ

# ការអប់រំបរិស្ថាន

## កំរិតបឋមសិក្សា

**គណៈកម្មការអន្តរក្រសួង ដឹកនាំ ការងារអប់រំបរិស្ថាន និងត្រួតពិនិត្យ**

លោក សំខាន់ ឌី
លោក ណាត ប៊ុនរឿន
លោកស្រី ញឹម វ៉ាន់ច័ន្ទកន
លោក សំ យ៉េន
លោក គីម ខាយ

**គណៈកម្មការនិពន្ធ និងរៀបរៀង**

លោក អ៊ុង ប៊ុនធឿន
លោក អ៊ុក ស៊ីសុវណ្ណ
លោក សម វ៉ាន់នី
លោក ហង្ស យុត
លោក ស៊ី វ៉ារុធ

**វិចិត្រករ**

លោក ឯម សត្យា

**អនុគណៈកម្មការគ្រូឧទ្ទេស**

លោក សម វ៉ាន់នី
លោកស្រី ស៊ឹម ពិដោរ
លោក រដ្ឋ សិទ្ធិ
លោក អៀត ប៊ុនឡេង

**ទីប្រឹក្សា**

លោក Peter Johnston
លោក Peter Gyallay-Pap
កញ្ញា Sylvia Reyes

**នាយកផលិតឯកសារវីឌីអូក្នុងសិក្ខាសាលាអប់រំបរិស្ថានទាំង៦ភូមិភាគ**

លោក ស៊ូ ស៊ូរ៉ុធ

**វាយកុំព្យូទ័រ**

កញ្ញា ហ៊ូ កល្យាណ

This draft *Primary School Teachers' Manual on Environmental Education* was prepared by the Inter-Ministerial Steering Committee for Environmental Education (IMSCEE) with technical assistance from UNDP's Environmental Technical Advisory Programme (ETAP). The writing, editing, and printing of this manual was supported UNDP/ETAP with additional funding from the Norwegian Agency for Development (NORAD).

Phnom Penh, October 1997

# អារម្ភកថា

ឯកសារសិក្សាស្តីពីការអប់រំបរិស្ថានដែលលោក លោកស្រីកំពុងអាននេះ ជាឯកសារសំរាប់ គ្រូបង្រៀននៅសាលាបឋមសិក្សា ។ ឯកសារនេះបានរៀបចំឡើងដោយគណៈកម្មការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន ។ សមាជិកនៃគណៈកម្មការអន្តរក្រសួងរួមមាន ក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងធម្មការ និងកិច្ចការសាសនា និងសមាគមពុទ្ធិកសិក្សា (វត្តសំរោងអណ្តែត) ។ ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុសំរាប់ដំណើរការរៀបចំ តាក់តែង និងបោះពុម្ពផ្សាយត្រូវបានឧបត្ថម្ភតាមរយៈកម្មវិធីជំនួយបច្ចេកទេសបរិស្ថាន (Environmental Technical Advisory Programme/ ETAP) នៃកម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិ (United Nations Development Programme/UNDP) ។

គណៈកម្មការអន្តរក្រសួងបានរៀបចំឯកសារ ដើម្បីបំប៉ន និងណែនាំគ្រូបង្រៀន ដោយផ្អែកលើចំណេះដឹងជាមូលដ្ឋានស្តីពីបរិស្ថាន ។ វត្ថុបំណងនៃឯកសារនេះ គឺបញ្ជ្រាបការអប់រំ បរិស្ថានទៅក្នុងកម្មវិធីសិក្សាកំរិតបឋមសិក្សា ដែលកំពុងអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ឯកសារនេះមានគោលបំណងផ្តល់ពុទ្ធិងាយៗស្តីពីបរិស្ថានដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស ដើម្បីធ្វើឱ្យគេ រីករាយនឹងបញ្ចេញគំនិត ហើយចូលរួមក្នុងការការពារ និងថែរក្សាបរិស្ថានជាតិ ។

ឯកសារនេះត្រូវបានកែលំអដោយផ្អែកលើមតិយោបល់ និងសំណូមពររបស់សិក្ខាកាមដែលបានចូលរួមវគ្គសិក្ខាសាលាស្តីពីការអប់រំបរិស្ថានកំរិតបឋមសិក្សាតាមរយៈកំរងសាលា នៅភូមិភាគកណ្តាល តាកែវ បាត់ដំបង ស្ទឹងត្រែង សៀមរាប និងក្រុងព្រះសីហនុ ក្នុងអំលុងខែឧសភា និងមិថុនា ឆ្នាំ ១៩៩៧ កន្លងមកនេះ ។ ចំពោះការបោះពុម្ពលើកនេះ មេរៀន និងលំហាត់ត្រូវបានរៀបចំនៅក្នុងម៉ូឌុលតែមួយ ។

យើងជឿជាក់ថា ឯកសារនេះនឹងក្លាយទៅជាឧបករណ៍មួយប្រកបដោយប្រសិទ្ធភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាជំនួយដល់អ្នកគ្រូ-លោកគ្រូនៅសាលាបឋមសិក្សាក្នុងការយល់ដឹងពីបរិស្ថាន និងការអប់រំបរិស្ថាន ។ យើងសង្ឃឹមថា ឯកសារនេះនឹងជួយកែលំអដល់វិស័យបរិស្ថាន និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគ្រប់រូបជាមិនខាន ។

" ការអប់រំបរិស្ថាន ជាភារកិច្ចរបស់យើងទាំងអស់គ្នា "

គណៈកម្មការអន្តរក្រសួង
ដឹកនាំការងារអប់រំបរិស្ថាន

# បញ្ជីមាតិកា

**ចំណងជើង** **ទំព័រ**


អារម្ភកថា ............ i

ការណែនាំសំរាប់គ្រូបង្រៀន ............ ១

**ជំពូកទី១ : បរិស្ថានជាអ្វី** ............ ៧

**មេរៀន :**

- *វគ្គទី១ : និយមន័យ និងការយល់ដឹងអំពីបរិស្ថាន* ............ ៧

ក. បរិស្ថានធម្មជាតិជាអ្វី ............ ៧

ខ. បរិស្ថានសង្គម-វប្បធម៌ជាអ្វី ............ ៩

គ. បរិស្ថានមនុស្សជាអ្វី ............ ១០

- *វគ្គទី២ : ការសិក្សាអំពីបញ្ញត្តិបរិស្ថាន* ............ ១២

ក. ទំនាក់ទំនងរវាងបរិស្ថានទាំង៣ ............ ១២

ខ. ឥទ្ធិពលរបស់មនុស្សចំពោះបរិស្ថាន ............ ១៣

គ. បរិស្ថានតែងមានការផ្លាស់ប្តូរជានិច្ច ............ ១៣

- *សង្ខេបមេរៀន* ............ ១៤

**សំភារៈ :**

១- កុមារគង្វាលចៀម និងដើមជ្រៃ ............ ១៦

២- កង្កែប និងក្អាម ............ ១៨

៣- ការកំណត់លក្ខណៈរវាងភាវៈមានជីវិត និងភាវៈគ្មានជីវិត ............ ២០

៤- ការប្រែប្រួលបរិស្ថាន ............ ២៣

៥- ការដឹងស្គាល់បរិស្ថាន ............ ២៥

៦- កំណាព្យ : សំរស់បរិស្ថាន ............ ២៦

៧- ចំរៀង : បរិស្ថានជាអាយុជីវិតនៃយើង ............ ២៨

**ជំពូកទី២ : បរិស្ថាន និងវប្បធម៌** ............ ៣០

**មេរៀន :**

ក. ទំនាក់ទំនងរវាងវប្បធម៌ និងសង្គម ............ ៣០

ខ. សង្គម និងវប្បធម៌ខ្មែរ ............ ៣០

គ. ព្រះពុទ្ធសាសនា និងវប្បធម៌ខ្មែរ ............ ៣១

- *សង្ខេបមេរៀន* ............ ៣៣

**សំភារៈ :**

១- រុក្ខទេពធីតា និងភិក្ខុមួយអង្គ ........ ៣៥
២- សំរង់បញ្ជីសារពើភ័ណ្ឌរបស់វត្ត ........ ៣៨
៣- កំណាព្យ : ត្រូវជួយថែរក្សាបរិស្ថានវប្បធម៌ប្រាសាទអង្គរ ........ ៤០
៤- ចំរៀង : យើងការពារបរិស្ថាន ........ ៤២
**ជំពូកទី៣ : រុក្ខជាតិមែនជាប្រភពអាហារ** ........ ៤៤
**មេរៀន :**
ក. សារៈសំខាន់នៃរុក្ខជាតិ ........ ៤៤
ខ. រស្មីសំយោគជាអ្វី ........ ៤៤
គ. ខ្សែអាហារជាអ្វី ........ ៤៥
• *សង្ខេបមេរៀន* ........ ៤៦
**លំហាត់ :**
១- ដង្កូវ និងក្អែក ........ ៤៨
២- ទន្សាយ និងចេក ........ ៥០
៣- ខ្សែអាហារ ........ ៥២
៤- ទំនាក់ទំនងរវាងរុក្ខជាតិបៃតង និងសត្វ ........ ៥៤
៥- ការដឹងស្គាល់វដ្តអាហារ ........ ៥៧
៦- កំណាព្យ : សារៈសំខាន់នៃរុក្ខជាតិ ........ ៥៩
៧- ចំរៀង : រុក្ខជាតិជាប្រភពអាហារ ឱសថ និងជាបរិស្ថាន ........ ៦១
**ជំពូកទី៤ : ទឹកជាប្រភពនៃជីវិត** ........ ៦៣
**មេរៀន :**
ក. សារៈសំខាន់នៃទឹក ........ ៦៣
ខ. ទឹកនៅក្នុងប្រទេសកម្ពុជា ........ ៦៤
គ. គ្រោះថ្នាក់បង្កឡើងដោយទឹក ........ ៦៥
• *សង្ខេបមេរៀន* ........ ៦៦
**លំហាត់ :**
១- សង្គ្រាមរវាងតឹង្កក់ និងតាព្រហ្ម ........ ៦៨
២- កបិលមហាព្រហ្ម ........ ៧០
៣- ផ្កា និងពពក ........ ៧២
៤- អនាម័យប្រភពទឹក ........ ៧៤
៥- សញ្ញាណនៃវដ្តទឹក ........ ៧៦
៦- អង្កេតស្រាវជ្រាវអំពីប្រភពទឹកមាននៅក្នុងភូមិ ........ ៧៨

៧- កំណាព្យ : ការពារប្រភពទឹក ........ ៨០
៨- ចំរៀង : ផលប្រយោជន៍នៃទឹក ........ ៨៣
**មុំខុលទី៥ : ព្រះអាទិត្យ** ........ ៨៥
**មេរៀន :**
ក. ព្រះអាទិត្យជាអ្វី ........ ៨៥
ខ. ផលប្រយោជន៍របស់ព្រះអាទិត្យ ........ ៨៦
គ. គ្រោះថ្នាក់បណ្ដាលមកពីព្រះអាទិត្យ ........ ៨៦
ឃ. គ្រោះថ្នាក់បណ្ដាលមកពីផែនដីឡើងកំដៅ ........ ៨៦
• *សង្ខេបមេរៀន* ........ ៨៧
**លំហាត់ :**
១- ព្រះអាទិត្យនៅឯណា ........ ៨៩
២- ថាមពលព្រះអាទិត្យ ........ ៩២
៣- កំសាន្តជាមួយនឹងស្រមោលម្រាមដៃ ........ ៩៤
៤- ថាមពល ........ ៩៧
៥- ពណ៌នៃពន្លឺព្រះអាទិត្យ ........ ៩៩
**មុំខុលទី៦ : សត្វព្រៃ** ........ ១០២
**មេរៀន :**
ក. សត្វព្រៃជាអ្វី ........ ១០២
ខ. សត្វព្រៃ និងមនុស្ស ........ ១០៣
គ. សត្វព្រៃ និងព្រះពុទ្ធសាសនា ........ ១០៤
ឃ. ការគំរាមកំហែងសត្វព្រៃ ........ ១០៤
• *សង្ខេបមេរៀន* ........ ១០៥
**លំហាត់ :**
១- ចចក ........ ១០៧
២- វិប្បដិសារីនៃអ្នកប្រមាញ់ម្នាក់ ........ ១០៩
៣- យើងរក្សាការពារសត្វព្រៃ ........ ១១២
៤- ការអង្កេតសត្វតូចៗ និងសត្វល្អិត ........ ១១៧
៥- យើងនាំគ្នាការពារ ថែរក្សាសត្វព្រៃរបស់យើង ........ ១១៩
៦- កំណាព្យ : វាចាសត្វព្រៃ ........ ១២២
៧- ចំរៀង : ទំនួញសត្វព្រៃ ........ ១២៤

**មុខលទី៧ : ដើមឈើ និងព្រៃឈើ** ........ ១២៦
**មេរៀន :**
ក. តួនាទីរបស់ដើមឈើ ........ ១២៦
ខ. តួនាទីរបស់ព្រៃឈើ ........ ១២៦
គ. ព្រៃឈើ និងវប្បធម៌ខ្មែរ ........ ១២៧
ឃ. មូលហេតុនៃការបាត់បង់ព្រៃឈើនៅប្រទេសកម្ពុជា ........ ១២៧
ង. ផលវិបាកនៃការបាត់បង់ព្រៃឈើ ........ ១២៨
ច. មធ្យោបាយការពារព្រៃឈើ ........ ១២៨
• *សង្ខេបមេរៀន* ........ ១២៩
**លំហាត់ :**
១- ភ្នំត្រធិល ........ ១៣១
២- បណ្ដាំព្រៃឈើ ........ ១៣៣
៣- ផលវិបាកបណ្ដាលមកពីការគ្មានព្រៃឈើ ........ ១៣៥
៤- សំណឹកដីដោយសារទឹក ........ ១៣៧
៥- ទស្សនៈកិច្ចព្រៃព្រឹក្សា ........ ១៣៩
៦- កំណាព្យ : ស្លាប់រស់ព្រោះព្រៃឈើ ........ ១៤០
៧- ចំរៀង : មិត្តអើយចងចាំ ........ ១៤៣
**មុខលទី៨ : ធនធានធម្មជាតិ** ........ ១៤៥
**មេរៀន :**
ក. ធនធានធម្មជាតិជាអ្វី ........ ១៤៥
ខ. មនុស្ស និងធនធានធម្មជាតិ ........ ១៤៥
គ. ថាមពល និងការប្រើប្រាស់ធនធានធម្មជាតិ ........ ១៤៦
ឃ. ការប្រើប្រាស់ប្រភពថាមពលដែលអាចកើតឡើងជាថ្មី ........ ១៤៧
ង. ព្រៃឈើសហគមន៍ជាអ្វី ........ ១៤៧
• *សង្ខេបមេរៀន* ........ ១៤៨
**លំហាត់ :**
១- ស្រមោច និងខ្លាឃ្មុំ ........ ១៥០
២- ធនធានធម្មជាតិក្នុងប្រទេសយើង ........ ១៥៥
៣- ធនធានធម្មជាតិនៅប្រទេសកម្ពុជា ........ ១៥៧
៤- ការដាំកូនឈើនៅក្នុងបរិវេណសាលារៀន ........ ១៥៨
៥- កំណាព្យ : ធនធានស្រុកខ្មែរ ........ ១៥៩

៦- ចំរៀង : អនិច្ចាជាតិខ្មែរ ........ ១៦១
**ជំពូកទី៩ : ការបំពុលបរិស្ថាន** ........ ១៦៣
**មេរៀន :**
ក. ការបំពុលបរិស្ថានជាអ្វី ........ ១៦៣
ខ. ឥទ្ធិពលនៃការបំពុលបរិស្ថាន ........ ១៦៥
គ. វិធីទប់ស្កាត់ និងកាត់បន្ថយការបំពុល ........ ១៦៥
• *សង្ខេបមេរៀន* ........ ១៦៦
**សំណាត់ :**
១- ប្រយ័ត្ន ! បន្លែ ផ្លែឈើពុល ........ ១៦៨
២- មេទា និងខ្លែចចក ........ ១៧១
៣- ការកាត់បន្ថយភាពកខ្វក់ ........ ១៧៣
៤- កាត់បន្ថយភាពកខ្វក់ដែលកើតពីសំរាម ........ ១៧៦
៥- ការស្ទង់ពិនិត្យមើលចរាចរនៅទីប្រជុំជន ........ ១៨០
៦- កំណាព្យ : បរិស្ថាន និងការបំពុល ........ ១៨២
៧- ចំរៀង : សំណោកបរិស្ថាន ........ ១៨៥
**ជំពូកទី១០ : គុណភាពនៃជីវិត** ........ ១៨៧
**មេរៀន :**
ក. គុណភាពនៃជីវិតជាអ្វី ........ ១៨៧
ខ. ទឹក ចំណីអាហារ និងសុខភាព ........ ១៨៨
គ. មាគ៌ាសីលធម៌ និងគុណភាពនៃជីវិត "សីលធម៌បរិស្ថាន" ........ ១៨៩
• *សង្ខេបមេរៀន* ........ ១៩០
**សំណាត់ :**
១- តើរកផ្លូវសុភមង្គលដោយរបៀបណា ........ ១៩២
២- ការភ្ញាក់រលឹករបស់ពួកប្រមាញ់មួយក្រុម ........ ១៩៥
៣- ប្រយោជន៍រួមធំជាងប្រយោជន៍ផ្ទាល់ខ្លួន ........ ១៩៧
៤- កំណាព្យ : បណ្តាំចំពោះកូនខ្មែរ ........ ១៩៩
៥- ចំរៀង : ស្រណោះស្រុកខ្មែរ ........ ២០២
**វាក្យស័ព្ទ** ........ ២០៤
**ឯកសារពិគ្រោះ** ........ ២០៩

ជំពូកទី
៨

# ធនធានធម្មជាតិ

**វត្ថុបំណង** : ជំរុញសិស្សឱ្យបង្កើនមនសិការម្ចាស់ការលើការគ្រប់គ្រង និងថែរក្សា ការពារឱ្យបានគង់វង្សល្អ ចំពោះធនធានធម្មជាតិដែលមាននៅជុំវិញផ្ទះ និងសហគមន៍ ។

**លទ្ធផល** : សិស្សយល់ដឹងអំពីធនធានធម្មជាតិដែលជាប្រភពសំភារៈសំរាប់ប្រើប្រាស់ក្នុងភូមិ ស្រុក និងសហគមន៍ ។

**សំណូមពរ** : ខ្ទឹមសារមេរៀន និងសំភារៈឧបទេសត្រូវសំរបសំរួលតាមកំរិតរបស់សិស្ស ។

## ក. ធនធានធម្មជាតិជាអ្វី

ធនធានធម្មជាតិជាអ្វីៗទាំងឡាយ ដែលកើតឡើងនៅក្នុងធម្មជាតិ ។ ទោះជាភាវៈមានជីវិតក្តី គ្មានជីវិតក្តី ដូចជា ទឹក ដី ព្រៃឈើ សត្វព្រៃ រ៉ែ សមុទ្រ ភ្នំ បឹង ទន្លេ ពន្លឺព្រះអាទិត្យ ខ្យល់ ។ល។ ក៏សុទ្ធតែមានតំលៃសំរាប់ខ្លួនផ្ទាល់ និងសំរាប់ជីវភាពរស់នៅរបស់មនុស្សដែរ ។

បច្ចុប្បន្ននេះ មានបញ្ហាបរិស្ថានជាច្រើននៅជុំវិញពិភពលោក ។ បញ្ហានេះបណ្តាលមកពីមនុស្សធ្វើអាជីវកម្មទាញយកផលពីធនធានធម្មជាតិនៅលើផែនដី ដោយពុំគិតដល់និរន្តរភាពបរិស្ថាន ។ ធនធានធម្មជាតិចែកចេញជាពីរផ្នែកគឺ ធនធានធម្មជាតិអាចកើតឡើងជាថ្មី និងមិនអាចកើតឡើងជាថ្មី ។ ឧទាហរណ៍ : ធនធានធម្មជាតិដែលមិនអាចកើតឡើងជាថ្មី ឬមានកំណត់ ដូចជា ប្រេងកាត រ៉ែខនិជ រ៉ែដែក រ៉ែមាស ថ្មភ្នំ ។ល។ ដែលគេទាញយកពីក្រោមសំបកផែនដី ។ ចំពោះធនធានធម្មជាតិ ដែលអាចកើតមានជាថ្មីដូចជា ថាមពលព្រះអាទិត្យ ទឹក ខ្យល់ (ធនធានព្រៃឈើ ធនធានត្រី ប្រសិនបើយើងប្រើប្រាស់វាសមហេតុផល) ។ល។

## ខ. មនុស្ស និងធនធានធម្មជាតិ

នៅពេលដែលមនុស្សចាត់ទុកខ្លួនឯងថាជាផ្នែកមួយដាច់ចេញពីបរិស្ថាន នោះគេយល់ឃើញថា ធម្មជាតិគ្រាន់តែជាប្រភពធនធានមួយ សំរាប់ទាញយកផលប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ប៉ុន្តែការពិត មនុស្សយើងគ្រាន់តែជាពំពួកសត្វមួយប្រភេទនៅក្នុងចំណោមសត្វជាច្រើនប្រភេទ ដែលរួមគ្នាបង្កើតបានជាឋានប្រព័ន្ធ (ឬប្រព័ន្ធអេកូឡូស៊ី) ។

ប្រព័ន្ធអេកូឡូស៊ីជាប្រព័ន្ធទំនាក់ទំនងអន្តរកម្មរវាងភាវៈមានជីវិត ដូចជា រុក្ខជាតិ សត្វ និងមីក្រុប និងផ្នែកផ្សេងៗទៀតរបស់បរិស្ថាន ។ មនុស្សគ្មានលទ្ធភាពក្នុងការគ្រប់គ្រងឋានប្រព័ន្ធដ៏ស្មុគស្មាញនៅលើផែនដីនេះឡើយ ។ ដូច្នេះគួរតែកុំសាកល្បងឱ្យសោះ ។ ប៉ុន្តែមនុស្សអាចគ្រប់គ្រងសកម្មភាពរបស់ខ្លួនតាមរយៈឋានប្រព័ន្ធក្នុង ឬជុំវិញផ្ទះ និងសហគមន៍ដោយផ្អែកលើលទ្ធភាព និងការចាំបាច់ ។ នេះជាគន្លឹះនៃនិរន្តរភាព ។ មនុស្សអាចអភិវឌ្ឍសង្គមរបស់ខ្លួន ដោយមិនចាំបាច់ធ្វើឱ្យខូចខាតដល់បរិស្ថានឡើយ ប្រសិនបើគេចេះគ្រប់គ្រងទំនាក់

ទំនងរបស់ខ្លួនបានល្អជាមួយថានប្រព័ន្ធ ដែលគេជាផ្នែកមួយដែរនោះ ។ នេះបានន័យថា យើងត្រូវរៀនយកចិត្តទុកដាក់ថែរក្សា និងប្រើប្រាស់ធនធានធម្មជាតិក្នុងរបៀបមួយប្រកបដោយនិរន្តរភាព ។

◇? *ឱ្យសិស្សកំណត់ប្រភេទធនធានធម្មជាតិ ដែលមានក្នុងសហគមន៍ជុំវិញសាលារៀន ។*
(ឧទាហរណ៍ : សត្វព្រៃ ប្រភពទឹក ដើមឈើ ព្រៃភ្នំ សមុទ្រ រ៉ែ ។ល។)

## គ. ថាមពល និងការប្រើប្រាស់ធនធានធម្មជាតិ

ការបំប្លែងធនធានធម្មជាតិ ឱ្យទៅជាធនធានសង្គម-វប្បធម៌ ដូចជាខ្មៅដៃ សៀវភៅ កៅអី តុ រទេះ សំណង់អគារ ផ្លូវថ្នល់ជាដើម តំរូវឱ្យមានការប្រើប្រាស់ថាមពល និងកំលាំងមនុស្ស ។ បញ្ហានេះគឺស្ថិតនៅត្រង់ថា មនុស្សយើងប្រើប្រាស់ថាមពលដែលមាននៅជុំវិញពិភពលោកដោយរបៀបណាដើម្បីឱ្យមាននិរន្តរភាព ។ ការប្រើប្រាស់ថាមពលនៅប្រទេសកំពុងអភិវឌ្ឍ និងប្រទេសរីកចំរើនភាគច្រើន បានពឹងផ្អែកលើប្រភពថាមពលដែលមិនអាចកើតមានឡើងជាថ្មី ដូចជា ប្រេងឥន្ធនៈ (សាំង.ម៉ាស៊ូត) ធ្យូងថ្ម ឧស្ម័ន រ៉ែ ។ល។ ប្រភពថាមពលទាំងនេះ ពុំមានជារៀងរហូតទេ ។ ពីព្រោះវាមានកំណត់ និងមិនអាចកើតមានឡើងជាថ្មីឡើយ ។ ម៉្យាងទៀត ការប្រើប្រាស់ប្រភពថាមពលប្រភេទនេះ អាចបង្កឱ្យមានការបំពុលដ៏សំបើមនៅក្នុងបរិស្ថានទៀតផង ។ ផ្សែងដែលចេញពីចំហេះប្រេងឥន្ធនៈ និងឧស្ម័នផ្សេងៗជាកត្តារួមចំណែកដ៏ធំបំផុតដល់ការបំពុលបរិយាកាស និងការឡើងកំដៅរបស់ផែនដី (សូមមើលមេរៀនទី៥) ។



## ឃ. ការប្រើប្រាស់ប្រភពថាមពលដែលអាចកើតឡើងជាថ្មី

មធ្យោបាយមួយសំរាប់ជួយមនុស្សធ្វើឱ្យបរិស្ថានមានភាពប្រសើរឡើង គឺការប្រើប្រាស់ប្រភព ថាមពលដែលអាចកើតឡើងជាថ្មី ដូចជា ថាមពលព្រះអាទិត្យ ខ្យល់ ទឹក ។ល។ ជាឧទាហរណ៍សំរាប់យើងអាចទាញយកពីបរិស្ថានធម្មជាតិ ។ ប្រភពថាមពលដ៏ចាស់បំផុតមួយនៅលើពិភពលោកគឺ ជីវរូប (Biomass) ដែលមានថាមពលផ្ទុកនៅក្នុងសារធាតុរុក្ខជាតិ ដូចជា ឈើកំពុក កាកសំណល់ ឬលាមកសត្វ និងសារធាតុសរីរាង្គផ្សេងៗទៀត ។ ការប្រើប្រាស់ជីវរូប ក៏រិតតូច (ក្នុងស្រុក) អាចបង្កគ្រោះថ្នាក់ដល់បរិស្ថានបន្តិចបន្តួច ប៉ុណ្ណោះ ។

ព្រះអាទិត្យបានផ្តល់ថាមពលកំដៅ និងពន្លឺ ។ បច្ចុប្បន្ននេះ មានប្រទេសជាច្រើនបានបំប្លែងថាមពលនេះឱ្យទៅជាថាមពលអគ្គិសនី ។ ថាមពលព្រះអាទិត្យក៏អាចប្រើសំរាប់ចំអិនអាហារបានដែរ ។ ប្រជាជនជាច្រើននៅព្រះរាជាណាចក្រកម្ពុជា និងនៅប្រទេសជិតខាងបានប្រើប្រាស់កំដៅព្រះអាទិត្យសំរាប់ហាលត្រី និងម្ហូបអាហារផ្សេងៗទៀត ។

គេបានបង្កើតចង្ក្រានផ្តល់ថាមពលដែលមានប្រសិទ្ធភាពដោយប្រើប្រាស់អុសតិច ។ ប្រការនេះរួមចំណែកជួយសង្គ្រោះព្រៃឈើនៅប្រទេសកម្ពុជាឱ្យផុតពីគ្រោះថ្នាក់បាន ។ គេប្រើរហាត់ទឹកនៅតាមដងស្ទឹង ទន្លេ សំរាប់ជាមធ្យោបាយស្រោចស្រពស្រែចំការ និងទាញយកថាមពលអគ្គិសនីសំរាប់ប្រើប្រាស់ក្នុងមូលដ្ឋាន និងសហគមន៍ ។

## ង. ព្រៃឈើសហគមន៍ជាអ្វី

នៅពេលដែលប្រជាជនមូលដ្ឋានរស់នៅក្នុង ឬក្បែរព្រៃឈើ ពួកគេតែងតែយកចិត្តទុកដាក់ថែរក្សា និងគ្រប់គ្រងព្រៃឈើនោះសំរាប់បំពេញជីវភាពរស់នៅមួយផ្នែករបស់ខ្លួន ។ នេះជាឧទាហរណ៍មួយដែលបញ្ជាក់ពីព្រៃឈើសហគមន៍ ។ ព្រៃឈើសហគមន៍ មានន័យថា មនុស្សប្រើប្រាស់ព្រៃឈើក្នុងរបៀបមួយដែលធានានិរន្តរភាព ដើម្បីឱ្យព្រៃឈើនៅតែជាធនធានមួយសំរាប់អនាគតដ៏យូរអង្វែង ។

ឧទាហរណ៍មួយផ្សេងទៀតនៃព្រៃឈើសហគមន៍ គឺចាប់ពីពេលណាដែលសហគមន៍មួយបានសំរេចចិត្តដាំដើមឈើឡើងវិញនៅក្នុងតំបន់មួយដែលមានព្រៃឈើរេចរិល ហើយយកចិត្តទុកដាក់ថែរក្សាការពារចំពោះកូនឈើតូចៗទាំងនោះ (ដូចជានៅតាមសាលារៀន ឬវត្តអារាមជាដើម) ។ នៅព្រះរាជាណាចក្រកម្ពុជាមានគំរូព្រៃឈើសហគមន៍ល្អៗជាច្រើនស្ថិតនៅក្នុងខេត្តតាកែវ និងកំពង់ឆ្នាំងដោយសហការជាមួយនាយកដ្ឋានរុក្ខា-ប្រមាញ់ ដើម្បីថែរក្សា ការពារ និងគ្រប់គ្រងតំបន់ព្រៃឈើដែលពួកគេរស់នៅ និងធ្វើការងារ ។ ខេត្តស្វាយរៀងក៏មានព្រៃឈើសហគមន៍ដែលកំពុងដាំដុះកូនឈើបន្ថែមលើកន្លែងដែលបាត់បង់បានជាច្រើនហិកតា ដែលដឹកនាំ និងឧបត្ថម្ភដោយអង្គការ "សន្តិសេនា" ដោយមានព្រះសង្ឃជាប្រធាន ។

◇? *សួរ និងពិភាក្សាជាមួយសិស្ស ដើម្បីឱ្យពួកគេអាចជួយខ្លួនគេ មាតាបិតា និងសហគមន៍ ក្នុងការគ្រប់គ្រងធនធានធម្មជាតិក្នុងមូលដ្ឋាន ។*

(ឧទាហរណ៍ : លើកទឹកចិត្ត និងជួយឱ្យសហគមន៍ :

- ជីក និងថែរក្សាស្រះរបស់សហគមន៍ ធ្វើអណ្តូងស្នប់ ឬរៀបចំគំរោងចែកចាយទឹក ។

- ចូលរួមក្នុងគំរោងដាំដើមឈើនៅតាមសាលារៀន វត្តអារាម ឬកន្លែងសាធារណៈផ្សេងទៀត ។
- រកមធ្យោបាយថ្មីៗដើម្បីប្រើប្រាស់ប្រភពថាមពលព្រះអាទិត្យ ខ្យល់ និងទឹក ។
- ចូលរួមក្នុងសកម្មភាពប្រើប្រាស់ជីវរូប (Biomass) ។
- ផលិត និងប្រើប្រាស់ចង្ក្រានដែលមានប្រសិទ្ធភាពដោយប្រើអុសតិច ។
- ចូលរួមក្នុងការដាំ និងថែរក្សាដើមឈើក្នុងតំបន់ព្រៃឈើរេចរិល) ។

**សង្ខេបមេរៀន :**

ធនធានធម្មជាតិ គឺជាភាវៈទាំងឡាយដែលកើតមានឡើងនៅក្នុងធម្មជាតិ ។ ធនធានធម្មជាតិចែកចេញជាពីរផ្នែក គឺធនធានអាចកើតឡើងជាថ្មី និងធនធានមិនអាចកើតឡើងជាថ្មី ។ មនុស្សគឺជាផ្នែកមួយនៅក្នុងបរិស្ថាន ។ ដូចនេះមនុស្សត្រូវចេះប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងប្រកបដោយនិរន្តរភាព ។ ដើម្បីកែច្នៃធនធានធម្មជាតិ ឱ្យទៅជាធនធានសង្គម-វប្បធម៌ មនុស្សត្រូវការបញ្ចេញកំលាំងផ្ទាល់ខ្លួន ប្រើប្រាស់បច្ចេកទេសជំនាញ និងថាមពល ។ ការប្រើប្រាស់ថាមពលដែលមានប្រភពពីធនធានធម្មជាតិ អាចកើតឡើងជាថ្មីផ្តល់ផលប្រយោជន៍ខ្ពស់ ហើយស្ទើរតែគ្មានការបំពុលបរិស្ថាន ។ បច្ចុប្បន្ននេះ គេបានបង្កើតព្រៃឈើសហគមន៍ជាច្រើនដើម្បីថែរក្សាការពារព្រៃឈើ និងធានានិរន្តរភាពព្រៃឈើ ។

# ស្រមោច និង ខ្លាឃ្មុំ

មុខលេខទី
៨

**រឿងនិទាន** **កំរិតទី១ ទី២**

**បញ្ញាប** : សិក្សាសង្គម ភាសាខ្មែរ និងវិទ្យាសាស្ត្រអនុវត្ត ។

**បញ្ញត្តិ** : ព្រៃឈើ និងសត្វព្រៃជាផ្នែកសំខាន់នៃធនធានធម្មជាតិ ។

**វត្ថុបំណង** : សិស្សយល់ថា សត្វព្រៃមិនអាចរស់នៅដោយគ្មានព្រៃឈើបានឡើយ ។

**លទ្ធផល** : សិស្សជួយថែរក្សា និងការពារព្រៃឈើដែលជាជំរក ផ្តល់អាហារ និងឧស្ម័នអុកស៊ីសែន សំរាប់ការរស់នៅរបស់សត្វព្រៃ ។

**សំភារៈឧបទេស** : រូបភាពក្នុងលំហាត់នេះ ។

**សេចក្តីណែនាំ** : ក្នុងសកម្មភាពនេះ អ្នកគ្រូ-លោកគ្រូនិទានរឿងឱ្យសិស្សស្តាប់ ។ បើមានលទ្ធភាពឱ្យសិស្សអាន និងសំដែងតួទៅតាមសាច់រឿង ។ បន្ទាប់មកអ្នកគ្រូ-លោកគ្រូចោទសំនួរដូចខាងក្រោម :

ថ្ងៃមួយនានិទាឃរដូវ [(១)] សត្វទាំងអស់មកជួបជុំគ្នានៅក្បែរមាត់ព្រៃ ។ ពួកគេសំរេចចិត្តថា ម្នាក់ៗ ត្រូវធ្វើការអ្វីមួយចំណែក ដើម្បីឱ្យអ្នកដទៃគោរព និងកោតស្ញប់ស្ញែង ។



១

(១) និទាឃរដូវ : ឈ្មោះរដូវមួយប្រើតាមសុរិយគតិ ជារដូវក្ដៅ រាប់ពីត្រឹមថ្ងៃទី ២១ មិនា ដល់ថ្ងៃ ២១ មិថុនា ។


មានតែខ្លាឃ្មុំមួយទេ ដែលពុំរវល់គិតគូរអ្វីសោះ ។ លុះមកដល់មាត់ប្រឡាយវា
ឃើញកណ្ដុរប្រែងមួយក្រុមកំពុងអារឈើ ។
អីយ៉ា ! ពួកនេះកំពុងធ្វើអ្វី ហ្នឹង ?
បន្ទាប់មក វាបន្តដំណើរទៅមុខទៀត ...
២


វាឃើញចចក និង កញ្ជ្រោង កំពុងធ្វើការ វាក៏ឈប់មើល ....
អីយ៉ា ! ពួកនេះកំពុងធ្វើអ្វីដែរ ហ្នឹង ?
ខ្លាឃ្មុំដើរបន្តិច, ឈប់បន្តិច នៅតែគិតមិនឃើញ។ តើពួកគេកំពុងធ្វើអ្វី ?
៣

រំពេចនោះ ខ្លាឃ្មុំឃើញគ្រាប់ជ្រៃមួយចេះដើរ វាឆ្ងល់ណាស់ ។




ខ្លាឃ្មុំឈរក្រពាត់ដៃមើលស្រមោចដែលកំពុងវាររទៅវារមក ។

រំពេចនោះ វាលោតកញ្ឆេងម្នាក់ឯង ព្រោះដឹងថាវាត្រូវធ្វើអ្វីហើយ ។ ៤

សារទរដូវ[២]ក៏មកដល់។ សត្វទាំងអស់ជួបជុំគ្នា ដើម្បីមើលលទ្ធផលការងាររបស់គេម្នាក់ៗ គេនាំគ្នាដើរត្រសងកាត់ព្រៃទៅដល់ប្រឡាយមួយ .....




បន្ទាប់មកពួកគេបន្តដំណើរទៅមើលលទ្ធផលរបស់សត្វដទៃទៀត ..... ។ ៥

( ២ ) សារទរដូវ ៖ រដូវចុះរ័ក្ខ ឬ រដូវមានខ្យល់ ភ្លៀង និង ទឹកសន្សើមខ្លះ ។

ទីវាលក្នុងព្រៃស្អាតផង បានរៀបចំយ៉ាងមានរបៀបរៀបរយ ។




ក្រោយពីសំរាកលេងលើស្ពានមួយស្របក់ សត្វទាំងអស់នាំគ្នា
បន្តដំណើរទស្សនកិច្ចទៅមុខទៀត ។

៦

ពួកគេបានជួបនឹងស្រមោចតូចល្អិតមួយ ។ ស្រមោចក៏វារនាំមុខសត្វទាំងអស់
សំដៅទៅ មាត់ព្រៃដែលមានកូនជ្រៃ ទើបដុះថ្មី ៗ ជាច្រើន ។




សត្វទាំងអស់កោតសរសើរសេចក្ដីព្យាយាមរបស់ស្រមោចក្រៃលែង ។

៧

(៣) វស្សានរដូវ   រដូវភ្លៀង ។




សំនួរ :

១- ក្នុងរឿងនិទាននេះ តើមានតួអង្គអ្វីខ្លះ ?
២- តើសត្វណាតូចជាងគេក្នុងចំនោមសត្វទាំងអស់ ?
៣- ហេតុអ្វីបានជាសត្វទាំងអស់កោតសរសើរសត្វស្រមោច ?
៤- ខ្លាឃ្មុំធំហើយខ្លាំង ហេតុអ្វីបានជាគេមិនកោតសរសើរ ?
៥- តើអំពើរបស់ខ្លាឃ្មុំ បានចូលរួមថែរក្សាព្រៃឈើដែរឬទេ ?
៦- តើអំពើរបស់ស្រមោច បានជួយអ្វីខ្លះដល់មនុស្ស និងសត្វ ?
៧- បើប្អូនជាតួអង្គខ្លាឃ្មុំ តើប្អូនធ្វើដូចខ្លាឃ្មុំដែរឬទេ ? ហេតុអ្វី ?
៨- តាមរូបភាពនេះ តើមានអ្វីខ្លះជាធនធានធម្មជាតិ ?
៩- តើអ្វីខ្លះជាធនធានធម្មជាតិដែលកើតឡើងជាថ្មី និងធនធានធម្មជាតិដែលមិនអាចកើតឡើងជាថ្មី តាមរយៈរូបភាពនេះ ?

មុខលទ្ធិ
៨

# ធនធានធម្មជាតិក្នុងប្រទេសយើង

សំនួរសរសេរ / តេស្ត — កំរិតសិក្សាទី២ និងទី៣

បញ្ញាបតាមរយៈ : វិទ្យាសាស្ត្រអនុវត្ត សិក្សាសង្គម និងភាសាខ្មែរ ។

បញ្ញត្តិ : ប្រទេសកម្ពុជាសំបូរធនធានធម្មជាតិ ។

វត្ថុបំណង : សិស្សកំណត់បានធនធានធម្មជាតិដែលមាននៅក្នុងសហគមន៍ និងក្នុងប្រទេសកម្ពុជា ។

លទ្ធផល : សិស្សញែកចេញបានច្បាស់រវាងធនធានធម្មជាតិអាចកើតឡើងវិញជាថ្មី និងមិនអាចកើតកើតឡើងវិញជាថ្មី ។

សំភារៈឧបទេស : សន្លឹកតេស្ត ឬសៀវភៅលំហាត់ ។

សេចក្ដីណែនាំ : ក្នុងសកម្មភាពនេះ អ្នកគ្រូ-លោកគ្រូត្រូវរៀបចំសន្លឹកតេស្តជាមុន ដោយសហការជាមួយមជ្ឈមណ្ឌលធនធានកំរងសាលា ។ បើគ្មានលទ្ធភាព ត្រូវចំលងសំនួរនៅលើក្ដារខៀនជាមុន រួចឱ្យសិស្សចំលងចូលសៀវភៅលំហាត់ ។

I. ចូរគូសរង្វង់ជុំវិញ ក. ខ. គ ដែលអ្នកយល់ថាជាចំលើយត្រឹមត្រូវ ។ សូមបញ្ជាក់ថា ចំលើយត្រឹមត្រូវមានតែមួយគត់ ។

១. សាលារៀនយើងមានធនធានធម្មជាតិ :
- ក. អគារ ២ខ្នង ។
- ខ. សួនច្បារ និងសួនបន្លែ ។
- គ. កំដៅ និងពន្លឺព្រះអាទិត្យ ។

២. ព្រះរាជាណាចក្រកម្ពុជាមានធនធានធម្មជាតិ :
- ក. រ៉ែត្បូងនៅប៉ៃលិន ។
- ខ. ផ្លូវជាតិសំខាន់ៗ ។
- គ. ប្រាសាទអង្គរ ។

៣. ធនធានធម្មជាតិដែលអាចកើតឡើងជាថ្មីមាន :
- ក. ខ្យល់ និងពន្លឺព្រះអាទិត្យ ។
- ខ. រ៉ែមាស និងប្រេងកាត ។
- គ. មច្ឆាជាតិ និងសត្វព្រៃ ។

II. បំពេញឃ្លា : ចូរជ្រើសរើសពាក្យមួយ ពុំពីរក្នុងរង្វង់ក្រចក ដើម្បីបំពេញឃ្លាដូចមានខាងក្រោម :

(ធនធានធម្មជាតិ មិនអាចកើត រ៉ែត្បូង ព្រៃឈើ)

១ - យើងប្រើប្រាស់ ______________ ច្រើនអនេក ។

២ - __________ ដែលត្រូវបានកាប់រួចហើយ ត្រូវជំនួសដោយការដាំជាថ្មី ។

៣ - ធនធានធម្មជាតិដែល __________ ឡើងជាថ្មីត្រូវថយចុះជាលំដាប់ ដូចជា __________ នៅប៉ៃលិន ។

៤ - ដូច្នេះយើងត្រូវនាំគ្នាថែរក្សា ____________ របស់យើងឱ្យបានយូរអង្វែង ។

**III.** ចូរគូសខ្សែភ្ជាប់រវាងល្បះក្នុងក្រុម (ក) និងក្រុម (ខ) ឱ្យមានន័យស៊ីគ្នា ឬទាក់ទងគ្នា :

| ក្រុម (ក) | ក្រុម (ខ) |
|---|---|
| ធនធានធម្មជាតិ • | • ការពារទល់នឹងទឹកជំនន់ ការពារសំនឹកដី ទាក់ទាញទឹកភ្លៀង បន្ថយកំដៅលើផែនដី ផ្ដល់អុកស៊ីសែន និងស្រូបយកឧស្ម័នកាបូនិចទៅវិញ ។ |
| សារៈសំខាន់នៃព្រៃឈើ • | • កំដៅឡើងខ្លាំង សំបូរឧស្ម័នកាបូនិច ដីខ្សោះជីជាតិ កង្វះទឹកភ្លៀង ។ |
| សត្វព្រៃបានជួយ • | • អ្វីៗទាំងឡាយមាននៅក្នុងធម្មជាតិ ទាំងមានជីវិត និងគ្មានជីវិត ។ |
| រ៉ែមានដូចជា • | • ពង្រាយគ្រាប់រុក្ខជាតិ ធ្វើឱ្យដីមានជីជាតិ ទាក់ទាញភ្ញៀវទេសចរ ។ |
| ធនធានធម្មជាតិមាន • | • ព្រៃឈើ សត្វព្រៃ រ៉ែ ភ្នំ សមុទ្រ ទឹក ដី ខ្យល់ ពន្លឺ និងកំដៅព្រះអាទិត្យ ។ |
| កាលណាគ្មានព្រៃឈើនៅលើ ផែនដី • | • ប្រេងកាត ត្បូង ថ្មងថ្ម រ៉ែមាស ថ្មកំបោរ ថ្មស្លាត ... ។ |

ម៉ូឌុលទី
៨

# ធនធានធម្មជាតិនៅប្រទេសកម្ពុជា

**សកម្មភាពក្នុងថ្នាក់** **ការិតទី២ និងទី៣**

បញ្ញាបតាមរយៈ : វិទ្យាសាស្ត្រអនុវត្ត សិក្សាសង្គម និងភាសាខ្មែរ ។

បញ្ញត្តិ : ធនធានធម្មជាតិកើតឡើងដោយឯកឯង ហើយវិវឌ្ឍនៅក្នុងលក្ខខ័ណ្ឌធម្មជាតិ ដូចជា រុក្ខជាតិ សត្វព្រៃ បឹង សមុទ្រ រ៉ែ ខ្យល់ ពន្លឺព្រះអាទិត្យ ។ល។

វត្ថុបំណង : សិស្សបង្កើតការយល់ដឹងពីធនធានធម្មជាតិដ៏សំបូរបែប ដែលជាប្រភពអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច និងវប្បធម៌ខ្មែរ ។

លទ្ធផល : សិស្សមានឥរិយាបថគាំទ្រការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយ និរន្តរភាព ។

សំភារៈឧបទេស : ផែនទីសេដ្ឋកិច្ចប្រទេសកម្ពុជា (មើលផែនទីក្នុងម៉ូឌុលទី៨) ។

សេចក្ដីណែនាំ : ក្នុងសកម្មភាពនេះ អ្នកគ្រូ-លោកគ្រូត្រូវចោទសំនួរឱ្យសិស្សពិភាក្សាដូចខាងក្រោម :

១- តាមរយៈផែនទីនេះ ឱ្យសិស្សរាប់ឈ្មោះធនធានធម្មជាតិឱ្យបាន ៥យ៉ាងតិច ។

២- ឱ្យសិស្សធ្វើការបែងចែកធនធានធម្មជាតិជាពីរក្រុម :

ក) ធនធានធម្មជាតិដែលអាចកើតឡើងជាថ្មី ។

ខ) ធនធានធម្មជាតិដែលមិនអាចកើតឡើងជាថ្មី ។

៣- តើធនធានធម្មជាតិមានសារៈសំខាន់អ្វីខ្លះសំរាប់ធម្មជាតិ និងសំរាប់សង្គមមនុស្ស ?

៤- រវាងធនធានធម្មជាតិទាំងពីរក្រុមខាងលើ តើគេបានលើកទឹកចិត្តមនុស្សឱ្យប្រើប្រាស់ក្រុមណាជាងក្រុមណា ? ព្រោះអ្វី ?

៥- តើប្អូនត្រូវប្រើប្រាស់ធនធានធម្មជាតិរបៀបណាដើម្បីឱ្យវាស្ថិតនៅគង់វង្សយូរអង្វែង ?

ម៉ូឌុលទី
៨

# ការដាំកូនឈើនៅក្នុងបរិវេណសាលារៀន

**សកម្មភាពក្រៅសាលា** **ថ្នាក់ទី១ ទី២ ទី៣**

**បញ្ញាបតាមរយៈ** : វិទ្យាសាស្ត្រអនុវត្ត សិក្សាសង្គម គណិតវិទ្យា និងភាសាខ្មែរ ។

**បញ្ញត្តិ** : ការដាំដើមឈើនៅក្នុងបរិវេណសាលារៀនជាគំរូដល់សហគមន៍ ។

**វត្ថុបំណង** : សិស្សចូលរួមដាំ ថែរក្សា និងការពារដើមឈើក្នុងបរិវេណសាលារៀន ដើម្បីបង្កើតសោភណភាព និងម្លប់ ។

**លទ្ធផល** : សិស្សមានបទពិសោធ និងមានស្មារតីទទួលខុសត្រូវចំពោះការដាំ ថែរក្សា និងការពារដើមឈើ ។

**សំភារៈឧបទេស** : កូនឈើ ចបកាប់ ចបជីក ជីកំប៉ុស្ត ឬជីលាមកសត្វ សំភារៈសំរាប់ធ្វើរបង ។

**សេចក្តីណែនាំ** : ក្នុងសកម្មភាពនេះ អ្នកគ្រូ-លោកគ្រូ ត្រូវរៀបចំ និងជ្រើសរើសពេលវេលាឱ្យបានសមស្រប ។ បន្ទាប់មកណែនាំសិស្សតាមចំណុចដូចខាងក្រោម :

១- គ្រូត្រូវជ្រើសរើសជាមុននូវកន្លែងដាំកូនឈើនៅក្នុងបរិវេណសាលារៀន ។

២- ឱ្យសិស្សជីករណ្តៅទៅតាមចំនួនដែលយើងចង់បាន ដោយមានទំហំសមស្របតាមប្រភេទ និងពូជកូនឈើ ។

៣- ឱ្យសិស្សលាយជីកំប៉ុស្ត ឬជីលាមកសត្វចំនួន៥គ.ក្រ ច្របល់ចូលជាមួយដីសំរាប់មួយរណ្តៅ ។ បន្ទាប់មកឱ្យបំពេញរណ្តៅទាំងនោះ ។

៤- ឱ្យសិស្សដាំកូនឈើនៅក្នុងរណ្តៅទាំងនោះដោយយកចិត្តទុកដាក់ ។

៥- ឱ្យសិស្សធ្វើរបងព័ទ្ធជុំវិញរណ្តៅ ។

៦- ចាត់តាំងសិស្សឱ្យផ្លាស់ប្តូរវេនគ្នា ដើម្បីថែរក្សា ដាក់ជី ការពារ និងស្រោចទឹកជាប់ជាប្រចាំ រហូតដល់ដើមឈើទាំងនោះធំ ។

ម៉ូឌុលទី
៨

# ធនធានស្រុកខ្មែរ

**សកម្មភាពក្នុង និងក្រៅថ្នាក់** **កំរិតទី២ និងទី៣**

**បញ្ជ្រាបតាមរយៈ** : វិទ្យាសាស្ត្រអនុវត្ត សិក្សាសង្គម និងភាសាខ្មែរ ។

**បញ្ញត្តិ** : ធនធានធម្មជាតិនឹងខ្សោះរលាយអស់ បើមនុស្សប្រើប្រាស់ដោយគ្មានស្មារតីទទួលខុសត្រូវ និងគ្មានគិតដល់និរន្តរភាព ។

**វត្ថុបំណង** : សិស្សយល់ថា ធនធានធម្មជាតិបច្ចុប្បន្ននៅប្រទេសកម្ពុជាកំពុងរងគ្រោះដោយសារសកម្មភាពទាញយកផលដោយគ្មានគិតដល់និរន្តរភាព ។

**លទ្ធផល** : សិស្សស្រឡាញ់ និងមានមោទនភាពចំពោះធនធានធម្មជាតិរបស់ខ្មែរ ។

**សំភារៈឧបទេស** : ផែនទីសេដ្ឋកិច្ចប្រទេសកម្ពុជា ។

**សេចក្តីណែនាំ** :

♦ សំរាប់សកម្មភាពក្នុងថ្នាក់ អ្នកគ្រូ-លោកគ្រូត្រូវចំលងអត្ថបទកំណាព្យលើក្តារខៀនជាមុនសិន ។ បើមានផាំងនេ បិទផាំងនេសិន ។ នៅពេលបង្រៀនសឹមបើកផាំងនេ ។ ការបង្រៀនត្រូវបែងចែកជា២វគ្គ ដូចការបង្រៀនមេសូត្រត់មាត់ដែរ គឺ :

- វគ្គទី១ :
  - ពន្យល់ន័យពាក្យពិបាក
  - លើកសំនួរដើម្បីយល់អត្ថន័យ
- វគ្គទី២ :
  - គ្រូអានអត្ថបទដោយសូត្រតាម "*បទពាក្យ៨*" ឱ្យសិស្សស្តាប់១ដង ឬ២ដង ។
  - ឱ្យសិស្សអានតៗគ្នាក្នុងម្នាក់២ឃ្លះឱ្យបានយ៉ាងតិច៣ចប់ ។
  - គ្រូចាប់ផ្តើមលុបពាក្យចុងចួននៅចុងឃ្លាបន្ទាប់ ។ រួចមកលុបពាក្យដទៃទៀតរហូតទាល់តែអស់អត្ថបទទាំងមូល ។
  - ឱ្យសិស្សសូត្រអត្ថបទឡើងវិញតាមការចងចាំ ។ ទីបញ្ចប់អ្នកគ្រូ-លោកគ្រូចោទសំនួរដូចមានខាងក្រោម ។

♦ សំរាប់សកម្មភាពក្រៅថ្នាក់ (លំហាត់នៅផ្ទះ) ឱ្យសិស្សចំលងអត្ថបទកំណាព្យនេះដាក់ក្នុងសៀវភៅលំហាត់ ហើយឱ្យសិស្សធ្វើលំហាត់នៅផ្ទះ ដោយសូត្រកំណាព្យ និងពិភាក្សាអំពីអត្ថន័យនៃកំណាព្យជាមួយបងប្អូន ឪពុកម្តាយ ឬញាតិមិត្តជិតខាង ។ ពេលមកដល់ថ្នាក់រៀនវិញ ឱ្យសិស្សរាយការណ៍ជូនមិត្តរួមថ្នាក់អំពីលទ្ធផលដែលគេទទួលបានពីមិត្តភក្តិ បងប្អូន ឪពុកម្តាយរបស់គេ ។

## អត្ថបទកំណាព្យ

# ធនធានស្រុកខ្មែរ

(បទពាក្យ៨)

១- *ធនធានស្រុកខ្មែរមានច្រើនកន្លង　　គ្មានសៅហ្មងអ្នកផងប៉ងប្រាថ្នា*
*មិនគិតហិនហោចអស់ដីព្រឹក្សា　　ជាតិខេមរាប្រុសស្រីភ័យបារម្ភ ។*

២- *រឹងព្រៃឈើក៏បាត់បង់អស់　　គ្មានស្រណោះស្ទើរចុតអស់រលំ*
*ចំពោះសត្វព្រៃវិនាសដំណំ　　គ្មានអ្នកខំថែសម្បត្តិព្រឹក្សា ។*

៣- *យកប៉ៃប៉ៃលិនគឺជាកំហុស　　ខ្មែរមើលចុះតើកំហុសអ្នកណា*
*គឺគេមិនគិតផលគ្រប់រូបបា　　មិនអនិច្ចាគិតតែប្រយោជន៍ខ្លួន ។*

៤- *ប្រាសាទអង្គរយំថ្ងូររាល់ថ្ងៃ　　ខ្មែរប្រុសស្រីត្រូវចាប់ភ្ញាក់ខ្លួនឡើង*
*រក្សាធនធានសម្បត្តិជាតិយើង　　ក្រោកឈរឡើងរក្សាឱ្យគង់វង្ស ។*

៥- *បញ្ហាបរិស្ថានបានធ្លាក់ធ្ងន់ធ្ងរ　　ខ្មែរអង្វរសុំគិតដល់ពូជពង្ស*
*ពីនេះទៅមុខសុំឱ្យបានគង់　　វិះរេចង់ស្គាល់ពីក្ដីសុខសាន្ត ។*

**ក. សំនួរត្រិះរិះ**

១- តើអ្នកអាចរៀបរាប់ធនធានធម្មជាតិមាននៅប្រទេសកម្ពុជាមានអ្វីខ្លះ ?
២- តើប៉ៃលិនស្ថិតនៅក្នុងស្រុកណា ? ខេត្តអ្វី ?
៣- ហេតុអ្វីបានជាប៉ៃលិនល្បីឈ្មោះជាងគេនៅប្រទេសកម្ពុជា ?
៤- តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចចំពោះអត្ថន័យកំណាព្យនេះ ?
៥- តើអ្នកនិពន្ធចង់បង្ហាញអ្វីខ្លះដល់អ្នក ចំពោះកំណាព្យនេះ ?

**ខ. លំហាត់**

១- ចូរពន្យល់ន័យរបស់ពាក្យគូសបន្ទាត់ពីក្រោមនៅក្នុងអត្ថបទកំណាព្យខាងលើនេះ ។
២- ចូរពិភាក្សាគំនិតរបស់អ្នកនិពន្ធជាមួយក្រុមរបស់អ្នក ចំពោះល្បះក្នុងប្រអប់ខាងក្រោមនេះ

| គឺគេមិនគិតពីប្រយោជន៍ខ្មែរ　　គេចង់បានតែប្រយោជន៍ខ្លួនឯង |
| --- |

*កំណត់សំគាល់ : អត្ថបទកំណាព្យនេះនិពន្ធដោយលោក សាមឿន ម៉ោះ តំណាងគ្រូមកពីកំរងសាលាជ័យសែន ខេត្តព្រះវិហារ និងកែសម្រួលដោយសមាជិកក្រុម២ នាឱកាសសិក្ខាសាលាស្ដីពីការអប់រំបរិស្ថានក្រីតបឋមសិក្សា តាមរយៈកំរងសាលាភូមិភាគសៀមរាប : ១៧ដល់ ២០ មិថុនា ១៩៩៧ ។*

មុខវិជ្ជាទី
៨

# អនិច្ចាជាតិខ្មែរ

**សកម្មភាពក្នុង និងក្រៅថ្នាក់** **កំរិតទី២ និងទី៣**

**បញ្ញាបំពាក់រយៈ** : ភាសាខ្មែរ វិទ្យាសាស្ត្រអនុវត្ត និងសិក្សាសង្គម ។

**បញ្ញត្តិ** : ធនធានធម្មជាតិមានសំបូរបែបនៅប្រទេសកម្ពុជា ដែលពលរដ្ឋខ្មែរគ្រប់រូបត្រូវនាំគ្នាថែរក្សា ។

**វត្ថុបំណង** : សិស្សយល់ថា មនុស្សមិនអាចផ្តាច់ខ្លួនចេញពីបរិស្ថានណាមួយឡើយ ។

**លទ្ធផល** : សិស្សសន្និដ្ឋានថា បើវប្បធម៌សាបសូន្យ ជាតិនឹងរលាយ ។ មនុស្សម្នាក់ៗមានមនសិការជានិច្ចថែរក្សា ការពារបរិស្ថាន ។

**សំភារៈឧបទេស** : រូបភាពប្រាសាទអង្គរ ឬប្រាសាទ ឬវត្តអារាមណាមួយ ។

**សេចក្តីណែនាំ** :

- សំរាប់សកម្មភាពក្នុងថ្នាក់ អ្នកគ្រូ-លោកគ្រូត្រូវណែនាំបង្រៀនសិស្សឱ្យចេះច្រៀងតាម "*លំនាំបទស្រណោះរៃយំ*" ជាមុនសិន ។ បន្ទាប់មក ឱ្យសិស្សច្រៀងម្នាក់ម្តងៗ រួចជាក្រុមៗ ។ ទីបញ្ចប់ អ្នកគ្រូ-លោកគ្រូចោទសំនួរដូចខាងក្រោម ។
- សំរាប់សកម្មភាពក្រៅថ្នាក់ (លំហាត់នៅផ្ទះ) ឱ្យសិស្សចំលងអត្ថបទចំរៀងនេះដាក់ក្នុងសៀវភៅលំហាត់ ហើយឱ្យសិស្សធ្វើលំហាត់នៅផ្ទះ ដោយច្រៀងចំរៀង និងពិភាក្សាអំពីអត្ថន័យនៃចំរៀងជាមួយបងប្អូន ឪពុកម្តាយ ឬញាតិមិត្តជិតខាង ។ ពេលមកដល់ថ្នាក់រៀនវិញ ឱ្យសិស្សរាយការណ៍ជូនមិត្តរួមថ្នាក់អំពីលទ្ធផលដែលគេទទួលបានពីមិត្តភក្តិ បងប្អូន ឪពុកម្តាយរបស់គេ ។

## អត្ថបទចំរៀង

### អនិច្ចាជាតិខ្មែរ

(លំនាំបទ ស្រណោះរៃយំ)

*I. អនិច្ចាជាតិខ្ញុំ ធម្មជាតិស្តុកស្តម្ភអើយ ព្រៃភ្នំជុំជិត (២ដង)*
*ទោះមានផ្លែតូចៗមែនពិតអើយ សម្បត្តិពិសិដ្ឋលើដីក្រោមដី ។*

*II. ក្នុងព្រៃមានសត្វ តូចធំផ្សេងឆ្ងាត់អើយ ក្នុងទឹកមានត្រី (២ដ)*
*បឹងទន្លេសាបៗធំក្រៃ ជំរកប្រពៃនៃមច្ឆាជាតិ ។*

*III. ក្នុងដីមានរ៉ែ មាសពេជ្រត្បូងទ្វេអើយ ឲ្យេងថ្ងប្រេងកាត (២ដង)*
*ប្រាសាទអង្គរៗល្អស្អាត មានប្រាង្គប្រាសាទ វប្បធម៌រុងរឿង ។*

IV. *ក្រោយមានសង្គ្រាម ត្រូវបានកំភមអើយ ក្មានត្រាប្រណី (២ដង)*
*ជនឆ្លៀតឱកាសៗអប្រិយ មិនគិតវែងខ្លី កាស់កាប់បំផ្លាញ ។*

V. *ពេលនេះកូនខ្មែរ ខំពួនខំថែអើយ ទាំព្រលឹងជាតិ (២ដង)*
*មិនឱ្យលិចលង់ៗឃ្លៀងឃ្លាត កសាងថែមទៀត កុំឱ្យសូន្យបង់ ។*

**សំនួរត្រិះរិះ**

១- ក្រៅពីព្រៃឈើ តើប្រទេសកម្ពុជាមានអ្វីទៀតដែលជាធនធានធម្មជាតិ ?

២- ចូរចែកថ្នាក់ធនធានធម្មជាតិនៅកម្ពុជាទៅតាមប្រភេទក្នុងដី លើដី ក្នុងទឹក ក្នុងព្រៃ និងក្នុងអាកាស ។

៣- មានមូលហេតុអ្វីខ្លះដែលបណ្ដាលឱ្យធនធានធម្មជាតិនៅប្រទេសកម្ពុជាត្រូវទទួលរងការបំផ្លិចបំផ្លាញជាខ្លាំង ?

៤- តើអ្នកនិពន្ធចង់បង្ហាញគំនិតអ្វីខ្លះ បើតាមអត្ថន័យនៃចំរៀងនេះ ?

៥- តើអ្នកមានចំណាប់អារម្មណ៍យ៉ាងណាដែរ ចំពោះអត្ថបទនៃពាក្យអនិច្ចាជាតិខ្មែរ ?

*កំណត់សំគាល់* : និពន្ធដោយ សុត សុនចារ៉ូ ប្រធានកំរងសាលាឡាបានសៀក ខេត្តរតនគិរី នាឱកាសសិក្ខាសាលាស្ដីពីការអប់រំបរិស្ថានកំរិតបឋមសិក្សា តាមរយៈកំរងសាលាភូមិភាគក្រុងព្រះសីហនុ : ២៤ ដល់២៧ មិថុនា ១៩៩៧ ។

**ម៉ូឌុលទី**
**៩**

# ការបំពុលបរិស្ថាន

**វត្ថុបំណង** : សិស្សយល់ដឹងពីការបំពុលបរិស្ថាន ឥទ្ធិពលនៃការបំពុលបរិស្ថាន និងរកវិធីផ្សេងៗ ដើម្បីធ្វើឱ្យបរិស្ថានកាន់តែល្អប្រសើរឡើងសំរាប់គ្រួសារ និងសហគមន៍ ។

**លទ្ធផល** : សិស្សទទួលបានចំណេះដឹង អំពីមូលហេតុ និងសកម្មភាពជាក់ស្តែងដែលបំពុលទឹក ដី ខ្យល់ និងដោយសូរសំលេង ។

**សំភារៈ** : ខ្ទឹមសារមេរៀន និងសំភារៈឧបទេសត្រូវសំរបសំរួលតាមកំរិតរបស់សិស្ស ។

## ក. ការបំពុលបរិស្ថានជាអ្វី

ការបំពុលបរិស្ថាន គឺជាការធ្វើឱ្យកខ្វក់ដល់បរិស្ថាន ។ ជាទូទៅប្រភពការនេះបង្កឡើងដោយសំណល់ផ្សេងៗតាមរយៈសកម្មភាពរបស់មនុស្ស ។ ការបំពុលធ្វើឱ្យទឹក ដី និងខ្យល់មានភាពមិនស្អាត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់សុខភាពរបស់មនុស្ស សត្វ និងជាសុកភាពបរិស្ថាន (មនុស្ស ធម្មជាតិ និងសង្គមវប្បធម៌) ។ ការបំពុលមានបួនយ៉ាងគឺ ការបំពុលទឹក ដី ខ្យល់ និងការបំពុលដោយសូរសំលេង ។

១- **ការបំពុលទឹក** : បណ្តាលមកពី មនុស្សបោះចោលសំណល់ផ្សេងៗទៅក្នុងប្រភពទឹក ដូចជា ស្រះ ស្ទឹង ទន្លេ បឹង និងសមុទ្រ ។ រោងចក្រ សហគ្រាសបញ្ចេញសំណល់រឹងរាវទៅក្នុងទឹក ។ គ្រួសារខ្លះចោល សំរាម ឬសារធាតុពុលទៅក្នុងស្រះ ស្ទឹង ទន្លេ បឹងបួរ ។ សត្វពាហនៈមួយចំនួនបានធ្វើឱ្យកខ្វក់ ប្រភពទឹក ប្រើប្រាស់ ។ ការប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិតក្នុងកសិកម្មក៏បណ្តាលឱ្យទឹកមានភាពកខ្វក់ ឬពុលទឹកដែរ ។

២- **ការបំពុលដី** : ជាទូទៅបង្កឡើងដោយសកម្មភាពរបស់មនុស្ស ដូចជា ការចាក់ចោល ឬជីកកប់សំណល់រឹងរាវដោយខ្វះការប្រុងប្រយ័ត្ន ការប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិតក្នុងការបង្កើនផលិតផលកសិកម្ម ។ សារធាតុទាំងនេះអាចជ្រាបចូលទៅក្នុងដី និងបង្កឱ្យដីមានភាពកខ្វក់ ឬពុល ។ម្យ៉ាងទៀត ឧស្ម័នពុលមួយចំនួនដែលបញ្ចេញពីរោងចក្រ សហគ្រាសទៅក្នុងបរិយាកាស បង្កជាទឹកភ្លៀងអាស៊ីត ហើយទឹកភ្លៀងនេះធ្លាក់មកលើផែនដី ដែលអាចធ្វើឱ្យដីមានភាពកខ្វក់ដែរ ។

៣- **ការបំពុលខ្យល់** : បណ្តាលមកពីសកម្មភាពរបស់មនុស្ស និងជួលកាលបណ្តាលមកពីសកម្មភាព ភ្នំភ្លើង ដែលបញ្ចេញផ្សែងពុលគ្រប់ប្រភេទទៅក្នុងខ្យល់ ។ រោងចក្រ សហគ្រាស និង យានយន្តដូចជា រថយន្តដឹកទំនិញ រថយន្តក្រុង ម៉ូតូ និងម៉ាស៊ីនភ្លើងដែលប្រើដោយចំហេះប្រេងឥន្ធនៈបានបញ្ចេញឧស្ម័នកាបូនិច ឧស្ម័នស៊ុលផួ និងឧស្ម័នពុលផ្សេងៗទៀតទៅក្នុងខ្យល់ដែលយើងដកដង្ហើម ។ ធ្យូង ឬអុសដែលបានប្រើប្រាស់ សំរាប់ចំអិនអាហារ

ក៏ជាប្រភពបំពុលបរិយាកាសដែរ ។ ធូលី និងផ្សែងដែលបង្កឡើងដោយយានយន្តគ្រប់ ប្រភេទតាមដងផ្លូវនានាក្នុងទីប្រជុំជន និងទីក្រុងក៏អាចបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់សុខភាព មនុស្សសត្វផងដែរ ។

៤- **ការបំពុលដោយសូរសំលេង** : បណ្ដាលមកពីសំលេងខ្លាំងៗដែលមិនមែនជាសូរសំលេងធម្មជាតិ ។ ប្រការនេះមានប្រភពចេញមកពីយានយន្តគ្រប់ប្រភេទ (ជាពិសេសរថយន្តធំៗ) ម៉ូតូ ម៉ាស៊ីនភ្លើង រោងចក្រ សហគ្រាសប្រព័ន្ធចាក់ផ្សាយសាធារណៈ និងឧបករណ៍តន្ត្រីដែលប្រព្រឹត្តទៅ នៅពេលមានពិធីផ្សេងៗក្នុងភូមិស្រុក ឬទីប្រជុំជន ។

◇ *ឱ្យសិស្សជួយផ្ដល់ឧទាហរណ៍ចំពោះការបំពុលទឹក ដី ខ្យល់ និងបំពុលដោយសូរសំលេងនៅក្នុងភូមិ ស្រុក ទីប្រជុំជន និងទីក្រុង ។*

## សកម្មភាពរបស់មនុស្ស និង ការបំពុលបរិស្ថាន



## ខ. ឥទ្ធិពលនៃការបំពុលបរិស្ថាន

ទឹកកខ្វក់ ឬទឹកពុលជាមូលហេតុនៃជំងឺផ្សេងៗដូចជា ជំងឺសើស្បែក កមរមាស់ រាគមួល និងអាសន្នរោគ ចំពោះមនុស្ស សត្វ និងអាចបំផ្លាញដល់ការលូតលាស់របស់រុក្ខជាតិ និងបន្លែដែលពុំធានាសុវត្ថិភាពដល់ការបរិភោគ ។

ដីកខ្វក់ ឬដីពុលអាចបង្កឱ្យប៉ះពាល់ដល់ការលូតលាស់ដំណាំផ្សេងៗ និងជីវៈចំរុះទាំងឡាយដែលរស់នៅក្នុងដី ។ ម្យ៉ាងទៀតសារធាតុពុលខ្លះអាចជ្រាបចូលទៅក្នុងផលដំណាំដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស ដើម្បីសត្វ ដែលទទួលទានផលដំណាំទាំងនោះ ។

ខ្យល់កខ្វក់ ឬខ្យល់ពុលជាមូលហេតុនៃការឈឺក្បាល អស់កំលាំងបណ្តាលឱ្យខូចសួត និងនាំមកនូវជំងឺផ្សេងៗចំពោះមនុស្ស និងសត្វ ។ ខ្យល់ពុលនេះក៏អាចបំផ្លាញ និងធ្វើឱ្យខូចដល់បរិស្ថានសង្គម វប្បធម៌ និងបរិស្ថានធម្មជាតិជាពិសេសព្រៃឈើ និងបន្លែបង្កាដែរ តាមរយៈនៃខ្យល់អាស៊ីត ។

ឥទ្ធិពលនៃការបំពុលដោយសូរសំលេងជាមូលហេតុបណ្តាលឱ្យខូច ឬចុះខ្សោយសោតវិញ្ញាណរបស់មនុស្ស និងសត្វ ។ ការបំពុលនេះ កាត់បន្ថយសមត្ថភាពរបស់មនុស្សដែលកំពុងប្រមូលផ្តុំអារម្មណ៍ រំខានដល់ការសិក្សា ការបំពេញកិច្ចការ និងទទួលទានដំណេក ។ នេះជាការរំខានដែលបង្កឱ្យមួម៉ៅក្តៅក្រហាយ តប់ប្រមល់ ធុញទ្រាន់ទ្រុឌទ្រោមកំលាំង និងថយចុះប្រសិទ្ធភាពការងារ ។

## គ. វិធីទប់ស្កាត់ និងកាត់បន្ថយការបំពុល

បច្ចុប្បន្ននេះ ការបំពុលបានក្លាយទៅជាបញ្ហាដ៏ធ្ងន់ធ្ងរដែលកំពុងគំរាមកំហែងដល់អាយុជីវិតមនុស្ស សត្វនៅលើផែនដី ។ តើយើងត្រូវប្រឈមមុខនឹងបញ្ហានេះយ៉ាងដូចម្តេច ?

យ៉ាងហោចណាស់ក៏មានចំលើយយ៉ាងច្បាស់លាស់មួយដែរ : ប្រសិនបើមានសកម្មភាពរបស់មនុស្សបង្កឱ្យមានការបំពុលដែលធ្វើឱ្យខូច ឬបំផ្លាញដល់សុខភាពខ្លួនឯង និងបរិស្ថាន ។ ដូច្នេះមនុស្សទាំងនោះ ត្រូវកាត់បន្ថយ ឬបញ្ឈប់សកម្មភាពទាំងនោះ ។ នេះមិនគ្រាន់តែជាការស្វែងរកការកែលំអសុខភាពខ្លួនឯងនិងបរិស្ថានជុំវិញប៉ុណ្ណោះទេ ។ ប៉ុន្តែទង្វើនេះនឹងផ្តល់នូវបរិស្ថានមួយដែលមានសុវត្ថិភាព និងសុខភាពសំរាប់កូនចៅយើងជំនាន់ក្រោយថែមទៀតផង ។

? *សួរ និងពិភាក្សាជាមួយសិស្ស រិះរកវិធានការផ្សេងៗនៅក្នុងគ្រួសារ និងសហគមន៍ដើម្បីទប់ស្កាត់ ឬកាត់បន្ថយការបំពុលទឹក ដី ខ្យល់ និងបំពុលដោយសូរសំលេង ។*

(ឧទាហរណ៍ : **ការបំពុលទឹក**

- មិនត្រូវចាក់សំរាម ឬសំណល់រឹង រាវទៅក្នុងប្រភពទឹក តាមដងវិថី ឬទីកន្លែងសាធារណៈ ។
- មិនអនុញ្ញាតិឱ្យប្រើប្រាស់ បឹង ស្រះ ឬទន្លេជាទីកន្លែងសំរាប់ចាក់កាកសំណល់ឡើយ ។
- រកកន្លែងណាដែលសមរម្យសំរាប់ចោលសំណល់ (ប្រើប្រាស់កន្លែងចាក់សំរាម ដែលបាន

កំណត់) ខ្ចប់សំរាមនៅក្នុងស្បោងកៅស៊ូហើយយកទៅចោលនៅតាមកន្លែងចោលសំរាម ចំពោះសំបកកំប៉ុងប៉ីយ៉េ ទឹកក្រូច ប្លាស្ទិច ដែក និងកែវ ត្រូវរក្សាទុកដើម្បីយកទៅប្រើប្រាស់ឡើងវិញ ។

**ឧទាហរណ៍ : ការបំពុលដី :**

- ចាក់ចោល ឬដឹកកប់សំណល់រឹង រាវ ត្រូវប្រុងប្រយ័ត្នជានិច្ច ។
- ប្រើប្រាស់ជីគីមី ឬថ្នាំសំលាប់សត្វល្អិតត្រូវសមស្របតាមលក្ខណៈបច្ចេកទេស ។
- កាត់បន្ថយការប្រើប្រាស់ប្រភពថាមពលនានា ដែលបញ្ចេញសារធាតុពុលច្រើនទៅក្នុងបរិយាកាស ។
- លើកទឹកចិត្តដោយទិញបន្លែ ផ្លែឈើណាដែលប្រើប្រាស់ជីធម្មជាតិ (មិនប្រើជីគីមី ឬថ្នាំសំលាប់សត្វល្អិត) ។

**ឧទាហរណ៍ : ការបំពុលខ្យល់**

- កាត់បន្ថយការប្រើប្រាស់អុស ធ្យូងសំរាប់ចំអិនអាហារ ដោយជំនួសការប្រើប្រាស់ចង្ក្រានដែលមានប្រសិទ្ធភាព និងប្រើប្រាស់ពីវឧស្ម័ននៅពេលណាដែលអាចធ្វើទៅបាន ។
- ដាំដើមឈើបន្ថែមជុំវិញផ្ទះ និងសាលារៀនព្រោះថា ដើមឈើអាចស្រូបយកឧស្ម័នពុល ផ្តល់សោភណភាព និងម្លប់ ។
- នៅទីប្រជុំជន និងទីក្រុងនានាគេអាចកាត់បន្ថយការបំពុលខ្យល់ ដោយប្រើប្រាស់កង់ ស៊ីក្លូ រ៉ឺម៉ក ឬមធ្យោបាយដឹកជញ្ជូនសាធារណៈ ។
- នៅរដូវប្រាំង គួរស្រោចទឹកនៅតាមផ្លូវ ដើម្បីកាត់បន្ថយធូលី និងលំអងផ្សែងនៅក្នុងខ្យល់ ។
- សុំឱ្យពន្យល់អ្នកជិតខាង និងម្ចាស់រោងចក្រឱ្យយល់ពីការបំពុលបរិស្ថានដែលគេជាចំណែកមួយដែរ ។

**ឧទាហរណ៍ : ការបំពុលដោយសូរសំលេង**

- ប្រើប្រាស់កំលាំងមនុស្សសមស្របដូចជា កង់ រ៉ឺម៉ក ស៊ីក្លូ និងមធ្យោបាយដឹកជញ្ជូនសាធារណៈ ដើម្បីកាត់បន្ថយការបំពុលសំលេង ។
- គួរដាក់ម៉ាស៊ីនភ្លើងឱ្យឆ្ងាយពីកន្លែងមនុស្ស និងសត្វរស់នៅ បើអាចធ្វើទៅបាន ។
- បន្ថយសំលេងចំពោះទូរទស្សន៍ វីដេអូ និងម៉ាញ៉េរបស់អ្នក ។
- ជៀសវាងការស្រែកឡូឡានៅផ្ទះ សាលារៀន ឬទីសាធារណៈ ។)

**សង្ខេបមេរៀន :**

ការបំពុលបរិស្ថាន គឺជាការធ្វើឱ្យកខ្វក់ ឬធ្វើឱ្យបរិស្ថានពុលដោយសារសំណល់រឹង រាវ ឬឧស្ម័ន តាមរយៈសកម្មភាពរបស់មនុស្ស ។ ការបំពុលមាន៤យ៉ាងគឺ : ការបំពុលទឹក ដី ខ្យល់ និងការបំពុលដោយសូរសំលេង ។ ការបំពុលបរិស្ថានអាចបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ រុក្ខជាតិ និងដល់បរិស្ថានសង្គម-វប្បធម៌ ។ បច្ចុប្បន្ននេះ ការបំពុលបរិស្ថានកាន់តែមានភាពធ្ងន់ធ្ងរឡើង ហើយបានបង្កគ្រោះថ្នាក់ជាច្រើនដល់មនុស្សជាតិ ។ អាស្រ័យហេតុនេះ មនុស្សគួរតែកាត់បន្ថយ ឬបញ្ឈប់សកម្មភាពទាំងឡាយណាដែលបង្កការបំពុលដល់បរិស្ថាន ។

✍ មុំខុសទី
៩

# ប្រយ័ត្ន ! បន្លែ ផ្លែឈើពុល

**រឿងនិទាន** **ថ្នាក់ទី២ និងទី៣**

**បញ្ញាបញ្ចូលរយៈ** : វិទ្យាសាស្ត្រអនុវត្ត សិក្សាសង្គម និងភាសាខ្មែរ ។

**បញ្ញត្តិ** : ផលវិបាកតិច ឬច្រើនបណ្តាលមកពីការប្រើប្រាស់ថ្នាំបំពុលសត្វល្អិតដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព ។

**វត្ថុបំណង** : តាមរយៈការស្តាប់រឿងនិទាន និងសំដែងតួ សិស្សអាចបង្ហាញពីវិធីកាត់បន្ថយការប្រើប្រាស់ថ្នាំពុល ដូចជាថ្នាំសំលាប់សត្វល្អិត និងជាតិគីមីផ្សេងៗទៀត ។

**លទ្ធផល** : សិស្សយល់ដឹងអំពីការប្រើប្រាស់ថ្នាំពុល ឬជាតិគីមីផ្សេងទៀតដែលធ្វើឱ្យមានការប៉ះពាល់ដល់សុខភាព ។

**សំភារៈឧបទេស** : អត្ថបទ "ប្រយ័ត្នបន្លែ ផ្លែឈើពុល" នៃលំហាត់នេះ ។

**សេចក្តីណែនាំ** : ក្នុងសកម្មភាពនេះ អ្នកគ្រូ-លោកគ្រូនិទានរឿងឱ្យសិស្សស្តាប់ ។ បើមានលទ្ធភាពឱ្យសិស្សអាន និងសំដែងតួទៅតាមសាច់រឿង ។ បន្ទាប់មក អ្នកគ្រូ-លោកគ្រូចោទសំនួរដូចមានខាងក្រោម ។

**អត្ថបទរឿងនិទាន :**

**វគ្គទី ១ : ការសន្ទនារវាងពូសុខ និងពូសៅ**

"- **ពូសុខ** : *សួស្តីសៅ ! តើឯងបំរុងធ្វើអ្វីមានចប និងបង្គីបែបនេះ ?*

- **ពូសៅ** : *អូ ! សុខទេតើ ! បន្លែរបស់ខ្ញុំឥឡូវដង្កូវស៊ីអស់ហើយ ។*

- **ពូសុខ** : *អូ ! អញ្ចឹងទេ ! បន្លែខ្ញុំពីមុនក៏ដូចឯងដែរ ។ នែ ! សំឡាញ់ឥឡូវនេះមានថ្នាំសំលាប់សត្វល្អិតមានគុណភាពខ្ពស់ណាស់ កុំថាតែដង្កូវស្មៅគ្រីតែសត្វល្អិតក្នុងដីក៏ងាប់ដែរ ។ ឯងទៅរកទិញនៅទីផ្សារទៅមិនខ្វះទេ ។*

- **ពូសៅ** : *អីយ៉ា ! សុខនិយាយត្រូវមែន ។ មើលចុះ ! ដង្កូវងាប់គ្មានសល់មួយស្មៅគ្រីតែសត្វល្អិតក៏ងាប់ដែរ ។*

- **កូនពូសៅ** : *ពុកៗ ! ឆ្មារបស់យើងងាប់ហើយ ។*

- **ពូសៅ** : *ហេតុអ្វីបានជាវាងាប់ ?*

- **កូនពូសៅ** : *ខ្ញុំមិនដឹងដែរពុក ។ ប៉ុន្តែខ្ញុំឃើញវាស៊ីសត្វចាបរាល់ថ្ងៃនៅឯរងបន្លែយើង ។"*

***វគ្គទី២ : ការសន្ទនារវាងមឹងសន និងមឹងភាព***

*"ក្នុងពេលទៅផ្សារមឹងភាព និងមឹងសនបានជួបគ្នានៅតាមផ្លូវ ហើយនិយាយគ្នាពីនេះពីនោះ :*

- **មឹងសន :** *នែ ! ភាព តើឯងដឹងទេសព្វថ្ងៃនេះនៅទីផ្សារ បន្លែ ផ្លែឈើដាំដុះ ក្នុងស្រុក និងនាំមកពីក្រៅប្រទេស គេបាញ់ថ្នាំការពារកុំឱ្យឆាប់រលួយ ហើយមិនឱ្យដង្កូវស៊ី ដើម្បីលក់បានថ្លៃ ។*
- **មឹងភាព :** *អញ្ចឹងមែនឬសន ! ខ្ញុំមានការចាប់អារម្មណ៍ដែរ ព្រោះខ្ញុំបានមើលទូរទស្សន៍ អង្គការសុខភាពពិភពលោកបានប្រកាសថា ចំណីអាហារជាប់ដោយជាតិពុល ពេលដែលយើងញ៉ាំទៅនឹងធ្វើឱ្យកើតមហារីកឈាម ហើយសព្វថ្ងៃអង្គការនេះចំណាយប្រាក់យ៉ាងច្រើន ដើម្បីស្រាវជ្រាវរកថ្នាំសំរាប់ព្យាបាល ។*
- **មឹងសន :** *បើអញ្ចឹងគិតយ៉ាងណាទៅ ដើម្បីដឹងថា បន្លែ ឬផ្លែឈើណាដែលគេបាញ់ថ្នាំ ឬមិនបាញ់ថ្នាំ ?*
- **មឹងភាព :** *ចំណែកខ្ញុំក៏មិនច្បាស់ដែរ ។ ប៉ុន្តែយើងអាចចំណាំបានខ្លះថា : បន្លែ ឬផ្លែឈើណាដែលល្អស្អាត គ្មានស្នាមដង្កូវស៊ីប្រហែលជាគេបាញ់ថ្នាំហើយ ។ ប៉ុន្តែមុននឹងស្ល ឬញ៉ាំផ្លែឈើ សនឯងត្រូវលាង ឬត្រាំទឹក ដើម្បីជំរះជាតិពុលនោះសិន ប្រយ័ត្នមានគ្រោះថ្នាក់ដល់កូនចៅ ។*
- **មឹងសន :** *យោបល់ឯងល្អម៉្យាងដែរ ។*
  *និយាយដល់ត្រឹមនេះ អ្នកទាំងពីរក៏បែកគ្នាទៅ ។"*

**សំនួរ :**

**កិច្ចទី២**

១- ក្នុងរឿងនេះមានតួអង្គអ្វីខ្លះ ?
២- យើងបាញ់ថ្នាំសំលាប់តែដង្កូវ ហេតុអ្វីបានជាសត្វល្អិតក្នុងដីត្រូវងាប់ដែរ ?
៣- តើសត្វណាខ្លះដែលស៊ីដង្កូវជាអាហារ ?
៤- ចុះបើសត្វដែលស៊ីដង្កូវងាប់ដោយថ្នាំពុល តើសត្វនោះនឹងទៅជាយ៉ាងណា ?
៥- យើងចូលចិត្តញ៉ាំចង្រិត ។ បើចង្រិតទាំងនោះត្រូវថ្នាំពុល តើយើងទៅជាយ៉ាងណាដែរ ? ហេតុអ្វីបានជាដូច្នេះ ?

**កិច្ចទី៣**

១- មានបន្លែពីរប្រភេទ :
- បន្លែគ្មានដង្កូវស៊ី ហើយគួរឱ្យចង់ទិញ (ដោយសារបាញ់ថ្នាំ) ។

- បន្លែមានជង្គរស៊ី ហើយគំលៃថោក ។

តើអ្នកសំរេចចិត្តទិញមួយណា ? ហេតុអ្វី ?

២- ឥឡូវមានតែបន្លែដែលគេបាញ់ថ្នាំ តើអ្នកធ្វើយ៉ាងណា ដើម្បីកុំឱ្យពុលនៅពេលដែលអ្នកស្ង ?

៣- តើការប្រើប្រាស់ថ្នាំពុល ធ្វើឱ្យប៉ះពាល់អ្វីខ្លះដល់បរិស្ថាន ?

៤- តើនឹងមានអ្វីកើតឡើងចំពោះគ្រួសារគេនៅពេលដែលគេទទួលទានបន្លែ ផ្លែឈើ មានជាតិថ្នាំពុល ?

៥- តើប្រទេសជាតិទាំងមូលនឹងទៅជាយ៉ាងណា បើបរិស្ថានដែលគេរស់នៅមានគេបំពុល ? ហេតុអ្វី ?

ម៉ូឌុលទី
៩

# មេទា និង ឆ្កែចចក

**រឿងនិទាន** **កំរិតទី១ ទី២ ទី៣**

**បញ្ញាបតាចរណ:** : វិទ្យាសាស្ត្រអនុវត្ត ភាសាខ្មែរ និងសិក្សាសង្គម ។

**បញ្ញត្តិ** : ការបំពុល ឬការធ្វើឱ្យកខ្វក់ដល់បរិស្ថាន ភាគច្រើនបណ្តាលមកពីសកម្មភាពរបស់មនុស្ស ដែលធ្វើដោយមិនដឹងខ្លួន ឬធ្វើមិនដឹងមិនឮ ។

**វត្ថុបំណង** : សិស្សយល់ថា សកម្មភាពអវិជ្ជមានរបស់មនុស្សជាហេតុបង្កឱ្យមានការបំពុលបរិស្ថាន ។

**លទ្ធផល** : សិស្សប្រកាន់ឥរិយាបថល្អ និងចូលរួមថែរក្សា ការពារបរិស្ថានឱ្យបានស្អាតល្អបរិសុទ្ធជានិច្ច ។

**សំភារៈឧបទេស** : រូបភាពមេទា និងឆ្កែចចក ។

**សេចក្តីណែនាំ** : នៅក្នុងសកម្មភាពនេះ អ្នកគ្រូ-លោកគ្រូនិទានរឿងឱ្យសិស្សស្តាប់ជាមុនសិន ។ បន្ទាប់មក ឱ្យសិស្សសង្ខេបរឿងនិទាននេះឡើងវិញ ។ បើមានលទ្ធភាព ឱ្យសិស្សអានរឿងនិទាន ហើយឱ្យសិស្សឯទៀតដើរតួតាមសាច់រឿង ។ ទីបញ្ចប់ អ្នកគ្រូ-លោកគ្រូចោទសំណួរដូចមានខាងក្រោម ។

**អត្ថបទរឿងនិទាន**

*"រឿងមួយតំណាលថា : នៅទីបឹងមួយដែលមានទឹកថ្លាឈ្វេង និងមានរុក្ខជាតិទាំងឡាយដុះខៀវខ្ចីស្រស់ បំព្រង មានមេទាមួយរស់នៅជាមួយកូនយ៉ាងសុខសាន្ត ។ ថ្ងៃមួយនៅពេលដែលមេទា និងកូនទាកំពុងហែលលេងយ៉ាងសប្បាយ មានឆ្កែចចកមួយបានរត់សំដៅមករកបឹងនេះ ដោយខ្លួនវាប្រឡាក់ទៅដោយក្លិនស្អុយអសោចមកជាមួយផង ។ ឆ្កែចចកបំរុងចុះផុសលាងក្លិនស្អុយនៅលើខ្លួននៅក្នុងទឹកបឹង ។ មេទាក៏បានស្រែកសួរថា : អេ ! បងចចកកំពុងធ្វើអ្វីហ្នឹង ? ឆ្កែចចកឆ្លើយថា : យើងចង់ចុះផុសលាងខ្លួនប្រាណដែលមានក្លិនស្អុយនេះណាំ ! ។ មេទាតបថា : ទេ ! មិនបានទេបង ខ្ញុំសូមអង្វរ សូមបងទៅផុសលាងខ្លួនរបស់បងនៅកន្លែងណាផ្សេងទៅ បើចុះផុសលាងខ្លួននៅទីនេះ ធ្វើឱ្យទឹកនេះកខ្វក់ និងមានក្លិនស្អុយ ដែលធ្វើឱ្យគ្រួសារខ្ញុំ និងរុក្ខជាតិដទៃទៀតពុំអាចរស់នៅបានឡើយ ។ ទោះជាមានការអង្វរពីមេទាយ៉ាងណាក៏ដោយ ឆ្កែចចកនៅតែបទេសចុះផុសលាងខ្លួនប្រាណស្អុយរបស់វាដដែល ។ ចាប់ពីពេលនោះមក ទឹកបឹងក្លាយទៅជាកករល្អក់ មានក្លិនស្អុយ ។ រុក្ខជាតិទាំងឡាយក៏ចាប់ផ្តើមស្វិតស្រពោន ។ មេទា និងកូនទាបាននាំគ្នាចាកចេញពីកន្លែងធ្លាប់រស់នៅសុខសាន្តទៅ រស់នៅកន្លែងមួយផ្សេងទៀត ។*

*រីឯឆ្កែចចកក៏នៅតែបន្តប្រើប្រាស់ទឹកបឹងនោះ ។ ថ្ងៃមួយវាកើតជំងឺរាគមួលយ៉ាងខ្លាំង ។ មិនយូរប៉ុន្មានវាក៏ស្លាប់ដោយសារការប្រើប្រាស់ទឹកបឹងដែលមានក្លិនស្អុយ និងមានសារជាតិពុលនោះទៅហោង ។"*

**"យើងយល់ពីបរិស្ថានគឺរស់ មិនយល់ដឹងពីបរិស្ថានគឺស្លាប់ " ។**

សំនួរត្រិះរិះ

ក. ចូរឆ្លើយនឹងសំនួរខាងក្រោម :

១- តើក្នុងរឿងនេះមានតួអង្គអ្វីខ្លះ ?

២- តើមេទាកំពុងធ្វើអ្វី ?

៣- តើចចកកំពុងធ្វើអ្វីដែរ ?

៤- តើចចកសំរេចគោលដៅរបស់វាឬទេ ?

៥- ហេតុអ្វីបានជាមេទា និងកូនទានាំគ្នាចាកចេញពីកន្លែងចាស់ ?

៦- តើចចកទទួលផលយ៉ាងណាដែរ នៅពេលដែលចាចចេសប្រើទឹកបឹងកខ្វក់នោះ ?

៧- តើអ្នកនិពន្ធចង់បង្ហាញគំនិតអ្វីខ្លះ តាមអត្ថបទនៃរឿងនិទាននេះ ?

៨- តើអ្នកមានមតិ ឬអារម្មណ៍យ៉ាងដូចម្តេចចំពោះអត្ថន័យនៃរឿងនិទាននេះ ?

ខ. ចូរអ្នករៀបហេតុការណ៍ដាក់តាមលំដាប់នៅក្នុងរឿង :

១- នៅទីបឹងមួយដែលមានទឹកថ្លាឈ្វេង និងមានរុក្ខជាតិនានាដុះខៀវខ្ចីស្រស់បំព្រង មានមេទាមួយរស់នៅជាមួយកូនយ៉ាងសុខសាន្ត ។

២- ទោះជាមានការអង្វរពីមេទាយ៉ាងណាក៏ដោយ ឆ្កែចចកនៅតែចចេសចុះងូតលាងខ្លួនប្រាណស្អុយរបស់វាដដែល ។

៣- មានឆ្កែចចកមួយបានរត់សំដៅមករកបឹងនេះ ដោយខ្លួនវាប្រឡាក់ទៅដោយក្លិនស្អុយអសោច ។

៤- ចាប់ពីពេលនោះមក ទឹកបឹងក្លាយទៅជាកករល្អក់ មានក្លិនស្អុយ ។

៥- សូមបងទៅដុសលាងខ្លួនរបស់បងនៅកន្លែងណាផ្សេងទៅ បើចុះដុសលាងខ្លួននៅទីនេះធ្វើឱ្យទឹកនេះកខ្វក់ និងមានក្លិនស្អុយ ។

> កំណត់សំគាល់ : និពន្ធដោយ លោក ពីង គិមឆេន ប្រធានកំរងសាលាវត្តបូព៌ ខេត្តសៀមរាប នាឱកាសសិក្ខាសាលាស្តីពីការអប់រំបរិស្ថានក៏រិតបឋមសិក្សា តាមរយៈកំរងសាលាភូមិភាគសៀមរាប : ១៧ដល់ ២០ មិថុនា ១៩៩៧ ។

មុខងារទី
៩

# ការកាត់បន្ថយភាពកខ្វក់

**សំនួរសេរសេរ / តេស្ត** **កិច្ចការទី១ ទី២ និងទី៣**

**បញ្ញាបតាមរយៈ** : វិទ្យាសាស្ត្រអនុវត្ត សិក្សាសង្គម គណិតវិទ្យា និងភាសាខ្មែរ ។

**បញ្ញត្តិ** : ភាពកខ្វក់បង្កឱ្យមានសុខភាពមិនល្អចំពោះមនុស្ស និងសត្វ ។

**វត្ថុបំណង** : សិស្សយល់ដឹងពីផលល្អនៃការសំអាតបរិស្ថាន ។

**លទ្ធផល** : សិស្សកែប្រែពីទំលាប់មិនល្អក្នុងការបោះចោលសំរាម ដើម្បីកាត់បន្ថយភាពកខ្វក់ក្នុងបរិស្ថានយើង ។

**សំភារៈឧបទេស** : សៀវភៅលំហាត់ ប៊ិក ឬខ្មៅដៃ រូបភាព ។

**សេចក្តីណែនាំ** : សកម្មភាពនេះ ជាការត្រួតពិនិត្យការយល់ដឹងរបស់សិស្សក្នុងការកាត់បន្ថយភាពកខ្វក់ ។ បន្ទាប់មក អ្នកគ្រូ-លោកគ្រូចោទសំនួរដូចខាងក្រោម ។

**សំនួរ**

**កិច្ចការទី១**

១- តើអ្វីខ្លះដែលជាសំរាម ?

២- តើសំរាមផ្ទះបាយមានអ្វីខ្លះ ?

៣- តើប្អូនត្រូវចាក់សំរាមនៅទីណា ?

**កិច្ចការទី២**

១- ចូរចែកថ្នាក់សំរាមក្នុងផ្ទះអ្នក និងសាលារៀនអ្នកដែលជា :

ក. សំរាមស្ងួត ។

ខ. សំរាមសើម ។

២- តើសំរាមប្រភេទណាមួយដែលគេអាចយកទៅប្រើប្រាស់ឡើងវិញបាន ?

៣- នៅក្នុងបញ្ជីសំរាមខាងក្រោម តើសំរាមណាមួយដែលអ្នកត្រូវជីកកប់ក្នុងដី ឬក៏លក់ ?

ក- ស្មៅជំរះ ស្លឹកឈើជ្រុះ ។

ខ- កំប៉ុងប្រេះ អំបែងកែវដប ។

គ- បន្លែសល់រលួយ ។

ឃ- សំបកកែសក្រដាស ឬសំបកដប ។

ង- ថង់ប្លាស្ទិច បានដែកបែក

**កំរិតទី៣**

១- សង្កេតរូប ហើយឆ្លើយសំនួរខាងក្រោម :






ក- តើមានសារៈសំខាន់អ្វីខ្លះ ក្នុងការច្នៃប្រឌិតប្រភេទសំរាមខ្លះយកទៅប្រើប្រាស់ម្តងទៀត ?

ខ- តាមរយៈរូបភាព ចូរបង្ហាញពីការប្រើប្រាស់ឡើងវិញនូវប្រភេទសំរាមខ្លះៗនៅ ផ្ទះ និងសាលារៀនរបស់អ្នក?

២- ចូរឆ្លើយសំនួរខាងក្រោម :

ក- បើសិនអ្នកជាប្រធានភូមិ ឬចៅសង្កាត់ តើអ្នកត្រូវរៀបចំច្បាប់ ឬវិធានការយ៉ាងណាក្នុងការចាក់សំរាមចោលក្នុងភូមិ ឬសង្កាត់របស់អ្នក ?

ខ- បើម្នាក់ៗបោះចោលសំរាមគ្រប់ទីកន្លែងក្នុងភូមិរបស់អ្នក តើភូមិរបស់អ្នកមានទិដ្ឋភាពយ៉ាងដូចម្តេច ?

គ- តើប្អូនមានវិធីអ្វីខ្លះក្នុងការបំបាត់សំរាម ?

✍
មុខងារទី
៩

# ការកាត់បន្ថយភាពកខ្វក់ដែលកើតពីសំរាម

**សកម្មភាពក្នុង និងក្រៅថ្នាក់** **ការិតទី២ និងទី៣**

**បញ្ញាបតាមរយ:** : សិក្សាសង្គម វិទ្យាសាស្ត្រអនុវត្ត និងភាសាខ្មែរ ។

**បញ្ញត្តិ** : ការចែកថ្នាក់សំរាម និងការប្រើប្រាស់សំរាមឡើងវិញ ដើម្បីចូលរួមកាត់បន្ថយភាពកខ្វក់ដល់បរិស្ថាន ដែលធានាដល់អនាម័យ និងសុខភាព ។

**វត្ថុបំណង** : សិស្សចេះចាត់ថ្នាក់សំរាម និងចេះយកសំរាមមកប្រើប្រាស់ឡើងវិញ ។

**លទ្ធផល** : សិស្សមានកិរិយាបថកែទំលាប់មិនល្អក្នុងការបោះចោលសំរាម ដើម្បីចូលរួមកាត់បន្ថយភាពកខ្វក់នៃបរិស្ថានយើង ។

**សំភារៈឧបទេស** : រូបភាព ដីស ក្តារខៀន (បើមានលទ្ធភាពអាចអូសសន្លឹកតេស្តចែកសិស្ស) ។

**សេចក្តីណែនាំ** : ក្នុងសកម្មភាពក្រៅថ្នាក់ ដំបូងគ្រូឱ្យសិស្សប្រមូលពត៌មាន (ឈ្មោះសំរាម) ដែលមាននៅជុំវិញខ្លួន ផ្ទះ និងក្នុងសហគមន៍ដែលគេរស់នៅ ។
មកដល់ថ្នាក់រៀនវិញ គ្រូគ្រាន់តែជាអ្នកជួយសិស្សឱ្យចេះប្រែក្លាយពត៌មានទាំងនោះទៅជាចំណេះដឹង បំណិន និងធានាឱ្យមានប្រសិទ្ធភាព លើការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្ស ។

**ក- ខាងក្រោមនេះ ជាសកម្មភាពទី១ដែលអ្នកគ្រូ-លោកគ្រូត្រូវអនុវត្តសំរាប់រយៈពេល១ម៉ោងសិក្សា :**

១- ណែនាំសិស្សឱ្យធ្វើការសង្កេតនៅតាមផ្ទះរៀងៗខ្លួន មុននឹងធ្វើសកម្មភាពក្នុងថ្នាក់ ។

២- រៀបចំជាសំណួរខ្លះៗ ដើម្បីបំផុសគំនិតដល់សិស្សក្នុងការចេញស្រាវជ្រាវ ដូចមានខាងក្រោម :

- ចូរអ្នកគិតមើល តើអ្វីខ្លះជាសំរាម ?
- ជាធម្មតា តើនៅក្នុងផ្ទះ ឬជុំវិញផ្ទះរបស់អ្នកមានសំរាមដែរឬទេ ? តើសំរាមនោះមានអ្វីខ្លះ ?
- ក្នុងផ្ទះ និងជុំវិញផ្ទះ តើកន្លែងណាដែលសំបូរសំរាមជាងគេ ?
- ហេតុអ្វីបានជាមានសំរាមបែបនេះ ?
- តើអ្នកណាជាអ្នកបោះចោល ? តើជាប្អូន ឬជាបង ? ឬជាឪពុកម្តាយរបស់អ្នក ?
- ចំពោះអ្នកវិញ តើបានបោះចោលសំរាមទេក្នុងមួយថ្ងៃៗ? តើបោះចោលអ្វីខ្លះ ?

ហើយយកទៅចោលនៅកន្លែងណា ?

- តើអ្នកមានគំនិតយ៉ាងដូចម្ដេចពេលសំរាមកាន់តែច្រើនឡើងៗនៅជុំវិញផ្ទះ ?
- អ្នកអាចគិតម្ដងទៀតទៅមើល តើមានវិធីណាដែលល្អជាងវិធីដែលអ្នកបានធ្វើធ្វើខាងលើ ហើយបានចំណេញពីសំរាមនោះផង ?

៣- ពេលចូលមកដល់ថ្នាក់រៀនវិញ គ្រូត្រូវចែកសិស្សជាក្រុមទៅតាមចំណុចជាក់ស្ដែង ហើយឱ្យសិស្សពិភាក្សាជាមួយមិត្តភក្ដិក្នុងក្រុមដោយសរសេរឈ្មោះសំរាមខ្លះៗ ដែលបានស្រាវជ្រាវឃើញនៅតាមផ្ទះរបស់សិស្សម្នាក់ៗចូលក្នុងបញ្ជី ដូចមានក្នុងប្រអប់ខាងក្រោម :

| | | |
|---|---|---|
| ១- | ៦- | ១១- |
| ២- | ៧- | ១២- |
| ៣- | ៨- | ១៣- |
| ៤- | ៩- | ១៤- |
| ៥- | ១០- | ១៥- |

៤- បន្ទាប់មកគ្រូចោទសំនួរឱ្យសិស្សពិភាក្សាជាក្រុម ដូចមានខាងក្រោម រួចឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ពីលទ្ធផលនៃការពិភាក្សា ។

- តើអ្នកនឹងអាចយកសំរាមទាំងនោះទៅចាក់ចោលតាមវិធីណា ?
- អ្នកសាកល្បងគិតមើល តើវិធីណាដែលសមរម្យ ?

**៦_ ខាងក្រោមនេះជាសកម្មភាពទី២ ដែលអ្នកគ្រូ_លោកគ្រូត្រូវអនុវត្តដូចចំនុចខាងក្រោម ដោយប្រើពេល១ម៉ោងសិក្សា**

១. គ្រូបង្ហាញរូបភាពខាងក្រោមដល់សិស្ស ហើយដាក់សំនួរឱ្យសិស្សដោះស្រាយ ។





*សំនួរ ៖ ពីរឆ្នាំមុនស្រះនេះសំបូរត្រីណាស់ តែឥឡូវនេះគ្មានត្រីទេ ។ ស្រះកាន់តែរាក់ ។ ដំណាំដែលគេដាំនៅក្បែរស្រះនេះក៏លូតលាស់យឺត ។ ឯប្រជាពលរដ្ឋដែល ប្រើប្រាស់ទឹកស្រះនេះក៏មានជំងឺដែរ ។*

* *ហេតុអ្វីបណ្ដាលឱ្យមានកើតបញ្ហាបែបនេះ ?*

២- ឱ្យសិស្សធ្វើការពិភាក្សាក្នុងក្រុម ដើម្បីរកអំណះអំណាងសមហេតុផលដើម្បីរាយការណ៍ ។

៣- បន្ទាប់មក គ្រូបន្តសំនួរ ដើម្បីឱ្យសិស្សពិភាក្សាក្នុងក្រុមរកចំលើយត្រឹមត្រូវ ដោយគ្រាន់តែគូសជុំវិញលើពាក្យ ឬក្រុមណាតែប៉ុណ្ណោះ ។ បញ្ជាក់ថា ចំលើយត្រឹមត្រូវមានតែមួយគត់ ។

*សំនួរ ៖ ក្នុងក្រុមរបស់អ្នក អ្នកអាចគិតទៅមើល តើវិធីណាដែលល្អជាងគេក្នុងការបោះចោលសំរាម ? (ចំលើយគឺត្រូវគូសរង្វង់ជុំវិញចំនុចណាមួយ ក្នុងចំណោមចំនុចទាំង ៤)*

ក- សំបកថង់ប្លាស្ទិច
- ចាក់ចោលក្នុងទឹកទន្លេ
- លក់ឱ្យអេតចាយ
- ប្រមូលដុត
- ជីកកប់

ខ- សត្វកណ្ដុរងាប់
- បោះចោលកណ្ដាលថ្នល់
- ចោលក្នុងគំនរសំរាម
- ជីកកប់ឱ្យឆ្ងាយពីប្រភពទឹក
- ដុត

គ- សំបកដូង កាកអំពៅ
- ជីកកប់
- ដុតចំអិនអាហារ
- បោះចោលក្នុងទឹក
- ប្រមូលដុតចោល

ឃ- បន្លែសល់ កាកបាយ កាកសំឡ
- ចាក់ចូលក្នុងថង់ប្លាស្ទិក រួចបោះចោលទៅក្នុងគំនរសំរាម
- ជះលើដី
- ធ្វើចំណីសត្វ (ជ្រូក)
- ជីកកប់

ង- កំទេចកំទីពុកផុយ ស្លឹកឈើ ជ្រុះ ស្មៅជំរះហើយ
- ដុត
- ប្រមូលចាក់ចូលក្នុងស្នូង
- ឱ្យទៅអ្នកប្រមូលសំរាម
- ជីកកប់ក្បែរដើមឈើ

ច- សំបកដប សំបកឡាំង កាសែតចាស់ៗ
- ឱ្យទៅអ្នកប្រមូលសំរាម
- លក់ឱ្យអេតចាយ
- ដុតចោល
- ជីកកប់

ឆ- សំបកកង់ សំបកកង់ឡាន សំបកកង់ម៉ូតូ

- ដុតចោល
- ជីកកប់
- បោះចូលក្នុងទន្លេ
- ច្នៃធ្វើជាសំភារៈប្រើម្តងទៀត

ជ- អំបែងដប អំបែងចាន សំបកកំប៉ុងច្រែះ

- បោះចោលនៅគំនរសំរាម
- លក់ឱ្យអេតចាយ
- ជីកកប់
- ទុកគរចោល

ឈ- សំណល់វត្ថុរឹងភាវចេញពីរោងចក្រ-សិប្បកម្ម

- ដឹកយកទៅចាក់ចោលឱ្យឆ្ងាយពីប្រភពទឹក
- បង្ហូរចូលក្នុងទឹក
- ជីកកប់
- ស្តុកគរចោល

ម៉ូឌុលទី
៩

# ការស្ទង់ពិនិត្យមើលចរាចរណ៍នៅទីប្រជុំជន

**សកម្មភាពក្រៅថ្នាក់** **ថ្នាក់ទី២ និងទី៣**

**បញ្ញាបទានរួម** : គណិតវិទ្យា សិក្សាសង្គម និងភាសាខ្មែរ ។

**បញ្ញត្តិ** : កំណើនយានយន្តគ្រប់ប្រភេទនៅក្នុងទីប្រជុំជន ឬទីក្រុង ។

**វត្ថុបំណង** : សិស្សចេះធ្វើស្ថិតិនៃកំណើនយានយន្តនៅតាមមូលដ្ឋានរបស់ខ្លួន តាមរយៈការអង្កេតស្រាវជ្រាវ ។

**លទ្ធផល** : សិស្សយល់ពីផលវិបាកនៃកំណើនយានយន្ត (ការបំពុលខ្យល់ និងការបំពុលដោយសូរសំលេង ស្ទះចរាចរ ...) ។

**សំភារៈឧបទេស** : សៀវភៅលំហាត់ ឬតារាង ខ្មៅដៃ ឬប៊ិក ។

**សេចក្តីណែនាំ** : ក្នុងសកម្មភាពនេះ អ្នកគ្រូ-លោកគ្រូត្រូវអនុវត្តតាមចំនុចដូចខាងក្រោម :

១- ឱ្យសិស្សគូសតារាងក្នុងសៀវភៅលំហាត់ដូចខាងក្រោម :

| ៨:០០-៨:៣០ ឬពេលណាមួយសមរម្យ | រថយន្តដឹកទំនិញ | រថយន្តតូច | ទោចក្រយានយន្ត | ស៊ីក្លូ | រទេះសេះ | ទោចក្រយាន | រទេះគោ | ថ្មើរជើង | រថភ្លើង | កាណូត | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| ១-ដើមឆ្នាំសិក្សា | | | | | | | | | | | |
| ២-២ខែក្រោយមក | | | | | | | | | | | |
| ៣-២ខែក្រោយមក | | | | | | | | | | | |
| ៤-២ខែក្រោយមក | | | | | | | | | | | |
| ៥-២ខែក្រោយមក | | | | | | | | | | | |
| ៦-ដំណាច់ឆ្នាំសិក្សា | | | | | | | | | | | |
| ៧- ស រុ ប | | | | | | | | | | | |

២- ចែកសិស្សជា៥ក្រុម ដែលក្រុមនីមួយៗនឹងទទួលខុសត្រូវរាប់ចំនួនទៅតាមប្រភេទយានយន្តនីមួយៗ (រថយន្តធំដឹកទំនិញ រថយន្តតូច ទោចក្រយានយន្ត ស៊ីក្លូ និងទោចក្រយាន្ត ...) ។

៣- នៅលើចិញ្ចើមផ្លូវណាមួយជិតសាលារៀន សិស្សត្រូវចំណាយពេល៣០នាទី ដើម្បីរាប់ចំនួនយានគ្រប់ប្រភេទ ។

៤- ពេលត្រលប់ចូលមកក្នុងថ្នាក់វិញ ក្រុមនីមួយៗធ្វើការប្រៀបធៀបចំនួន និងប្រភេទយានយន្ត ហើយអ្នកគ្រូ-លោកគ្រូសរុបស្ថិតិតាមប្រភេទយានយន្តនីមួយៗ ឬចំលងស្ថិតិចូលនៅលើក្តារខៀន ។ សិស្សបំពេញស្ថិតិចូលក្នុងសៀវភៅលំហាត់ ។

៥- ធ្វើលំហាត់នេះឡើងវិញ រៀងរាល់២ខែម្តងរហូតដល់ដំណាច់ឆ្នាំសិក្សា ។

៦- វិភាគតួលេខដែលទទួលបានក្នុងមួយឆ្នាំសិក្សា ហើយធ្វើការសន្និដ្ឋានចំពោះការបំពុលខ្យល់ និងការបំពុលដោយសូរសំលេងមានការកើនឡើងស្របពេលទៅនឹងកំណើននៃយានយន្តគ្រប់ប្រភេទ ។

✍ មុខងារទី ៩

# បរិស្ថាន និងការបំពុល

**សកម្មភាពក្នុង និងក្រៅថ្នាក់** **ការិតទី២ និងទី៣**

**បញ្ញាបតាចរយៈ** : វិទ្យាសាស្ត្រអនុវត្ត សិក្សាសង្គម និងភាសាខ្មែរ ។

**បញ្ញត្តិ** : ការបំពុលបរិស្ថាន ទឹក ខ្យល់ និងសូរសំលេង នាំមកនូវគ្រោះអន្តរាយដល់ខ្លួនយើង ។

**វត្ថុបំណង** : សិស្សយល់ដឹងពីសារៈសំខាន់នៃទឹក ខ្យល់ និងភាពគ្មានការរំខានសូរសំលេង ។

**លទ្ធផល** : សិស្សចូលរួមធ្វើអនាម័យនៅក្នុងបន្ទប់រៀន សាលារៀន នៅផ្ទះ និងសហគមន៍ ។

**សំភារៈឧបទេស** : ទឹក កែវ ថង់ប្លាស្ទិក ស្លឹកឈូក ស្លឹកចេក កូនវិទ្យុ ។

**សេចក្តីណែនាំ** :

♦ សំរាប់សកម្មភាពក្នុងថ្នាក់ អ្នកគ្រូ-លោកគ្រូត្រូវចំលងអត្ថបទកំណាព្យលើក្តារខៀនជាមុនសិន ។ បើមានរាំងនន បិទរាំងននសិន ។ នៅពេលបង្រៀនសឹមបើករាំងនន ។ ការបង្រៀនត្រូវបែងចែកជា២វគ្គ ដូចការបង្រៀនមេសូត្ររត់មាត់ដែរ គឺ :

- វគ្គទី១ :
  - ពន្យល់ន័យពាក្យពិបាក
  - លើកសំនួរដើម្បីយល់អត្ថន័យ
- វគ្គទី២ :
  - គ្រូអានអត្ថបទដោយសូត្រតាម "*បទពាក្យ៧*" ឱ្យសិស្សស្តាប់១ដង ឬ២ដង ។
  - ឱ្យសិស្សអានតៗគ្នាក្នុងម្នាក់២ឃ្លះឱ្យបានយ៉ាងតិច៣ចប់ ។
  - គ្រូចាប់ផ្តើមលុបពាក្យចុងចូននៅចុងឃ្លាបន្ទាប់ ។ រួចមកលុបពាក្យដទៃទៀត រហូតទាល់តែអស់អត្ថបទទាំងមូល ។
  - ឱ្យសិស្សសូត្រអត្ថបទឡើងវិញតាមការចងចាំ ។ ទីបញ្ចប់ អ្នកគ្រូ-លោកគ្រូចោទសំនួរដូចមានខាងក្រោម ។

♦ សំរាប់សកម្មភាពក្រៅថ្នាក់ (លំហាត់នៅផ្ទះ) ឱ្យសិស្សចំលងអត្ថបទកំណាព្យនេះដាក់ក្នុងសៀវភៅលំហាត់ ហើយឱ្យសិស្សធ្វើលំហាត់នៅផ្ទះ ដោយសូត្រកំណាព្យ និងពិភាក្សាអំពីអត្ថន័យនៃកំណាព្យជាមួយបងប្អូន ឪពុកម្តាយ ឬញាតិមិត្តជិតខាង ។ ពេលមកដល់ថ្នាក់រៀនវិញ ឱ្យសិស្សរាយការណ៍ជូនមិត្តរួមថ្នាក់អំពីលទ្ធផលដែលគេ ទទួលបានពីមិត្តភក្តិ បងប្អូន ឪពុកម្តាយរបស់គេ ។

**អត្ថបទកំណាព្យ**

## បរិស្ថាន និងការបំពុល

(បទពាក្យ៧)

| | |
|---|---|
| ១- បំពុលបរិស្ថានទង្វើបី | ញាត្តិមិត្តប្រុសស្រីត្រូវត្រងត្រាប់ |
| បំពុលបរិស្ថានអាចឱ្យស្លាប់ | បើរស់ក៏យ៉ាប់ព្រោះអាប់អួរ ។ |
| ២- មួយបំពុលទឹកនឹកមិនដល់ | បោះចោលសំណល់ចូលបឹងបួរ |
| សំណល់ដាក់ធុង ឬស្បោងយួរ | មិនគួរចោលតរឱ្យស្អុយហើម ។ |
| ៣- ទីពីរគឺការបំពុលខ្យល់ | ដែលនាំប៉ះពាល់ដល់ដង្ហើម |
| ទោះសត្វ រុក្ខជាតិ មនុស្សជាដើម | ដង្ហើមត្រូវការខ្យល់ប្រពៃ ។ |
| ៤- ទីបីបំពុលតាមសំលេង | រំខានការគេងអ្នកជទៃ |
| មិនថាជនបទទីក្រុងក្តី | គិតគូរលកលៃរកវិធាន ។ |
| ៥- អប់រំណែនាំឱ្យគេយល់ | ឱ្យស្គាល់តំលៃពីបរិស្ថាន |
| កុំឱ្យមនុស្សចេះតែបំពាន | ដល់ការរស់រាន សត្វ រុក្ខជាតិ។ |
| ៦- កាតព្វកិច្ចយើងទាំងអស់គ្នា | ចូរកុំព្រួយត្រូវខ្វះឃ្លាត |
| បន្ទយជាតិពុលសង្គមជាតិ | ស្រស់សាច់ជៅញាតិស្រស់ប្រិមប្រិយ ។ |

**សំនួរ**

**ក. សំនួរត្រិះរិះ**

១- អ្នកផឹកទឹក បើទឹកនោះគ្មានអនាម័យ តើអ្នកនឹងទៅជាយ៉ាងណា ?

២- អ្នកត្រូវមានវិធានការយ៉ាងណាខ្លះ ដើម្បីថែរក្សាប្រភពទឹកឱ្យបានល្អ ?

៣- អ្នកដកដង្ហើមរាល់ពេលវេលា គឺដើម្បីអ្វី ? (*ស្រូបយកខ្យល់ល្អតាមច្រមុះ*)

៤- តើអ្វីខ្លះដែលធ្វើឱ្យការដកដង្ហើមរបស់អ្នកពិបាក និងមានគ្រោះថ្នាក់ ?

៥- តើសូរសំលេងខ្លាំងៗផ្តល់ផលអាក្រក់អ្វីខ្លះដល់មនុស្ស ជាពិសេសមនុស្សចាស់ ?

៦- នៅក្នុងបន្ទប់រៀន សាលារៀន និងនៅផ្ទះរបស់អ្នក តើអ្នកមិនត្រូវធ្វើសកម្មភាពអ្វីខ្លះ ដែលនាំឱ្យពុលទឹក ខ្យល់ និងសូរសំលេង ?

៧- បើយើងទាំងអស់គ្នាអាចធ្វើឱ្យទឹកស្អាត ខ្យល់ស្អាត និងពុំរំខានដោយសូរសំលេងខ្លាំងៗ តើយើងម្នាក់ៗនឹងទៅជាយ៉ាងណា ? ការសិក្សាយ៉ាងណា ? ជាតិយើងយ៉ាងណា ?

**ខ. លំហាត់**

១- ចូរពន្យល់ន័យរបស់ពាក្យដែលគូសបន្ទាត់ពីក្រោមនៅក្នុងអត្ថបទកំណាព្យខាងលើនេះ ។

*កំណត់សំគាល់ : និពន្ធដោយ : លោក ខៀវ នរុត្តី អនុប្រធានការិ.បុគ្គលិក មន្ទីរ អ.យ.ក ខេត្តកំពត និងកែសំរួលដោយសមាជិកក្រុមទី ៤ នាឱកាសសិក្ខាសាលាស្តីពីការអប់រំបរិស្ថានកំរិតបឋម តាមរយៈកំរងសាលាភូមិភាគក្រុងព្រះសីហនុ : ២៤ ដល់ ២៧ មិថុនា ១៩៩៧ ។*

ទំនុកទី ៩

# សំណោកបរិស្ថាន

**សកម្មភាពក្នុង និងក្រៅថ្នាក់** **ថ្នាក់ទី២ និងទី៣**

**បញ្ញាបទាចរយ:** : ភាសាខ្មែរ វិទ្យាសាស្ត្រអនុវត្ត និងសិក្សាសង្គម ។

**បញ្ញត្តិ** : ធនធានធម្មជាតិមានសំបូរបែបនៅប្រទេសកម្ពុជា ដែលពលរដ្ឋខ្មែរគ្រប់រូបត្រូវនាំគ្នាថែរក្សា ។

**វត្ថុបំណង** : សិស្សយល់ថា មនុស្សមិនអាចផ្ដាច់ខ្លួនចេញពីបរិស្ថានណាមួយឡើយ ។

**លទ្ធផល** : សិស្សសន្និដ្ឋានថា បើវប្បធម៌សាបសូន្យ ជាតិនឹងរលាយ ដែលទាមទារឱ្យមនុស្សម្នាក់មានមនសិការថែរក្សា ការពារបរិស្ថានជានិច្ច ។

**សំភារៈឧបទេស** : រូបភាពប្រាសាទអង្គរ ឬប្រាសាទ ឬវត្តអារាមណាមួយ ។

**សេចក្ដីណែនាំ** :

- ♦ សំរាប់សកម្មភាពក្នុងថ្នាក់ អ្នកគ្រូ-លោកគ្រូត្រូវណែនាំបង្រៀនសិស្សឱ្យចេះច្រៀងតាម "*លំនាំបទស្រណោះរ៉ៃយំ*" ជាមុនសិន ។ បន្ទាប់មក ឱ្យសិស្សច្រៀងម្នាក់ម្ដងៗ រួចជាក្រុមៗ ។ ទីបញ្ចប់ អ្នកគ្រូ-លោកគ្រូចោទសំនួរដូចខាងក្រោម ។
- ♦ សំរាប់សកម្មភាពក្រៅថ្នាក់ (លំហាត់នៅផ្ទះ) ឱ្យសិស្សចំលងអត្ថបទចំរៀងនេះដាក់ក្នុងសៀវភៅលំហាត់ ហើយឱ្យសិស្សធ្វើលំហាត់នៅផ្ទះ ដោយច្រៀងចំរៀង និងពិភាក្សាអំពីអត្ថន័យនៃចំរៀងជាមួយបងប្អូន ឪពុកម្ដាយ ឬញាតិមិត្តជិតខាង ។ ពេលមកដល់ថ្នាក់រៀនវិញ ឱ្យសិស្សរាយការណ៍ជូនមិត្តរួមថ្នាក់អំពីលទ្ធផលដែលគេទទួលបានពីមិត្តភក្តិ បងប្អូន ឪពុកម្ដាយរបស់គេ ។

## អត្ថបទចំរៀង

### សំណោកបរិស្ថាន

(លំនាំបទ ស្រណោះរ៉ៃយំ)

I. សែនស្រណោះអើយខ្លួនខ្ញុំ ធ្លាប់តែឧត្ដម ល្អស្រស់ប្រិមប្រិយ (ពីរដង)
តែឥឡូវៗ អាក្រក់ណាស់ក្រៃ នរជនប្រុសស្រី គេមិនមេត្តា ។

II. គេបំផ្លាញអើយរូបខ្ញុំ ហាក់មានគំនុំ ខ្លាំងក្លាពេកក្រៃ (ពីរដង)
គេខំប្រឹងៗ ប្រែប្រះក្រឡៃ ឥតមានសំចៃ លើរូបខ្ញុំសោះ ។

III. គេបង្ហើរអើយផ្សែងពុល    ចួចឡើងភលៗ  នៅលើវេហាស៍ (ពីរដង)
នាំអាក្រក់ៗ ផ្ទៃអាកាសា    ដែលជាសង្ខារ  នៃអស់សព្វសត្វ ។

IV. ចំណែកនៅអើយក្នុងទឹក    ច្រើនក្រៃសន្ធឹក  នូវកាកសំណល់ (ពីរដង)
ដែលគេបានៗ ប្រើនៅសេសសល់  គេមិនអំពល់ខ្វាយខ្វល់អ្វីឡើយ ។

V. រីសំលេងទៀតសោត    គេមិនចេះកោត  ក្រែងនរណាអី (ពីរដង)
ខំប្រឹងស្រែកៗ  បំពងអស់ដៃ   បំរើសេចក្តី    ត្រូវការរបស់ខ្លួន ។

VI. អាសូររូបអើយខ្ញុំផង   កុំមានបំណង   ប្រល័យសង្ខារ (ពីរដង)
ខ្ញុំចង់រស់ៗ នៅក្នុងលោកា    មិនចង់មរណា   ផុតពីទ្វីបលោក ។

VII. ប្រួលប្រែអស់ហើយខ្ញុំ     សែនកើតទុក្ខធំ  នៅក្នុងលោកីយ៍ (ពីរដង)
បើមនុស្សសត្វៗ ពុំបានខ្វល់ខ្វាយ   អ្នកនឹងកើតភ័យ    ថ្ងៃក្រោយមិនខាន ។

VIII. អ្នកត្រូវចងអើយចាំថា     រូបខ្ញុំនេះណា    គឺជាខ្លួនអ្នក (ពីរដង)
រីអ្នកវិញៗ នោះប្រាកដជាក់   ពុំមានអបលក្ខណ៍     គឺជារូបខ្ញុំ ។

IX. ហេតុនេះអ្នកទាំងអស់គ្នា     គ្រប់ៗអង្គា     ត្រូវតែខិតខំ (ពីរដង)
ថែរក្សាៗ  ការពាររូបខ្ញុំ      ឱ្យបានសុខជុម  ខ្ញុំជាបរិស្ថាន ។

**សំនួរត្រិះរិះ**

១- តើក្នុងចំរៀងនេះ អ្នកនិពន្ធចង់បង្ហាញពីអ្វី ?

២- តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចចំពោះអត្ថន័យនៃចំរៀងនេះ ?

៣- តើឃ្លា ឬវគ្គត្រង់ណាដែលបង្ហាញឱ្យឃើញពីការបំពុលខ្យល់ សំលេង និងទឹក ?

> *កំណត់សំគាល់ : និពន្ធដោយលោក ឡុង គិម សួង ប្រធានការិយាល័យបឋមសិក្សា និងមន្ត្រីយ៍នៃមន្ទីរអ.យ.ក ខេត្តរតនគិរី និងកែសំរួលដោយសមាជិកក្រុមទី ៤ នាឱកាស សិក្ខាសាលាស្តីពីការអប់រំបរិស្ថានក្នុងកំរិតបឋមសិក្សា តាមរយៈកំរងសាលាភូមិភាគក្រុងព្រះសីហនុ : ២៧ ដល់ ២៧ មិថុនា ១៩៩៧ ។*

ជំពូកទី
១០

# គុណភាពនៃជីវិត

**វត្ថុបំណង** : សិស្សយល់ដឹងពីកត្តាផ្សេងៗដែលរួមចំណែកក្នុងជីវភាពរស់នៅរបស់ខ្លួន និងអ្នកដទៃ ។

**លទ្ធផល** : សិស្សទទួលបានចំណេះដឹងអំពីជីវភាពរស់នៅមានគុណភាពអាស្រ័យលើសកម្មភាពត្រឹមត្រូវ និងសីលធម៌ល្អសំដៅលើខ្លួនឯង អ្នកដទៃ និងបរិស្ថានជុំវិញ ។

**សំណូមពរ** : ខ្លឹមសារមេរៀន និងសំភារៈឧបទេសត្រូវសំរបទៅតាមកំរិតរបស់សិស្ស ។

## ក. គុណភាពនៃជីវិតជាអ្វី

**គុណភាពនៃជីវិត** ជារបៀបរបបរស់នៅមួយដែលយើង និងគ្រួសាររបស់យើងរស់នៅក្នុងសហគមន៍ ហើយមានទំនាក់ទំនងជាមួយបរិស្ថានដែលនៅជុំវិញ ។

**គុណភាពខ្ពស់នៃជីវិត ឬជីវិតមានគុណភាព** មានន័យថាយើង និងគ្រួសាររបស់យើងទទួលបានតំរូវការចាំបាច់ជាមូលដ្ឋានគ្រប់គ្រាន់ដូចជា ចំណីអាហារ ទីជំរក ទឹក សំលៀកបំពាក់ក៏ដូចជាតំរូវការផ្នែកសញ្ចេតនា និង ស្មារតីក្នុងជីវិតរស់នៅ ។ អ្នករស់នៅដោយរីករាយពេញចិត្តប្រកបដោយសុខភាពល្អ មានជីវិតរុងរឿង តែយើងគួរមានស្មារតីទទួលខុសត្រូវយកចិត្តទុកដាក់ និងជួយអ្នកដទៃ ដែលមានសំណាងតិចជាងយើង ។ យើងគួរតែស្វែងយល់ និងដើរតាមគន្លងសីលធម៌របស់ព្រះពុទ្ធដែលទូន្មានថា មនុស្សត្រូវមានសីលធម៌ (សីល) ការប្រមូលអារម្មណ៍ (សមាធិ) និងមានគុណធម៌ (បាណា) ។

**គុណភាពទាបនៃជីវិត** មានន័យថា យើង និងគ្រួសាររបស់យើងមិនអាចទទួលបានតំរូវការជាមូលដ្ឋានគ្រប់គ្រាន់ក៏ដូចជាកង្វះខាតផ្នែកសញ្ចេតនា និងស្មារតីផងដែរ ។ ប្រការនេះជំរុញឱ្យយើងរស់នៅពុំមានសុខភាពបរិបូរ និងជួបជីវិតទុរគត ។ ជាធម្មតា ការរស់នៅរបៀបនេះនឹងនាំឱ្យមនុស្សប្រព្រឹត្តអំពើមិនបរិសុទ្ធដូចជា ការលោភលន់ (លោភៈ) ការស្អប់ (ទោសៈ) និងការភ័ន្តវង្វេង (មោហៈ) ។

បរិស្ថានមួយល្អ ត្រូវតែឆ្លើយតបទៅនឹងតំរូវការចាំបាច់ជាមូលដ្ឋានដូចខាងក្រោម :

- គេហដ្ឋានដែលយើងកំពុងរស់នៅ ត្រូវតែស្អាតជានិច្ច ។
- ចំណីអាហារគ្រប់គ្រាន់ ហើយត្រូវរក្សាទុកគ្របឬដាក់ឱ្យបានល្អ ។
- មុនចូលដំណេកយើងត្រូវដាក់មុង ឬប្រើប្រាស់បន្ទប់ដែលមានសំណាញ់ ។ មូសជាប្រភពនៃជំងឺឆ្លងដ៏មានគ្រោះថ្នាក់ដូចជា ជំងឺគ្រុនចាញ់ គ្រុនឈាម ។ល។
- មានសំលៀកបំពាក់ សំភារៈប្រើប្រាស់សមរម្យ ។
- យើងត្រូវតែសំអាតទីធ្លាលំនៅដ្ឋាន សួនច្បារ និងប្រមូលសំរាមដាក់ទៅក្នុងធុងសំរាម ។ សួនច្បារដែលមានដើមឈើ ដើមផ្កា និងស្មៅបង្កើតឱ្យមានបរិយាកាសរីករាយសំរាប់សំរាកកំសាន្ត និងភាព

សុខសាន្ត ។

• ដំណើរកំសាន្តក្នុងព្រៃក៏ជាវិធីមួយសំរាប់បង្កសេចក្ដីរីករាយដល់គុណភាពនៃជីវិតដែរ ។

## ខ. ទឹក ចំណីអាហារ និងសុខភាព

ទឹកដែលមានអនាម័យ ជាកត្តាសំរាប់ទ្រទ្រង់ជីវិតរបស់មនុស្ស សត្វ និងរុក្ខជាតិ ។ ជាការប្រសើរ យើងត្រូវតែទទួលទានទឹកដែលមានអនាម័យ ឬទឹកឆ្អិន ។ យើងត្រូវសំអាតខ្លួនជាមួយនឹងទឹកស្អាត ដើម្បីជៀសវាងជំងឺឆ្លងផ្សេងៗ ។ ការប្រើប្រាស់ទឹកបឹង ឬត្រពាំងដែលកខ្វក់នឹងនាំឱ្យកើតជំងឺសើស្បែកផ្សេងៗ ។ កុមារត្រូវការទទួលទានចំណីអាហារដែលមានជីវជាតិគ្រប់គ្រាន់ដូចជា បន្លែ ផ្លែឈើស្រស់ ត្រីសាច់ គ្រាប់ធញ្ញជាតិ ។ល។ ដើម្បីទទួលបានសុខភាពល្អ និងការលូតលាស់ ។ ការទទួលទានអាហារត្រូវឱ្យបានទៀងទាត់ពេល និងចំពារអាហារឱ្យបានម៉ត់ល្អ ដោយជៀសវាងការប្រញាប់ប្រញាល់ ។ កុមារត្រូវហាត់ប្រាណជាប្រចាំ ដើម្បីឱ្យរាងកាយរឹងមាំល្អ និងមានប្រាជ្ញាឈ្លាសវៃ ។



## គ. មាគ៌ាសីលធម៌ និងគុណភាពនៃជីវិត "សីលធម៌បរិស្ថាន "

ព្រះពុទ្ធបានទូន្មានថា សីលធម៌ និងគុណភាពនៃជីវិតរបស់យើងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធបំផុត ។ នៅពេលដែលយើងកែលំអខ្លួនឯង ហើយយើងចាប់ផ្ដើមធ្វើឱ្យបរិស្ថានមួយមានសុខុមាលភាព ពោលគឺទាំងផ្នែកសរីរៈ សញ្ចេតនា និងសីលធម៌ នោះមានន័យថា យើងនឹងចូលរួមចំណែកធ្វើឱ្យបរិស្ថានធម្មជាតិ និងសង្គម-វប្បធម៌ មានគុណភាពកាន់តែល្អប្រសើរឡើងដែរ ។

ដំណើរការខាងលើនេះអាចប្រព្រឹត្តទៅបានដោយជោគជ័យ និងមានប្រសិទ្ធភាព ដរាបណាមានការចូលរួមពីប្រជារាស្ត្រគ្រប់លំដាប់ថ្នាក់ ។ យើងអាចជួយបង្កើតសកម្មភាពគំរូល្អៗ សំរាប់បង្ហាញនៅក្នុងថ្នាក់រៀនរបស់យើងដល់អ្នកជិតខាង អ្នកភូមិស្រុក និងអ្នកទីក្រុង ។

នៅពេលដែលយើង និងអ្នកដទៃប្រតិបត្តិតាមមាគ៌ាមួយត្រឹមត្រូវ ឬផ្លូវកណ្ដាលរបស់ព្រះពុទ្ធនោះ យើងនឹងអាចបណ្ដុះបានឥរិយាបថនៃការយកចិត្តទុកដាក់ថែរក្សាបរិស្ថាន (មនុស្ស ធម្មជាតិ និងសង្គម-វប្បធម៌) ។ អាស្រ័យហេតុនេះយើងពិតជាបានជួយបង្កើត "សីលធម៌បរិស្ថាន " មួយដែលជាលទ្ធផលគុណភាពនៃជីវិតដ៏ឧត្ដុង្គឧត្ដមសំរាប់ប្រទេសជាតិយើង ។

◇ *សួរនិងពិភាក្សាជាមួយសិស្ស តើគេអាចធ្វើយ៉ាងដូចម្ដេចដើម្បីកែលំអគុណភាពនៃជីវិតរបស់គេ និងអ្នកដទៃ ។*

(ឧទាហរណ៍ :
- បរិភោគចំណីអាហារដែលធ្វើឱ្យមានសុខភាពល្អ (បន្លែ និងផ្លែឈើស្រស់) ។
- មេត្តាដល់ភាវៈមានជីវិត និងប្រើប្រាស់ភាវៈទាំងអស់ដោយសមហេតុផល ។
- ផ្សព្វផ្សាយចំណេះដឹងអំពីបរិស្ថានដែលបានរៀនពីសាលារៀនដល់ឪពុកម្ដាយ បងប្អូន និងញាតិមិត្ត ។
- អនុវត្តត្រឹមត្រូវតាមក្បួនអនាម័យ (សំអាតខ្លួនប្រាណជានិច្ច សំលៀកបំពាក់ស្អាត ផឹកទឹកដាំពុះ កុំបរិភោគម្ហូបឆ្អួម ប្រើមុងនៅពេលគេង) ។
- គោរពឪពុកម្ដាយ ជួយការងារបងប្អូន ញាតិមិត្តនៅជុំវិញផ្ទះ ។
- ដាំ និងថែរក្សាកូនឈើនៅជុំវិញផ្ទះ សាលារៀន និងវត្តអារាម ។
- ធ្វើការហាត់ប្រាណ ដោយលេងកីឡាមានការហែលទឹកជាដើម ។
- អនុវត្តគោលការណ៍សីលធម៌ ជាពិសេសសីលទាំងប្រាំ ឬក៏សុំដំបូន្មានពីចៅអធិការវត្ត ។
- រៀនចំណេះដឹងបរិស្ថានបន្ថែមគ្រប់ពេលវេលា និងគ្រប់ទីកន្លែងដែលអាចធ្វើទៅបាន ។
- រើសក្រដាស ឬសំរាមដែលនៅរាយប៉ាយតាមផ្លូវ ក្នុងផ្ទះ សាលារៀន និងវត្តអារាម ។
- ........................................................................

**សង្ខេបមេរៀន :**

គុណភាពនៃជីវិត ជារបៀប ឬដំណើររស់នៅមួយរបស់មនុស្សម្នាក់ គ្រួសារ និងសហគមន៍ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបរិស្ថានជុំវិញ ។ គុណភាពនៃជីវិតអាចប្រែប្រួលដោយពាក់ព័ន្ធទៅនឹងផ្នែក២សំខាន់គឺ : ផ្នែក ស្មារតី និងសំភារៈ ។ ដើម្បីសំរេចបានគុណភាពនៃជីវិត មនុស្សម្នាក់ៗត្រូវប្រតិបត្តិតាមមាគ៌ាមួយត្រឹមត្រូវ ឬផ្លូវកណ្តាល របស់ព្រះពុទ្ធដែលនឹងបណ្តុះបានឥរិយាបថនៃការគោរព យកចិត្តទុកដាក់ ថែរក្សា ការពារបរិស្ថានដែលជាប្រភពផ្តល់ "ផ្នែកសំភារៈ" ។ ទីបំផុត យើងពិតជាបង្កើតបាន "សីលធម៌បរិស្ថាន" មួយដែលជាលទ្ធផលគុណភាពនៃជីវិតដ៏ឧត្តុង្គឧត្តមសំរាប់ប្រទេសជាតិទាំងមូល ។

ម៉ូឌុលទី
១០

# តើរកផ្លូវសុខមង្គលដោយវិធីណា

**រឿងនិទាន** **កំរិតទី១ ទី២ និងទី៣**

**បញ្ជ្រាបតាមរយៈ** : ភាសាខ្មែរ សិក្សាសង្គម និងវិទ្យាសាស្ត្រអនុវត្ត ។

**បញ្ញត្តិ** : កត្តារួមផ្សំបង្កើតឱ្យមានគុណភាពនៃជីវិត មាន ទឹកស្អាត ខ្យល់បរិសុទ្ធ ចំណីអាហារគ្រប់គ្រាន់ ជំរក សីលធម៌រស់នៅ ... ។

**វត្ថុបំណង** : សិស្សចេះប្រៀបធៀបរវាងការរស់នៅស្អាត មានអនាម័យ និងគ្មានអនាម័យតាមរយៈរឿងនិទាន ។

**លទ្ធផល** : សិស្សចូលរួមយ៉ាងសកម្មក្នុងការសំអាតផ្ទះសំបែង ថ្នាក់រៀន សាលារៀន ។

**សំភារៈឧបទេស** : រូបភាពក្នុងសៀវភៅភាសាខ្មែរថ្នាក់ទី២ (ទំព័រ១៤៦ ១៤៧ ១៤៩ និង ១៥១) និងសិក្សាសង្គមថ្នាក់ទី២ (ទំព័រ ២៩ ៣០ ៣៣ ៣៧) ។

**សេចក្តីណែនាំ** : ក្នុងសកម្មភាពនេះ អ្នកគ្រូ-លោកគ្រូនិទានរឿងឱ្យសិស្សស្តាប់ ។ បើមានលទ្ធភាពឱ្យសិស្សអាន និងសំដែងតួទៅតាមសាច់រឿង ។ ទីបញ្ចប់អ្នកគ្រូ-លោកគ្រូចោទជាសំនួរទៅសិស្សដូចខាងក្រោម ។

## អត្ថបទរឿងនិទាន

*"គ្រួសារសុខសាន្ត និងអំពល់មានផ្ទះនៅឯជនបទឆ្ងាយពីទីក្រុង ឈ្មោះភូមិសែនត្រជាក់ចិត្ត ។ ភូមិស្ថាន និងទីធ្លានៅជុំវិញផ្ទះស្អាតណាស់ គ្មានគំនរសំរាម គ្មានរុយ និងក្លិនស្អុយទេ ។ គ្មានស្បោង ឬថង់ប្លាស្ទិចរសាត់តាមខ្យល់ ឬស្បែកមាត់ស្រះទឹកសោះឡើយ ។ តើគ្រួសារក្នុងភូមិនេះបំបាត់មិនឱ្យមានសំរាមតាមរបៀបណា ?*

*អ្នកភូមិទាំងនោះមានចំណេះវិជ្ជា និងបទពិសោធគួរសមដែរ ក្នុងការរស់នៅជាកសិករ ចេះរៀបចំសំអាតភូមិ ធ្វើឱ្យទាក់ភ្នែកអ្នកដទៃ ។ ពួកគេមានសាមគ្គីគ្នាណាស់ ។ ពេលទំនេរពីការងារនាំគ្នាធ្វើពលកម្ម ដូចជា លើកផ្លូវ ជីកស្រះ ស្តារលូទឹក ឬប្រឡាយក្នុងភូមិ ។ មនុស្សម្នា ឬអ្នកទេសចរដែលបានធ្វើដំណើរឆ្លងកាត់ទីនេះ តែងតែសរសើរមិនដាច់ពីមាត់ថា ពិតជាភូមិត្រជាក់ចិត្តមែន ។*

*ទោះជាយ៉ាងណាក៏ដោយ មានគ្រួសារពីរដែលមានការរស់នៅខុសគ្នាដែរ ។ គ្រួសារសុខសាន្តចេះសំអាតទីធ្លាបរិវេណផ្ទះ ។ ស្លឹកឈើជ្រុះចេះបោសប្រមូលកប់ក្បែរគល់ចេក ។ ផ្ទៃដីរាបស្មើគ្មានទឹកដក់ពេលមានភ្លៀងម្តងៗ ។ បង្គន់ស្អាតជានិច្ច ។ អណ្តូងទឹក និងពាងទឹកសុទ្ធតែមានគំរបយ៉ាងជិត ។ ក្នុងផ្ទះ និងចង្ក្រានបាយមានធុងពីរ ។ ធុងមួយមានស្បោងប្លាស្ទិចទ្រាប់ពីក្នុងសំរាប់ដាក់សំរាមសើម ដូចជា សំបកស្វាយ បន្លែរលួយ ស្រកា/ ឆ្អឹងត្រីជាដើម ។ ពេលដែលសំរាមពេញ ចងថង់នោះឱ្យជិត រួចយកថង់ថ្មីមកប្តូរជំនួស ។*

*គ្រួសារនេះបានរៀបចំយ៉ាងល្អក្នុងការចិញ្ចឹមសត្វ និងការធ្វើដំណាំ ។ នៅពេលដែលយើងបានដើរចូល*

*ទៅ ធ្វើឱ្យយើងហាក់ដូចជាមានអារម្មណ៍ថា កំពុងស្ថិតនៅក្នុងសួនច្បារ និងសួនចិញ្ចឹមសត្វ ។ ដោយសារការយល់ដឹង និងការរៀបចំបែបនេះ សមាជិកគ្រួសារសុខសាន្តនេះមានចំណីអាហារគ្រប់គ្រាន់ ជំរកសមរម្យ ខ្យល់អាកាសបរិសុទ្ធ ទឹកស្អាត ធ្វើឱ្យគ្រួសារមានជាសុខភាព ។*

*យើងក្រឡេកមើលទៅគ្រួសាររបស់អំពល់វិញម្តង ។ គ្រួសារនេះមិនបានសំអាតលំនៅដ្ឋានដូចគ្រួសារដទៃទៀតឡើយ ។ ខាងមុខផ្ទះ ខាងក្រោយផ្ទះសុទ្ធតែសំរាម និងស្មៅ ។ ក្បែរផ្ទះបាយ និងអណ្តូងទឹកសំបូរដោយភក់ជ្រាំ ។ សំបកកំប៉ុង និងសំបកកង់ចាស់ៗទុកគរចោល ធ្វើឱ្យមានទឹកដក់ ហើយសំបូរទៅដោយរុយមូស និងកណ្តុរ ។ កូនរបស់គាត់មានជំងឺជាប្រចាំ ។ គ្រួសារនេះមានចំណេះដឹងតិចតួច ពុំសូវចាប់អារម្មណ៍ទៅលើអ្នកជិតខាងដែលមានបទពិសោធក្នុងការរស់នៅ ។"*

**សំនួរ**

**កិច្ចការទី១**

១. តើភូមិដែលគ្រួសារសុខសាន្តរស់នៅឈ្មោះភូមិអ្វី ?

២. ហេតុអ្វីបានជាគេដាក់ឈ្មោះភូមិនោះជាភូមិត្រជាក់ចិត្ត ?

៣. តើផ្ទះនីមួយៗគេបានរៀបចំយ៉ាងណាខ្លះ ?

៤. តើគ្រួសារនីមួយៗគេបំបាត់មិនឱ្យមានសំរាមតាមរបៀបណាខ្លះ ?

៥. ហេតុអ្វីបានជាក្រុមគ្រួសារអំពល់មានជំងឺជាប្រចាំ ?

៦. តើអ្នកគួរយកគំរាប់តាមគ្រួសារសុខសាន្ត ឬគ្រួសារអំពល់ ក្នុងការកែប្រែជីវិតរស់នៅ ? ហេតុអ្វី ?

៧. តើអ្នកពេញចិត្តនឹងភូមិត្រជាក់ចិត្តនេះទេ ? ហេតុអ្វី ?

៨. តើអ្នកនឹងត្រូវរៀបចំយ៉ាងណាចំពោះលំនៅដ្ឋានរបស់អ្នក ?

**កិច្ចការទី២**

១. រំលឹកឡើងវិញគ្រួសារសុខសាន្ត និងគ្រួសារអំពល់ ហើយប្រៀបធៀបការយល់ដឹងនៃគ្រួសារទាំងពីរនេះ ។

២. អ្នកគិតមើល តើមានហេតុផលអ្វីខ្លះដែលធ្វើឱ្យគ្រួសារអំពល់ជួបវិបត្តច្រើនជាងគេ ?

៣. ប្រសិនបើគ្រួសារទាំងអស់នៅក្នុងភូមិមានលក្ខណៈដូចគ្រួសារអំពល់ តើមានអ្វីកើតឡើង ?

៤. ហេតុអ្វីចាំបាច់ត្រូវតែសំអាតលំនៅដ្ឋាន ?

៥. លំនៅដ្ឋានស្អាត (មានអនាម័យ) មានខ្យល់បរិសុទ្ធ មានទឹកស្អាត ចំណីអាហារគ្រប់គ្រាន់ តើវានឹងនាំអ្វីដល់គ្រួសារអ្នក ?

៦. តើអ្នកត្រូវរៀបចំអ្វីខ្លះចំពោះការរស់នៅរបស់អ្នកឱ្យដូចគ្រួសារសុខសាន្ត ?

**កិច្ចទី៣**

១ ហេតុអ្វីបានជាក្រុមគ្រួសារអំពល់កើតជំងឺមិនដាច់ ?

២. ហេតុអ្វីបានជាក្រុមគ្រួសារសុខសាន្តមិនកើតជំងឺដូចគ្រួសារអំពល់ ?

៣. តើគុណភាពនៃការរស់នៅទាក់ទងទៅនឹងការសំអាត ឬមិនសំអាតឬទេ ?

៤. ចូរប្អូនប៉ាន់ស្មាន តើនឹងមានអ្វីកើតឡើងបន្តទៀតចំពោះគ្រួសារអំពល់ ប្រសិនបើគ្រួសារនេះមិនអើពើសំអាតបរិស្ថានជុំវិញផ្ទះ ?

៥. ផ្អែកលើគ្រួសារអំពល់ជាភស្តុតាង តើវានឹងមានឥទ្ធិពលអាក្រក់ណាខ្លះកើតឡើងចំពោះគ្រួសារអ្នក បើអ្នកមិនយកចិត្តទុកដាក់អំពីបរិស្ថាន ?

៦. ក្នុងការរៀបចំគុណភាពនៃជីវិត តើអ្នកអាចធ្វើដូចគ្រួសារសុខសាន្តបានឬទេ ?

៧. អ្នកបានដឹងហើយថា ការខ្វះចំណេះវិជ្ជា និងភាពមិនយកចិត្តទុកដាក់ដល់បរិស្ថានធ្វើឱ្យគុណភាពនៃជីវិតមានកំរិតទាប ។ តើមានមធ្យោបាយណាជួយកាត់បន្ថយកុំឱ្យមានភាពក្រីក្រកើតឡើងដល់ប្រជាពលរដ្ឋយើង ?

✍
មុខងារទី
១០

# ការធ្លាក់ខ្លួនរបស់ពួកប្រមាញ់មួយក្រុម

**រឿងនិទាន** **ក្រិតទី១ ទី២ និងទី៣**

**បញ្ញាបទាធរយៈ** : សិក្សាសង្គម វិទ្យាសាស្ត្រអនុវត្ត និងភាសាខ្មែរ ។

**បញ្ញត្តិ** : សីលធម៌ និងគុណភាពនៃជីវិតរបស់យើងតែងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជានិច្ច ។

**វត្ថុបំណង** : សិស្សយល់ថា សីលធម៌បរិស្ថានជាមាគ៌ាមួយដ៏ប្រពៃ ដែលមនុស្សទាំងអស់ត្រូវប្រកាន់យកដើម្បីធានាគុណភាពនៃជីវិតដ៏ឧត្ដុង្គឧត្ដមសំរាប់ពលរដ្ឋម្នាក់ៗ ក៏ដូចជាប្រទេសជាតិដែរ ។

**លទ្ធផល** : សិស្សប្រកាន់ខ្ជាប់នូវឥរិយាបថវិជ្ជមានតាមរយៈការកែលំអខ្លួនឯង និងចូលរួមធ្វើឱ្យបរិស្ថានមានគុណភាពកាន់តែល្អប្រសើរឡើង ។

**សំភារៈឧបទេស** : រូបភាពសត្វព្រៃ (មើលរូបភាពម៉ូឌុលទី៦) ។

**សេចក្ដីណែនាំ** : នៅក្នុងសកម្មភាពនេះ អ្នកគ្រូ-លោកគ្រូនិទានរឿងឱ្យសិស្សស្ដាប់ជាមុនសិន ។ បន្ទាប់មក ឱ្យសិស្សសង្ខេបរឿងនិទាននេះឡើងវិញ ។ បើមានលទ្ធភាព ឱ្យសិស្សអានរឿងនិទាន ហើយឱ្យសិស្សឯទៀតដើរតួតាមសាច់រឿង ។ ទីបញ្ចប់ អ្នកគ្រូ-លោកគ្រូចោទសំនួរដូចមានខាងក្រោម ។

**អត្ថបទរឿងនិទាន :**

*"កាលពីព្រេងនាយ មានពួកប្រមាញ់មួយក្រុម រស់នៅក្នុងស្រទាប់ប្រជាជន លបប្រព្រឹត្តបរបាញ់សត្វព្រៃលក់ ឬសំលាប់តាមវិធីទាក់ បំពុល ធ្វើជាអាជីវកម្មប្រចាំថ្ងៃ ។ ថ្ងៃមួយពួកអ្នកប្រមាញ់បានចាប់សត្វខ្ទីងរាប់សិបក្បាល និងបក្សីច្រើនប្រភេទទៀត មានក្ងាន មេ និងទា ។ លុះដើរមកដល់មាត់ច្រកព្រៃបំរុងដើរចូលភូមិវិញ ស្រាប់តែជួបព្រឹទ្ធាចារ្យមួយរូប គាត់បានណែនាំពីសេចក្ដីល្អ ការប្រព្រឹត្តិនូវធម៌ មេត្តា ករុណា និងជំហ្វូនទានរបស់សង្គម ។ ពួកប្រមាញ់ក្នុងសហគមន៍មុំនោះក៏ជ្រះថ្លា ស្គាល់កំហុស ហើយក៏យកសត្វដែលនៅរស់ទាំងនោះទៅលែងក្នុងព្រៃវិញ ។ ចាប់ពីពេលនោះមក គេក៏លែងឃើញពួកប្រមាញ់ទាំងនេះទៀត ។ ឯពពួកបក្សីក៏សំបូរក្នុងព្រៃក្បែរភូមិស្រុកនោះ ហើយហើរបង្ហាញខ្លួនគួរពេចពិលរមិលមើល ។"*

## សំនួរ

ក. ចូរអ្នកឆ្លើយនឹងសំនួរខាងក្រោមនេះ :

១- តើក្នុងរឿងនេះ មានតួអង្គអ្វីខ្លះ ?
២- តើមានវិធីអ្វីខ្លះដែលពួកប្រមាញ់ប្រើសំរាប់ចាប់សត្វព្រៃ ?
៣- ហេតុអ្វីបានជាពួកប្រមាញ់ព្រមលះបង់អំពើបំផ្លាញសត្វព្រៃរបស់ខ្លួន ?
៤- តើមានទិដ្ឋភាពថ្មីអ្វីកើតឡើងក្រោយពីអវត្តមានពួកប្រមាញ់ ?
៥- តើអ្នកនិពន្ធចង់បង្ហាញគំនិតអ្វីខ្លះតាមរយៈអត្ថបទរឿងនិទាន ?
៦- តើអ្នកមានមតិយ៉ាងណាខ្លះចំពោះអត្ថន័យរបស់រឿងនិទាននេះ ?

ខ. ចូរអ្នករៀបរាប់ហេតុការណ៍ជាក់លាក់តាមលំដាប់នៅក្នុងរឿង :

១- ថ្ងៃមួយពួកអ្នកប្រមាញ់បានចាប់សត្វខ្លែកភាប់សិបក្បាល ។
២- ឯពួកបក្សីក៏សំបូរក្នុងព្រៃក្បែរភូមិស្រុកនោះ ។
៣- លុះដើរមកដល់មាត់ច្រកព្រៃ ស្រាប់តែជួបព្រឹទ្ធាចារ្យមួយរូប ។
៤- គាត់បានណែនាំពីសេចក្ដីល្អ ការប្រព្រឹត្តិនូវធម៌មេត្តា ករុណា ។
៥- ចាប់ពីពេលនោះមក គេក៏លែងឃើញពួកប្រមាញ់ទាំងនេះទៀត ។

ចំណុចទី
១០

# ប្រយោជន៍រួមធំជាងប្រយោជន៍ផ្ទាល់ខ្លួន

**សកម្មភាពក្នុងថ្នាក់** **កម្រិតទី៣**

**បញ្ញាបទាមសះ** : សិក្សាសង្គម វិទ្យាសាស្ត្រអនុវត្ត និងភាសាខ្មែរ ។

**បញ្ញត្តិ** : ព្រះពុទ្ធបានទូន្មានមនុស្សឱ្យប្រព្រឹត្តអំពើ មេត្តា ករុណា ឧបេក្ខា និងមុតិតា បើគ្មានធម៌ទាំង៤នេះទេ នឹងនាំឱ្យមនុស្សប្រព្រឹត្តអំពើមិនបរិសុទ្ធ ដូចជា ការលោភលន់ ការស្អប់ និងការភ័ន្តវង្វេង ។

**វត្ថុបំណង** : សិស្សមានស្មារតីទទួលខុសត្រូវ យកចិត្តទុកដាក់ជួយអ្នកដទៃ និងដើរតាមគន្លងធម៌របស់ព្រះពុទ្ធ ជាពិសេសការកាត់បន្ថយភាពលោភលន់ ។

**លទ្ធផល** : សិស្សយល់ថា ភាពលោភលន់នឹងនាំមនុស្សឱ្យលែងគិតគូរដល់ប្រយោជន៍ និងសេចក្តីសុខរបស់អ្នកដទៃ ។

**សំភារៈឧបទេស** : ប័ណ្ណ ឬក្រដាសរ៉ូណេអូកាត់ជា៨ចំណែក ប៊ិច ឬហ្វឺត ។

**សេចក្តីណែនាំ** : នៅក្នុងសកម្មភាពនេះ អ្នកគ្រូ-លោកគ្រូត្រូវរៀបចំប័ណ្ណសំរាប់សរសេរល្បះអំណះអំណាងដូចមានខាងក្រោម ។ ពេលចែកទៅសិស្ស សូមលុបលេខរៀងចេញ ។ ខាងក្រោមនេះជាបំនុចអនុវត្ត ។

**រូបប្រភេទទី១**

| | | |
|---|---|---|
| ①  ចិត្តបរិសុទ្ធ គិតគូរដល់ប្រយោជន៍ និងសេចក្តីសុខអ្នកដទៃ. | ② មិនកាប់ព្រៃឈើ ធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន. | ③ មានភ្លៀងគ្រប់គ្រាន់សំរាប់ធ្វើស្រែចំការ. |
| ④ មានចំណីអាហារគ្រប់គ្រាន់. | ⑤ សុខភាពមាំមួន ជីវិតរុងរឿង | ⑥ ជួយអ្នកដទៃ ដែលមានសំណាងតិចជាងយើង. |




១- អ្នកគ្រូ-លោកគ្រូបែងចែកសិស្សជាពីរក្រុម ក្រុមទី១ពិភាក្សាសំនួរ (ក) ក្រុមទី២ពិភាក្សាសំនួរ (ខ) ។

ក- ហេតុអ្វីបានជាគ្រួសារកសិករក្រីក្រមួយចំនួនចាកចោលលំនៅដ្ឋានពីជនបទមករស់នៅទីក្រុង ?

ខ- នៅទីក្រុង តើគ្រួសារក្រីក្រទាំងនោះជួបការលំបាកយ៉ាងណាខ្លះ ?

២- ក្រោយពីពិភាក្សាហើយឱ្យក្រុមនីមួយៗឡើងរាយការណ៍ ។

៣- គ្រូចែកសន្លឹកកិច្ចការទាំងពីរប្រភេទ (ដូចបានកំនត់ក្នុងសំភារៈឧបទេស) ឱ្យក្រុមទាំងពីរ (សូមមើលរូបសំរាប់សរសេរប័ណ្ណ) ។

៤- ណែនាំសិស្សឱ្យរៀបសន្លឹកកិច្ចការភ្ជាប់ទៅតាមប្រភេទនីមួយៗ (ប័ណ្ណទី១ ឬទី២) តាមលំដាប់ហេតុផល ។

៥- គ្រូចោទសំនួរឱ្យក្រុមទាំងពីរពិភាក្សាម្តងទៀត រួចឱ្យសិស្សឆ្លើយតាមការរៀបជាគំនិតធំទាំងពីរដូចខាងលើ :

- ចំពោះខ្លួនអ្នក តើប្រកាន់យកគំនិតមួយណា ?
- ហេតុអ្វីបានជាអ្នកប្រកាន់គំនិតបែបនេះ ?

**ទំនុកទី ១០**

# បណ្ដាំចំពោះកូនខ្មែរ

**សកម្មភាពក្នុង និងក្រៅថ្នាក់** **ការិតទី៣**

**បញ្ញាចង្អុលបង្ហាញ** : សិក្សាសង្គម វិទ្យាសាស្ត្រអនុវត្ត និងភាសាខ្មែរ ។

**បញ្ញត្តិ** : ជីវភាពរស់នៅល្អ មានគុណភាពអាស្រ័យលើសកម្មភាពត្រឹមត្រូវ និងសីលធម៌ល្អ សំដៅការគាំទ្រ ថែរក្សា និងការពារបរិស្ថាន ។

**វត្ថុបំណង** : សិស្សយល់ថា គុណភាពនៃជីវិតនឹងទទួលបានផលល្អ លុះណាតែបរិស្ថានធានាបាន តុល្យភាព និងនិរន្តរភាពសំរាប់មនុស្សជំនាន់យើង និងជំនាន់ក្រោយ ។

**លទ្ធផល** : សិស្សប្រកាន់ឥរិយាបថល្អ គាំទ្របរិស្ថាន និងចូលរួមថែរក្សា ការពារបរិស្ថានក្នុងសហគមន៍របស់ខ្លួន និងប្រទេសជាតិ ។

**សំភារៈឧបទេស** : រូបភាពសត្វព្រៃ ព្រៃឈើ និងប្រាង្គប្រាសាទបូរាណ ។

**សេចក្ដីណែនាំ** : ♦ សំរាប់សកម្មភាពក្នុងថ្នាក់ អ្នកគ្រូ-លោកគ្រូត្រូវចំលងអត្ថបទកំណាព្យលើក្ដារខៀនជាមុនសិន ។ បើមានវាំងនន បិទវាំងននសិន ។ នៅពេលបង្រៀនសឹមបើកវាំងនន ។

ការបង្រៀនត្រូវបែងចែកជា២វគ្គ ដូចការបង្រៀនមេសូត្ររត់មាត់ដែរ គឺ :

- វគ្គទី១ :
  - ពន្យល់ន័យពាក្យពិបាក
  - លើកសំនួរដើម្បីយល់អត្ថន័យ
- វគ្គទី២ :
  - គ្រូអានអត្ថបទដោយសូត្រតាម "បទពាក្យ៧" ឱ្យសិស្សស្ដាប់១ដង ឬ២ដង ។
  - ឱ្យសិស្សអានតៗគ្នាក្នុងម្នាក់២ឃ្លាៈឱ្យបានយ៉ាងតិច៣ចប់ ។
  - គ្រូចាប់ផ្ដើមលុបពាក្យចុងចួននៅចុងឃ្លាបន្ទាប់ ។ រួចមកលុបពាក្យដទៃទៀត រហូតទាល់តែអស់អត្ថបទទាំងមូល ។
  - ឱ្យសិស្សសូត្រអត្ថបទឡើងវិញតាមការចងចាំ ។

♦ សំរាប់សកម្មភាពក្រៅថ្នាក់ (លំហាត់នៅផ្ទះ) ឱ្យសិស្សចំលងអត្ថបទកំណាព្យនេះដាក់ក្នុងសៀវភៅលំហាត់ ហើយឱ្យសិស្សធ្វើលំហាត់នៅផ្ទះ ដោយសូត្រ និងពិភាក្សាអំពីអត្ថន័យនៃកំណាព្យជាមួយបងប្អូន ឪពុកម្ដាយ ឬញាតិមិត្តជិតខាង ។ ពេលមកដល់ថ្នាក់រៀនវិញ ឱ្យសិស្សរាយការណ៍ជូនមិត្តរួមថ្នាក់អំពីលទ្ធផលដែលគេទទួលបានពីមិត្តភក្តិ បងប្អូន ឪពុកម្ដាយរបស់គេ ។

## "បណ្តាំចំពោះកូនខ្មែរ"

(បទពាក្យ ៧)

១- មាតុភូមិកម្ពុជាត្រាយូរលង់ កេរឈ្មោះឧត្តុង្គល្បីក្នុងលោក
ស្នាដៃកូនខ្មែរធ្លាប់ជ័យជោគ តាំងពីមុនមកគួរស្ញប់ស្ញែង ។

២- ប្រាសាទអង្គររំលេចក្បាច់ ត្រកាលល្អផ្តាច់គួរកោតក្រែង
ចម្លាក់ឆ្មៀលឆ្ងល់គ្រប់កន្លែង ទីតាំងខេងវេងកណ្តាលព្រៃ ។

៣- ចរិតប្រវត្តិដ៏អស្ចារ្យ លើផ្ទាំងសិលាពាសពេញផ្ទៃ
បង្ហាញឃើញច្បាស់អស្ចារ្យក្រៃ កម្ពុជាថ្លាថ្លៃមហានគរ ។

៤- ឥឡូវមិនគួរខ្វាំងចង្រៃ សាហាវព្រៃផ្សៃនាំវិករ
កុំទេចបំផ្លាញខឿនវប្បធម៌ ឱ្យជាតិធ្លាក់ក្រវិនាសខ្ចាត់ ។

៥- បឹងបួរស្ទឹងព្រែកទន្លេឆ្ងាយ សមុទ្រអន្ទាយ ខៀវស្រងាត់
បាត់បង់មច្ឆាជាតិសព្វសត្វ ព្រៃល្បាតប្រែជារហោឋាន ។

៦- ម្រឹគម្រឹគាទាសំបូរ ធ្លាប់ចូររំពងពេញសួសាន
មិនគួរប្រាត់ប្រាស់ស្លាត់សូន្យបាន ប្រែប្រាណក្រលាស់គួរអនិច្ចា ។

៧- ហៃឱកូនខ្មែរទាំងឡាយអើយ កុំនៅកន្តើយខំសិក្សា
រៀនតដំណែលតាមដូនតា ជួយដាំរុក្ខាជួយការពារ ។

៨- សម្បត្តិធម្មជាតិដែលសល់ខាន រុញច្រាននាំគ្នាខំរក្សា
ឱ្យបានគង់វង្ស និងរីកនា នោះទើបផានាភាពសុខក្រៃ ។

៩- ជួយខំទប់ស្កាត់អំណើបាប ចោរខ្វាំងបានសាបមកលើផ្ទៃ
បំផ្លាញជាតិឯងគ្មានសំចៃ កែថ្ងៃឱ្យមកស្គាល់ត្រូវខុស ។

១០- គឺការវៀរចាកសំលាប់សត្វ ខិតខំកំចាត់អំពើជ្រួស
ពុករលួយតណ្ហាស្រវឹងហួស និងការគិតគោះចង់តែបាន ។

១១- វប្បធម៌រលំជាតិរលាយ កុំគិតងាយៗថាស្មានៗ
ស្លាប់ហើយមិនងាយកើតវិញបាន ដូចព្រៃសួសានដែលបាត់បង់ ។

១២- ហៃឱកូនខ្មែរទាំងឡាយអើយ កូនកុំកន្តើយនៅបង្អង់
បណ្តុះសតិបញ្ញាខ្ពង់ តំរង់ឃ្មាតខ្មីដើរទៅមុខ ។

១៣- បរិស្ថានបវរជាតិរុងរឿង ប្រជាកុំខ្លើងប្រទេសសុខ
រកស៊ីមានបានគ្មានកើតទុក្ខ គ្រប់ស្រុកកោតក្រែងលែងមើលងាយ ។

## ក. សំនួរផ្ទៃរិះ

១- តើបរិស្ថានធម្មជាតិមានអ្វីខ្លះ ?

២- តើបរិស្ថានសង្គម-វប្បធម៌មានអ្វីខ្លះ ?

៣- ដើម្បីឱ្យជីវិតមានគុណភាព តើមនុស្សអាចផ្ដាច់ខ្លួនចេញពីបរិស្ថានធម្មជាតិ និងបរិស្ថានសង្គម-វប្បធម៌បានឬទេ ? ព្រោះអ្វី ?

៤- តើអ្នកមានវិធានការយ៉ាងដូចម្ដេចក្នុងការថែរក្សា និងការពារបរិស្ថាន ដើម្បីឱ្យមនុស្សជំនាន់ក្រោយទទួលបានជីវិតមានគុណភាព ?

៥- តើអ្នកនិពន្ធចង់បង្ហាញគំនិតអ្វីខ្លះដល់យើង ដើម្បីរក្សាបានជីវិតមានគុណភាព តាមរយៈអត្ថបទនៃកំណាព្យនេះ ?

៦- តើអ្នកមានអារម្មណ៍ ឬមតិយ៉ាងដូចម្ដេចចំពោះអត្ថន័យនៃកំណាព្យនេះ ?

**ខ. លំហាត់ :**

១- ចូរអ្នកពន្យល់ន័យរបស់ពាក្យដែលគូសបន្ទាត់ពីក្រោម នៅក្នុងអត្ថបទកំណាព្យខាងលើ ។

២- ចូរអ្នករកន័យដូចរបស់ពាក្យលំហាត់ខាងលើ ។

*កំណត់សំគាល់ : កំណាព្យនេះនិពន្ធដោយលោក ជួប កៅ ប្រធានមន្ទីរបរិស្ថានក្រុងកែប នាឱកាសសិក្ខាសាលាការអប់រំបរិស្ថានកំរិតបឋមសិក្សា តាមរយៈកំរងសាលាភូមិភាគក្រុងព្រះសីហនុ : ២៤ដល់ ២៧ មិថុនា ១៩៩៧*

✍
ម៉ូឌុលទី
១០

# ស្រណោះស្រុកខ្មែរ

**សកម្មភាពក្នុង និងក្រៅថ្នាក់** **កិច្ចទី៣**

**បញ្ញាបតាមឈរៈ** : សិក្សាសង្គម វិទ្យាសាស្ត្រអនុវត្ត និងភាសាខ្មែរ ។

**បញ្ញត្តិ** : សីលធម៌រស់នៅ និងគុណភាពនៃជីវិតរបស់យើងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធក្នុងការថែរក្សា និងការពារបរិស្ថានឱ្យមានភាពគង់វង្ស និងសុខុមាលភាព ។

**វត្ថុបំណង** : សិស្សយល់ថា ជីវិតមានគុណភាពទៅបាន លុះណាតែសកម្មភាពរបស់មនុស្សម្នាក់ៗ ប្រព្រឹត្តឡើងប្រកបដោយស្មារតីទទួលខុសត្រូវ និងភ្ញាក់រលឹកចំពោះផលវិបាកនានាដែលនឹងកើតឡើងដល់បរិស្ថាន ។

**លទ្ធផល** : សិស្សមានមោទនភាពចំពោះមាតុភូមិរបស់ខ្លួន និងមានឥរិយាបថចូលរួមថែរក្សាបរិស្ថានធម្មជាតិ និងសង្គម-វប្បធម៌ឱ្យមានគុណភាពកាន់តែប្រសើរឡើង ។

**សំភារៈឧបទេស** : ផែនទីសេដ្ឋកិច្ចប្រទេសកម្ពុជា (មើលម៉ូឌុលទី៨) ។

**សេចក្តីណែនាំ** :
- ♦ សំរាប់សកម្មភាពក្នុងថ្នាក់ អ្នកគ្រូ-លោកគ្រូត្រូវណែនាំសិស្សឱ្យចេះច្រៀងតាម "*លំនាំបទ ស្រណោះស្រុកខ្មែរ*" ជាមុនសិន ។ បន្ទាប់មក ឱ្យសិស្សច្រៀងម្នាក់ម្តងៗ រួចជាក្រុមៗ ។ ទីបញ្ចប់ អ្នកគ្រូ-លោកគ្រូចោទសំនួរដូចខាងក្រោម ។
- ♦ សំរាប់សកម្មភាពក្រៅថ្នាក់ (លំហាត់នៅផ្ទះ) ឱ្យសិស្សចំលងអត្ថបទចំរៀងនេះដាក់ក្នុងសៀវភៅលំហាត់ ហើយឱ្យសិស្សធ្វើលំហាត់នៅផ្ទះ ដោយច្រៀងចំរៀង និងពិភាក្សាពីអត្ថន័យនៃចំរៀងជាមួយបងប្អូន ឪពុកម្តាយ ឬញាតិមិត្តជិតខាង ។ ពេលមកដល់ថ្នាក់រៀនវិញ ឱ្យសិស្សរាយការណ៍ជូនមិត្តរួមថ្នាក់អំពីលទ្ធផលដែលគេទទួលបានពីមិត្តភក្តិ បងប្អូន ឪពុកម្តាយរបស់គេ ។

## អត្ថបទចំរៀង

### ស្រណោះស្រុកខ្មែរ
**(លំនាំបទ ស្រណោះស្រុកខ្មែរ)**

| | | |
|---|---|---|
| *I.* | *សូរិយាអើយរះហើយ* | *ឱ ! សូរិយារះហើយ* |
| | *ព្រលឹងកែវអើយ* | *ស្រណោះដីខ្មែរ* |
| | *ឱណាមានសព្វទ្រព្យធន* | *ឱ ! ណាមានសព្វទ្រព្យធន* |
| | *ជាតិខ្មែរអត់ធន* | *ខិតខំរកពុន គ្រប់ពេលវេលា ។* |

| | | |
|---|---|---|
| *II.* | *ដីខ្មែរអើយសំបូរ* | *ឱ ! ដីខ្មែរ អើយសំបូរ* |
| | *សម្បត្តិហៀរហូរ* | *ឥតមានខ្វះអ្វី* |
| | *ឱ ! ណាក្នុងទឹកមានត្រី* | *ឱណាលើដីមានឈើ* |
| | *ក្នុងព្រៃមានសត្វ សំបូរសម្បត្តិ* | *វប្បធម៌នានា ។* |
| *III.* | *មានទាំងអើយប្រាសាទ* | *ឱ ! មានទាំងអើយប្រាសាទ* |
| | *ព្រលឹងកែវអើយ* | *គឺប្រាសាទអង្គរ* |
| | *ឱ ! ណាល្អស្រស់* | *បវរ ឱណា !លើលោកគ្មានទេ* |
| | *ផ្ទះអើយស្វមខ្មែរ* | *ជួយថែរក្សាឱ្យបានគង់វង្ស ។* |

**សំនួរត្រិះរិះ :**

១- តើនៅប្រទេសកម្ពុជាមានធនធានធម្មជាតិ និងវប្បធម៌អ្វីខ្លះ ?

២- មានតែធនធានធម្មជាតិមួយមុខ តើអាចធានាបាន ជីវិតមានគុណភាពដែរឬទេ ?

៣- ចុះបើមានតែសម្បត្តិវប្បធម៌ តែខ្វះការគ្រប់គ្រងថែរក្សា និងការពារ តើយើងអាចសំរេចបានជីវិតមានគុណភាពឬទេ ?

៤- តើជាការពិតឬទេ បើគេនាំគ្នាលួចវត្ថុបូរាណទៅលក់ ឬទាញផលពីធនធានធម្មជាតិច្រើនហួសហេតុ ដើម្បីទទួលបានគុណភាពខ្ពស់នៃជីវិត ?

៥- តើអ្នកនិពន្ធចង់បង្ហាញគំនិតអ្វីខ្លះ បើតាមអត្ថបទនៃចំរៀងនេះ ?

៦- តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច ចំពោះអត្ថន័យនៃចំរៀងនេះ ?

*កំណត់សំគាល់ : ចំរៀងនេះនិពន្ធដោយលោក សាមឿន ម៉ោះ មកពីសាលាកំរងជ័យសែន ខេត្តព្រះវិហារ នាឱកាសសិក្ខាសាលាការអប់រំបរិស្ថានកំរិតបឋមសិក្សា តាមរយៈកំរងសាលាភូមិភាគសៀមរាប : ១៧ដល់ ២០ មិថុនា ១៩៩៧*

# វាក្យសព្ទ

**ក្លរ៉ូហ្វីល (Chlorophyll) :** ជាតិពណ៌បៃតងដែលជាកន្លែងសំខាន់ក្នុងការស្រូប ឬចាប់យកពន្លឺព្រះអាទិត្យនៅក្នុងដំណើរការរស្មីសំយោគ (សូមមើលរស្មីសំយោគ) ។

**កំណកអាកាស (Precipitation) :** បរិមាណទឹកដែលធ្លាក់ចុះក្រោមរូបភាពជាភ្លៀង ឬព្រិលនៅក្នុងតំបន់ណាមួយ ។

**ការចែកថ្នាក់ (Classification) :** ប្រព័ន្ធនៃការចែកជាក្រុម ជាពួកនៃភាវៈទាំងអស់ ។

**ការថែរក្សា (Conservation) :** ខ្លះថា "អភិរក្ស" ដែលមានន័យថា ការប្រើប្រាស់ដោយប្រយ័ត្នប្រយែងនូវធនធានដែលមានដើម្បីការពារគុណភាព និងចៀសវាងការខ្ជះខ្ជាយ ។

**ការផុតពូជ (Extinction) :** ការបាត់ពូជ ឬប្រភេទទាំងស្រុងរបស់សរីរាង្គណាមួយ ដូចជា ប្រភេទសត្វឌីណូសូជាដើម ។ នៅពេលដែលប្រភេទណាមួយផុតពូជ ក៏វាលែងមានអត្ថិភាពតទៅទៀតហើយ ។

**ការវិវត្ត (Evolution) :** លំនាំនៃការប្រែប្រួលផ្នែកជីវសាស្ត្របែ្លកៗ ដែលជាចុងក្រោយបង្កឱ្យមានជោគជ័យ (ការសំរបខ្លួន) ឬបរាជ័យ (ការផុតពូជ) របស់ប្រភេទសត្វ និងរុក្ខជាតិ ការផលិតប្រភេទសត្វ និងរុក្ខជាតិថ្មីៗជាច្រើនទៀត ។ ការវិវត្តផ្នែកជីវសាស្ត្រនេះ នៅមានបន្តនៅឡើយនាពេលបច្ចុប្បន្ននេះ ។

**ការសន្និដ្ឋាន (Conclusion) :** ផ្នែកមួយក្នុងផ្នែកទាំង៤នៃពិសោធន៍ ។ ឯចំលើយ ឬដំណោះស្រាយពឹងផ្អែកលើការសង្កេតពិនិត្យ ។

**ការសំរបខ្លួន (Adaptation) :** លក្ខណៈដែលជួយសរីរាង្គឱ្យមានជីវិតគង់វង្សនៅក្នុងបរិស្ថានពិសេសមួយ ។

**កាឡូរី (Calorie) :** បរិមាណកំដៅដែលត្រូវការដើម្បីបង្កើនសីតុណ្ហភាព១អង្សាសេលសុស ក្នុងទឹកទំងន់ ១គ.ក ។

**កោសិកា (Cell) :** ផ្នែកតូចបំផុតរបស់ភាវៈរស់ដែលរកឃើញដោយជីវវិទូ ។ គ្រប់សរីរាង្គមានជីវិតទាំងអស់ សុទ្ធតែមានកោសិកា ។ សរីរាង្គខ្លះដូចជាពពួកប៉ារ៉ាស៊ីត និងអាមីប ឬមីក្រុបជាប្រភេទឯកកោសិកា ។

**ខ្លាញ់ (Fat) :** សារធាតុចិញ្ចឹមដែលសំបូរថាមពល និងអាចរក្សាទុកបានសំរាប់ប្រើប្រាស់ពេលក្រោយៗទៀត ។

**ខ្សែអាហារ (Food Chain) :** សំណុំសរីរាង្គដែលរស់ដោយសារស៊ីសរីរាង្គផ្សេងៗទៀត ។

**គុណធម៌ (Virtue) :** សេចក្តីល្អ សេចក្តីបរិសុទ្ធ សេចក្តីអាណិត ប្រណី ។

**គុណភាព (Quality) :** របស់ដែលមានអនុភាពស័ក្តិសិទ្ធិ ។

**គុណសម្បត្តិ (Qualification) :** ការបរិបូរដោយសេចក្តីល្អ សេចក្តីបរិសុទ្ធ ។

**គ្លុយកូស (Glucose) :** ស្ករដែលប្រើប្រាស់ជាអាហារដោយរុក្ខជាតិ និងសត្វ ។ គ្លុយកូសកើតឡើងពីរុក្ខជាតិបៃតងដោយសារជ្រៀតឆ្លាយការបោនឌីអុកស៊ីត និងចំហាយទឹក ពេលមានវត្តមានពន្លឺ

ព្រះអាទិត្យ ដែលជាប្រភពថាមពល ។ នៅក្នុងដំណើរការរស្មីសំយោគរុក្ខជាតិបែតងបញ្ចេញអុកស៊ីសែន ដែលជាអនុផលរបស់វា ។

**ចំហាយទឹក (Water Vapor) :** ទំរង់ឧស្ម័ននៃទឹក ។

**ជីវចំរុះ (Biodiversity) :** ទំហំនៃភាពសំបូរប្រភេទសត្វ និងរុក្ខជាតិដែលមានភាពខុសប្លែកគ្នា និងពូជនៅក្នុងប្រព័ន្ធណាមួយ ។

**ជីវម៉ាស (Biomass) :** ទំរង់នៃភាវៈមានជីវិតទាំងអស់នៅក្នុងតំបន់ណាមួយ ។

**ជំងឺ (Disease) :** លក្ខខ័ណ្ឌដែលមនុស្សធ្លាក់ខ្លួនឈឺ ព្រោះតែមុខងារនៃខ្លួនប្រាណមានភាពមិនស្រួល ឬអកម្មផ្នែកណាមួយ ។

**ជំរក (Habitat) :** បរិស្ថានរូបដែលពពួក ឬប្រភេទសត្វ និងរុក្ខជាតិរស់នៅជុំគ្នា ។

**ឈាមត្រជាក់ (Cold Blooded) :** លក្ខណៈរបស់សត្វដែលកំដៅខ្លួនរបស់វាប្រែប្រួលទៅតាមបរិស្ថានរស់នៅ ។

**ដីសើម (Wetland) :** តំបន់ដែលមានលក្ខណៈសើមជានិច្ច និងរងការលិចលង់នៅពេលទឹកឡើងជាទៀងទាត់ ជាពិសេសតំបន់វាលភក់នៅតាមដងស្ទឹង ទន្លេ ឬសមុទ្រ ។

**ដំណកដង្ហើម (Respiration) :** ដំណើរការដែលឧស្ម័នអុកស៊ីសែនធ្វើប្រតិកម្មគីមី ហើយបញ្ចេញឧស្ម័នកាបូនិច ។ ដំណើរការដែលអង្គកាយប្រើប្រាស់អាហារ និងអុកស៊ីសែនដើម្បីទទួលបានថាមពល ។

**ប្រព័ន្ធ (Ecosystem) :** សហគមន៍នៃសរីរាង្គគ្រប់ប្រភេទ ដោយរួមបន្ថែមទាំងគ្រប់ទិដ្ឋភាពនៃបរិស្ថានរូប និងគីមីរបស់សរីរាង្គនោះផង ។

**ថនិកសត្វ (Mammal) :** ប្រភេទសត្វឆ្អឹងកងដែលមានឈាមក្តៅ មានរោម និងបំបៅកូន ។

**ថាមពល (Energy) :** សមត្ថភាពដើម្បីធ្វើការងារអ្វីមួយ ។

**ថាមពលជីវម៉ាស (Biomass Energy) :** ថាមពលបានមកពីកសិផល (ដើមឈើ អំពៅ ពោត ...) តាមរយៈចំហេះផ្ទាល់ ឬឥន្ធនៈអន្តរការីមានដូចជា អាល់កុលជាដើម ។

**ធនធាន (Resource) :** អ្វីៗដែលមនុស្សត្រូវការដើម្បីរស់នៅ ។ អ្វីៗដែលមានប្រយោជន៍ ។

**ធនធានដែលមិនអាចកើតឡើងជាថ្មីបាន (Non-Renewable Resource) :** អ្វីៗដែលពុំអាចផ្លាស់ប្តូរកើតឡើងវិញ ឬជំនួសបានដោយធម្មជាតិ ដែលកាលណាប្រើអស់ហើយ គឺអស់តែម្តង ព្រោះវាមានកំរិត ។

**ធនធានដែលអាចកើតឡើងបានជាថ្មី (Re-newable Resource) :** អ្វីៗដែលអាចផ្លាស់ជំនួស ឬធ្វើឱ្យកើតឡើងវិញបានដោយធម្មជាតិ ឬអាចបំពេញបរិមាណដោយឯកឯង និងក្នុងលក្ខខណ្ឌដែលមនុស្សចេះប្រើឱ្យមានតុល្យភាព ឬនិរន្តរភាព ។

**ធាតុ (Element) :** សារធាតុដែលកើតឡើងទាំងស្រុងពីអាតូមប្រភេទដូចគ្នា ។ សារធាតុបែបនេះពុំអាចបំបែកឱ្យទៅជាសារធាតុយ៉ាងងាយដោយវិធីគីមីតទៅទៀតបានឡើយ ។ ឧទាហរណ៍ មាស អុកស៊ីសែន កាបោន និងក្លរីន ។

**ធាតុអាកាស (Weather) :** ការប្រែប្រួលនៃស្ថានភាពបរិយាកាសនៅក្នុងខណៈណាមួយ ពិសេសពីមួយថ្ងៃទៅមួយថ្ងៃ (សីតុណ្ហភាព សម្ពាធអាកាស សំណើម ...) ។

**និរន្តរភាព (Sustainability) :** ភាពគិតមានចន្លោះ ភាពកើតមានជានិច្ចឥតឈប់ឈរ ។

**បរិស្ថាន (Environment) :** កត្តាសរុបនៃរូបនិយម គឺមី និងជីវសាស្ត្រដែលអាចមានឥទ្ធិពលទៅលើសរីរាង្គ ។

**ប្រព័ន្ធ (System) :** ក្រុមនៃសរីរៈធ្វើការរួមគ្នាដើម្បីធ្វើសកម្មភាពរស់នៅ ។

**ប្រភេទទទួលគ្រោះថ្នាក់ (Endangered Species) :** ប្រភេទសត្វ ឬរុក្ខជាតិដែលកំពុងថយបរិមាណយ៉ាងតិចបំផុត ហើយដែលអាចផុតពូជយ៉ាងងាយផង ។

**បាក់តេរី (Bacteria) :** ប្រភេទសរីរាង្គម្យ៉ាងមានកំណើតជាយូរលង់មកហើយ ដែលថាជារុក្ខជាតិក៏ពុំមែន ថាជាសត្វក៏ពុំមែន ។ វារស់នៅដោយសារសារធាតុចិញ្ចឹមដែលបានមកពីសរីរាង្គដទៃទៀត និងអនុផលរបស់វា ។ វាមាននៅតាមខ្យល់អាកាស ដែលអាចធ្វើឱ្យយើងរងជំងឺ ។ វាមាននៅក្នុង និងលើខ្លួនប្រាណយើង ។ វាអាចជួយរំលាយអាហាររបស់យើង និងជួយកំចាត់វត្ថុសំណល់ចេញពីខ្លួនយើង ។

**បាតុភូតផ្ទះកញ្ចក់ (Green house Effect) :** ការកើនកំដៅនៃផែនដី ដែលជាផលបានមកពីឧស្ម័នផ្ទះកញ្ចក់ ។ ឧស្ម័នផ្ទះកញ្ចក់សំខាន់ជាងគេគឺ កាបោនឌីអុកស៊ីត ឬឧស្ម័នកាបូនិច ។ ឧស្ម័ននេះចាប់យករំភាយកំដៅដែលភាយចេញពីស្រទាប់ផែនដី និងរារាំងរំភាយកំដៅមិនឱ្យទៅកាន់លំហអាកាសបាន ។

**ភ្លៀងអាស៊ីត (Acid Rain) :** ទឹកភ្លៀងដែលមានផ្ទុកបរិមាណអាស៊ីតខ្ពស់មកពីតំបន់ប្រើប្រាស់ចំហេះឥន្ធនៈ ធ្យូងថ្មជាសារធាតុគ្រោះថ្នាក់បំផុត ។ ភ្លៀងអាស៊ីតអាចបណ្ដាលឱ្យរុក្ខជាតិមិនលូតលាស់ ហើយពេលហូរចូលស្ទឹង ទន្លេ បណ្ដាលឱ្យបាត់បង់ភាវៈមានជីវិតទាំងអស់ដែលរស់នៅក្នុងទឹកនោះ ។

**ចំណាសី (Carnivores) :** សត្វស៊ីសាច់ជាអាហារ ។

**រស្មីសំយោគ (Photosynthesis) :** ដំណើរការដែលរុក្ខជាតិបៃតងបង្កើតម៉ូលេគុលស្ករចេញពីចំហាយទឹក និងកាបូនិចពីបរិយាកាសដោយមានវត្តមានពន្លឺព្រះអាទិត្យ និងសារធាតុពណ៌បៃតងក្លរ៉ូហ្វីល ។ នៅក្នុងដំណើរការនេះ អុកស៊ីសែនត្រូវបញ្ចេញចោល ដែលជាអនុផល ។ រុក្ខជាតិបៃតងផ្ដល់អាហារដល់សរីរាង្គភាគច្រើននៅក្នុងពិភពលោកនេះ ។

**រំភាយញើស (Transpiration) :** ការបាត់បង់ជាតិទឹកពីជាលិកាពងក្នុងរបស់រុក្ខជាតិតាមរយៈរន្ធញើស ភាគច្រើននៅលើស្លឹករុក្ខជាតិ ។

**វដ្តទឹក (Water cycle) :** ចលនារបស់ទឹកដែលផ្ដើមចេញពីទឹករំហួត ឆ្លងកាត់តាមរយៈបរិយាកាស កំណកអាកាសរសាត់លើផ្ទៃដី ឬក្នុងដី ហើយវិលត្រលប់មកកាន់ទីរំហួតដើមវិញ ។

**វប្បធម៌ (Culture) :** ទំនៀមទំលាប់ សំភារៈបរិក្ខារ បច្ចេកទេស ផលិតផល គំនិត ភាសា និងជំនឿរបស់មនុស្ស ។

**សង្គម (Society) :** ការប្រមូលផ្ដុំមនុស្ស ឬរបស់សង្គម កិច្ចការដែលធ្វើឡើងដើម្បីជួយយិតយោងសង្គមមនុស្សឱ្យបានសុខចំរើន ។

**សត្វ (Animal) :** សរីរាង្គពហុកោសិកា ដែលត្រូវការអាហារដើម្បីរស់ និងផ្លាស់ទីចុះឡើងក្នុងបរិស្ថាន ។

**សត្វល្មូន (Reptiles) :** ប្រភេទសត្វឆ្អឹងកង មានឈាមត្រជាក់ដូចជា ពស់ ថ្លែន និងក្រពើជាដើម ។

**សត្វស្លាប (Birds) :** ពពួកសត្វឆ្អឹងកងមានឈាមក្តៅ ដែលមានស្លាបគ្របដណ្តប់ខ្លួន និងក្រាបពង ។

**សមាធិ (Meditation) :** លក្ខណៈគ្រប់យ៉ាងដែលញ៉ាំងចិត្តឱ្យស្ងប់ ។

**សហគមន៍ (Community) :** សរីរាង្គទាំងអស់ដែលរស់នៅជុំគ្នា នៅក្នុងតំបន់មួយច្បាស់លាស់ ។

**សរីរាង្គ (Organism) :** ភាវៈរស់ទាំងមូល ឬទាំងស្រុង ។ នៅទីនេះសំដៅភាវៈមានជីវិតទាំងអស់ ។

**សារធាតុអសរីរាង្គ (Abiotic) :** ភាវៈគ្មានជីវិត ពោលគឺសំដៅសមាសភាគនៃភាវៈគ្មានជីវិតទាំងអស់របស់ប្រព័ន្ធ (ទឹក ពន្លឺ ជាដើម) ។

**សីល (Precept) :** ការកាន់ ឬប្រព្រឹត្តល្អដោយកាយវាចា ការវៀរចាកអំពើអាក្រក់ ឬមិនប្រព្រឹត្តគន្លងវិន័យ ឬច្បាប់ ។

**សីលធម៌ (Moral) :** ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អ ។

**សំណាញ់អាហារ (Food Web) :** ប្រព័ន្ធនៃការចិញ្ចឹមខ្លួនដ៏ស្មុគ្រស្មាញមួយដែលមានជាប់ជាមួយនឹងខ្សែអាហារជាច្រើន ។

**សំណឹកដី (Erosion) :** ឥទ្ធិពលយូរអង្វែងរបស់កំដៅ ទឹក ខ្យល់ ទឹកកក និងភ្លៀង ដែលធ្វើឱ្យសឹក ឬរលាយ ។ គ្រាប់ខ្សាច់ ឬគ្រាប់សំណឹកនេះហៅថា កករ ដែលអាចកកើតឡើងដោយសារដំណើរការគីមី ឬជីវគីមី ដោយរងនូវអំពើមេកានិច ។ សំណឹកដីអាចកើតមានឡើងនៅពេលដែលភ្លៀងហូរនាំយកស្រទាប់ដីឡើងទៅចាក់ចូលប្រឡាយ ឬស្ទឹង ទន្លេ ឬពេលដែលដីធូរត្រូវខ្យល់បំប៉ើងទៅឆ្ងាយ ។

**អាកាសធាតុ (Climate) :** ការប្រែប្រួលនៃស្ថានភាពបរិយាកាសនៅក្នុងអំលុងពេលណាមួយ ពិសេសពីរដូវមួយទៅរដូវមួយនៅក្នុងតំបន់ណាមួយ ។ អាកាសធាតុមានសីតុណ្ហភាព សំណើមកំណកអាកាស អត្រាវំហួត ពន្លឺថ្ងៃ និងខ្យល់ជាដើម ។

**អាសន្នរោគ (Cholera) :** ប្រភេទជំងឺពោះវៀន បង្កឡើងដោយបាក់តេរីម្យ៉ាង ។ ជំងឺនេះអាចឆ្លងរាលដាលដោយសារការបំពុលទឹក លាមកមនុស្ស ... ។

**អូសូន (Ozone) :** សមាសភាគបង្កើតឡើងអាតូមអុកស៊ីសែន៣ម៉ូលេគុល ($O_3$) ។ អុកស៊ីសែនដែលយើងត្រូវការដកដង្ហើមមានអាតូមតែ ២ប៉ុណ្ណោះ ($O_2$) ។

**អេកូឡូស៊ី (Ecology) :** ខ្វះនិយមហៅថា "បរិស្ថានវិទ្យា" ដែលមានន័យថា ជាស្បង់ដែលសិក្សាពីទំនាក់ទំនងរវាងភាវៈរស់ និងបរិស្ថានដែលភាវៈរស់ រស់នៅ ។

**អ្នកបំបែក (Decomposers) :** សរីរាង្គដែលដើរតួជាភ្នាក់ងាររកកាយ ឬកំទេចភាគច្រើនជាបាក់តេរី ឬផ្សិតដែលរស់បានដោយសារសាកសពសត្វ និងរុក្ខជាតិដែលងាប់ ។

**អ្នកប្រើប្រាស់ (Consumer) :** សរីរាង្គណាមួយដែលពឹងពាក់លើសរីរាង្គ ជា "អ្នកផលិត" សំរាប់ធ្វើជាអាហារ ។ អ្នកប្រើប្រាស់ស៊ីរុក្ខជាតិ ឬស៊ីអ្នកប្រើប្រាស់ដទៃទៀត ។ រុក្ខជាតិជាអ្នកផលិត ព្រោះថា វាបង្កើតអាហារតាមរយៈរស្មីសំយោគ ។ រុក្ខជាតិរក្សា ឬគរទុកអាហារទាំងនោះដែលក្រោយមកអាចរកបានចំពោះសរីរាង្គណាមួយដែលពឹងពាក់លើអ្នកផលិត ។

**អ្នកផលិត (Producers) :** សរីរាង្គទាំងឡាយដែលអនុវត្តរស្មីសំយោគ ក្នុងដំណើរការផលិតត្អួយកូស ។ អ្នកផលិត និងសរីរាង្គដែលស៊ីអ្នកផលិតប្រើប្រាស់ត្អួយកូស ជាអាហាររបស់ខ្លួន ។

**ឧស្ម័នកាបូនិច** (Carbon Dioxide) : ខ្លះហៅថា "កាបោនឌីអុកស៊ីត" ដែលជាឧស្ម័នម្យ៉ាងគ្មានពណ៌ គ្មានក្លិន នៅក្នុងសីតុណ្ហភាពធម្មតា និងតាងដោយ $CO_2$ ។ ឧស្ម័ននេះត្រូវរុក្ខជាតិបៃតងស្រូបយកនៅក្នុងបាតុភូតរស្មីសំយោគ ។ វាកើតឡើងដោយសារដំណកដង្ហើមរបស់រុក្ខជាតិ និងសត្វ និងចំហេះឥន្ធនៈធ្យូងថ្ម ។

**ឧស្ម័នផ្ទាំងកញ្ចក់** (Greenhouse Gases) : ឧស្ម័នដែលអណ្តែតក្នុងបរិយាកាសផែនដី និងចាប់យកវិភាយកំដៅពីផ្ទៃផែនដី ។ នេះជាលទ្ធផលនៃសកម្មភាពរបស់មនុស្សជាសំខាន់ ។ ឧស្ម័នទាំងនេះរួមមានកាបោនឌីអុកស៊ីត មេតាន ក្លរ៉ូភ្លុយអរ៉ូកាបោន និងអុកស៊ីតនីទ្រិច ។

# ឯកសារពិគ្រោះ
# (Bibliography)


1 Asia/Pacific Cultural Center for UNESCO 1995. An Ecology Book for Children on Asian/Pacific Trees "TREES"

2 CEAT, UNDP OPS. 1994. Introduction to general environmental concepts.

3 Department of Natural Resources, Bureau of Parks and Recreation & Bureau of Forestry. PUBL-FR-073. 1992. "Forests are Fun"

4 Education Department, Science Section, 1990. Science Field Work Activities, Primary Level Years 3 and 4

5. Education Department, Science Section, 1990. Science Field Work Activities, Primary Level Years 5 and 6.

6 Ministry of Environment in Association with UNDP and other Cooperating Organisations, 1994. First State of the Environment Report.

7 Nick Middleton, Oxford University Press 1988. Atlas of Environmental Issues.

8 Taej Mundkur, Peter Carr, Sun Hean, and Chhim Somean, 1994. NWF/IUCN/WWF Programme Endangered Species in Asia "Surveys for Large Waterbirds in Cambodia".

9 UNEP, UNICEF, 1990. The State of the Environment "Children and the Environment".

10. UNEP, 1995. An Environmental Guide for you and your Community "TAKING ACTION ".

11. Unesco-UNEP International Environmental Education Programme, Series 6, 1985. Environmental Education Module for In-Service Training of Teachers and Supervisors for Primary Schools.

12. Earth's Vanishing Forests, Roy A. Gallant, Macmillan Publishing Company, New York, 1991

13. Environmental Science : The Way the World Works, Bernard J. Nebel, Printice-Hall, Inc, Second Edition, New Jersey, 1987.

14 The Environment : Issues and Choices for Society, Penelope Revelle and Charles Revelle, Jones and Bartlett Publishers, Third Edition, Boston, 1998.

15 វចនានុក្រម ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៦៧